ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការប្រើប្រាស់ដីក្នុង ឃុំតឺន

## ឆ្នាំ ២០០៩-២០២២

## ស្រុកកូនមុំ ខេត្តរតនគិរី



**រៀបចំដោយៈ** គណៈកម្មាធិការផែនការ និងថវិកា/ក្រុមប្រឹក្សាឃុំ/សង្កាត់

**គាំទ្រដោយៈ** ក្រុមសម្របសម្រួលស្រុក និងសម្របសម្រួលផែនការប្រើប្រាស់ដីធ្លីថ្នាក់ស្រុក

ខែ ធ្នូ ឆ្នាំ ២០០៩

# មាតិកា


**អារម្ភកថា** ០៣

**សេចក្តីផ្តើម** ០៤

**ជំពូក១: ពត៌មាននិងទិន្នន័យសំរាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំ** ០៥

**១.១ ស្ថានភាពទូទៅ** ០៥

១.១.១ ទីតាំងរដ្ឋបាល ០៥

១.១.២ ប្រជាសាស្ត្រ ៧

១.១.៣ ភាពគ្មានដីធ្លី ៨

១.១.៤ ស្ថានភាពសេដ្ឋកិច្ច ៨

១.១.៥ ស្ថានភាពអប់រំ និងសិក្សាធិការ ៩

១.១.៦ ស្ថានភាពសុខាភិបាល ១០

១.១.៦.១ ផ្នែកសុខាភិបាល ១០

១.១.៦.២ ការផ្គត់ផ្គង់ទឹកស្អាត ១២

**១.២ ស្ថានភាពភូមិសាស្ត្រ** ១៣

១.២.១ ទីតាំងភូមិសាស្ត្រ ១៣

១.២.២ អាកាសធាតុ ១៤

១.២.៣ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងការដឹកជញ្ជូន ១៥

១.២.៤ ប្រព័ន្ធស្រោចស្រព ១៦

**១.៣ ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន** ១៦

១.៣.១ ស្ថានភាពនៃការប្រើប្រាស់ដី ១៦

១.៣.២ ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដី ១៧

១.៣.៣ ស្ថានភាពកសិកម្ម ១៨

១.៣.៤ ធនធានធម្មជាតិ ២២

១.៣.៤.១ ធនធានព្រៃឈើ ២២

១.៣.៤.២ ធនធានជលផល ២២

**១.៤ ទីផ្សារ និងខ្សែសង្វាក់ផលិតផល** ២២

១.៤.១ ទីផ្សារ និងតំលៃកសិផល ផល-អនុផលព្រៃឈើ និងផលនេសាទ ២២

១.៤.២ ខ្សែសង្វាក់ និងចរាចរផលិតផល ២៣

១.៤.៣ ឱកាស និងឧបសគ្គ ២៣

**ជំពូក២: ការវិភាគគំរូវការសំរាប់អនាគត** ២៥

**២.១ តំបន់រសើប** ២៥

**២.២ ការប្រឈម/ ឧបសគ្គ** ២៦

**២.៣ តំរូវការនៃការអភិវឌ្ឍន៍ និងគោលដៅយុទ្ធសាស្ត្រឃុំ** ២៦

**២.៤ តំរូវការដីសំរាប់អនាគត** ២៧

២.៤.១ ប្រជាសាស្ត្រ ២៧

២.៤.១.១ អត្រាកំណើន ២៧

២.៤.១.២ ការធ្វើចំណោលប្រជាសាស្ត្រ ២៨

២.៤.២ តំរូវការដីសំរាប់លំនៅដ្ឋាន ២៩

២.៤.៣ តំរូវការដីកសិកម្ម ៣០

២.៤.៤ តំរូវការដីសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ ៣១

២.៤.៥ តំរូវការដីសំរាប់ហេដ្ឋារចនាសម្ព័ន្ធសង្គម ៣១

២.៤.៥.១ តម្រូវការសាលារៀន ៣២

២.៤.៥.២ សេវាកម្មសុខភាព និងការផ្គត់ផ្គង់ទឹកស្អាត ៣២

ក. សេវាកម្មសុខភាព ៣២

ខ. ការផ្គត់ផ្គង់ទឹកស្អាត ៣៣

២.៤.៥.៣ ផ្នែកវប្បធម៌ និងសាសនា ៣៣

២.៤.៥.៤ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ ៣៤

**ជំពូក៣: ផែនការប្រើប្រាស់ដីពេលអនាគត ឆ្នាំ២០០៩ ដល់ ២០២២** ៣៦

**៣.១ ស្ថានភាពដី សក្តានុពលដី និងតំរូវការដី** ៣៦

៣.១.១ ស្ថានភាពដីទូទៅ និងសក្តានុពល ៣៦

៣.១.២ តំរូវការដីតាមប្រភេទ ៣៦

**៣.២ ការបែងចែកដីតាមតម្រូវការប្រើប្រាស់** ៣៩

៣.២.១ ការវិភាគអន្តរអំពើ ៣៩

៣.២.២ ផែនទីប្រើប្រាស់ដីនាពេលអនាគត ៤២

៣.២.៣ ការបរិយាយការប្រើប្រាស់តាមក្បាលដី ៤៣

# អារម្ភកថា

របាយការណ៍ស្តីអំពី ផែនការប្រើប្រាស់ដីនៅក្នុងឃុំតឹន ឆ្នាំ២០២២ ត្រូវបានរៀបចំឡើង ដោយក្រុមប្រឹក្សាឃុំតឹននិងមានការចូលរួមពីប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈដោយមានការចូលរួមជួយពីក្រុមអ្នកសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដី (D_LUP) ស្រុកកូនមុំសហការចូលរួមសម្របសម្រួលពីក្រុមអ្នកសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដី (P_LUP) ខេត្តតនគីរី និងគាំទ្របច្ចេកទេសពីក្រុមការងារសមាសភាគរៀបចំដែនដី (Land Management Component) របស់អគ្គនាយកដ្ឋានរៀបចំដែនដី និង នគរូបនីយកម្ម នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ក្រោមការជួយឧបត្ថម្ភថវិកាពីអង្គការ DANIDA/DFID-NZaid តាមរយៈស្ថានទូតដាណឺម៉ាកប្រចាំនៅ ព្រះរាជាណាចក្រកម្ពុជា។ គោលបំណងចំបងនៃ ផែនការប្រើប្រាស់ដី នៅក្នុងឃុំតឹននេះគឺដើម្បី គាំទ្រដល់ដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំកម្មវិធីវិនិយោគឃុំ និងសំរាប់ប្រើប្រាស់ក្នុងការរៀបចំអភិវឌ្ឍន៍ឃុំទាំងមូល ឱ្យមាននិរន្តរភាព ចំទិសដៅ និងឱ្យស្របតាមគោលនយោបាយកាត់បន្ថយភាពក្រីក្រ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ សំដៅពង្រឹងអភិបាលកិច្ចល្អរបស់រាជរដ្ឋាភិបាល ដើម្បីលើកស្ទួយសេដ្ឋកិច្ច និង ជីវភាពរស់នៅរបស់ ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរឡើង។

ក្រុមប្រឹក្សាឃុំតឹន សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងអង្គការ DANIDA/DFID-NZaid តាមរយៈស្ថានទូតដាណឺម៉ាកប្រចាំនៅក្នុងប្រទេសកម្ពុជា ដែលបានផ្តល់ថវិកា ជំនួយសំរាប់ដំណើរការរៀបចំផែនការប្រើប្រាស់ដីធ្លីនេះចាប់តាំងពីការចាប់ផ្តើមរហូតដល់ទីបញ្ចប់។ ជាមួយគ្នានេះដែរ ក៏សូមថ្លែងអំណរគុណផងដែរដល់ក្រុមការងាររបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដីខេត្តរតនគីរី ដែលបានជួយសម្របសម្រួលក្នុងការរៀបចំផែនការនេះ ហើយផែនការប្រើប្រាស់ដី ដែលបានលេចចេញជារូបរាងប្រកបដោយជោគជ័យនេះ ក៏ដោយសារតែមានការចូលរួម និងគាំទ្រពីសំណាក់មន្ទីរពាក់ ព័ន្ធនានាជុំវិញខេត្ត ជាពិសេស គឺអង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត រដ្ឋបាលព្រៃឈើ មន្ទីរកសិកម្ម និងមន្ទីរបរិស្ថានខេត្ត ។

ក្រុមប្រឹក្សាឃុំតឹនក៏មិនអាចបំភ្លេចបានផងដែរនូវការជួយឧបត្ថម្ភគាំទ្រ បង្ហាត់បង្ហាញទាំងទ្រឹស្តីនិងបច្ចេកទេសអនុវត្តផ្ទាល់លើការងារ រៀបចំផែនការប្រើប្រាស់ដី ពីក្រុមអ្នកសម្របសម្រួល រៀបចំផែនការប្រើប្រាស់ដីថ្នាក់ខេត្ត ( P_LUP ) ថ្នាក់ស្រុក (D_LUP) និងក្រុមការងារថ្នាក់ជាតិ របស់សមាសភាគរៀបចំដែនដី។

យើងខ្ញុំទាំងអស់គ្នាសង្ឃឹមថា សម្តេច ឯកឧត្តម លោកជំទាវ អស់លោក-លោកស្រី អ្នកនាងកញ្ញាទាំងអស់នឹងបានយល់ដឹងអំពីស្ថានភាព និង តម្រូវការព្រមទាំងបញ្ហាប្រឈមទាំងឡាយពាក់ព័ន្ធ នឹងការប្រើប្រាស់ដីធ្លី ដែលរាំងស្ទះដល់ដំណើរការអភិវឌ្ឍន៍ឃុំតឹនហើយ នឹងបង្ហាញនូវទឹកចិត្តសប្បុរសធម៌ដ៏ថ្លៃថ្លាតាមរយៈការចូលរួម ផ្តល់នូវសំភារៈ និង ថវិការសំរាប់គាំទ្រការអនុវត្តន៍ផែនការប្រើប្រាស់ដីធ្លីនេះ ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍ មូលដ្ឋានតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ របស់រាជរដ្ឋាភិបាលប្រកបដោយជោគជ័យ។

ឃុំតឹន,ថ្ងៃទី...០៤...ខែ.....០៤......ឆ្នាំ ២០១០

មេឃុំ តឹន

ចា ហ៊ីតាន

# សេចក្តីផ្តើម

តឹនគឺជាឃុំមួយ ស្ថិតនៅក្នុងស្រុកកូនមុំ ខេត្តរតនគីរីដែលមានចំងាយផ្លូវពីក្រុងមកឃុំចំងាយ ២៣គីឡូម៉ែត្រ។ នៅឆ្នាំ ១៩៨០ ដល់បច្ចុប្បន្ននេះ ឃុំតឹនបានជួបប្រទះការគំរាមគំហែងដីធំមួយលើការប្រើប្រាស់ដីអនាធិបតេយ្យ និងមានការបាត់បង់ព្រៃឈើជាបន្តបន្ទាប់ ។ ដោយកំណើនប្រជាជនចេះតែកើនឡើង តំរូវអោយក្រុមប្រឹក្សាឃុំ និង សមាជិក គជថ ប្រជាជននៅក្នុងឃុំបានរួបរួមឯកភាពគ្នាចំនួន ៤ភូមិ (តឹន កាំបាក់ តាហ៊ីយ ឡាអ៊ិន ) ក្នុងគោលបំណងបង្កើតផែនការប្រើប្រាស់ដីឃុំ ស្របច្បាប់ប្រកបដោយតម្លាភាព និងប្រសិទ្ធភាពខ្ពស់ ។

ផែនការប្រើប្រាស់ដី បើនិយាយជារួម បានឆ្លុះបញ្ចាំងពីបញ្ហា និង តំរូវការចាំបាច់ របស់ប្រជាពលរដ្ឋលើវិស័យទាំងប្រាំ ដូចជាសេដ្ឋកិច្ច សង្គមកិច្ច ធនធានធម្មជាតិ និង បរិស្ថាន ផ្នែកសេវាកម្មរដ្ឋបាល និង សន្តិសុខ ផ្នែកយេនឌ័រដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការជាអទិភាពទាំងនេះក្នុងការចូលរួមចំណែក លើកកំពស់ជីវភាពរស់នៅ និង សុខភាពរបស់ប្រជាពលរដ្ឋអោយកាន់តែល្អប្រសើរឡើងជាងមុន បើនិយាយជារួមវិញផែនការប្រើប្រាស់ដីឃុំ ជាឧបករណ៏មួយដ៏សំខាន់ ដែលជួយដល់ក្រុមប្រឹក្សាឃុំ ក៏ដូចជាខេត្តទាំងអស់នៅថ្នាក់ក្រោមជាតិ ក្នុងការចូលរួមចំណែកដល់ការគ្រប់គ្រង់ និងប្រើប្រាស់ធនធានធម្មជាតិ ប្រកបដោយចិរភាព និងប្រសិទ្ធភាព ។ ដូច្នេះការប្រើប្រាស់ដី ឃុំ ជាការងារស្នូលសំរាប់អាជ្ញាធរគ្រប់លំដាប់ថ្នាក់ពិសេសអាជ្ញាធរដែនដី និង មានមូលដ្ឋានអោយកាន់តែគ្រប់ជ្រុងជ្រោយក្នុងការរៀបចំបញ្ចូលផែនការប្រើប្រាស់ដីនៅក្នុង ផែនការអភិវឌ្ឍន៏សេដ្ឋកិច្ចនៅថ្នាក់មូលដ្ឋាន ដោយធ្វើសមាហរកម្មផែនការថ្នាក់ស្រុក និង ការអនុម័តក្នុងការកសាងផែនការអភិវឌ្ឍន៏សេដ្ឋកិច្ចដោយមានការចូលរួមពី គ្រប់ភាគីពាក់ព័ន្ធក្នុងការចូលរួមសេដ្ឋកិច្ច ។

# ជំពូក ១
# ព័ត៌មាន និងទិន្នន័យសម្រាប់កសាងផែនការប្រើប្រាស់ដីនៅក្នុងឃុំសង្កាត់

## ១.១ ស្ថានភាពទូទៅ

ឃុំតឺនបានកកើតឡើងក្នុងឆ្នាំ ១៩៣០ ជាឃុំមួយក្នុងស្រុកកូនមុំ ខេត្តរតនគិរី ។ ក្នុងសម័យអាណានិគមសៀម ចូលមកកាន់កាប់នៅក្នុងតំបន់នេះ ក្រោយមកក៏បានបង្កើតឃុំនេះឡើង ដោយលោក អ៊ំបុន និងអ៊ំតឺន ហើយបានដាក់ឈ្មោះឃុំនេះថាឃុំតឺនតាំងពីនោះមក ដែលមាន ៥ ភូមិ ( ភូមិតឺន ភូមិចាអ៊ុង ភូមិកាំបាក់ ភូមិឡាអ៊ិន ភូមិតាហ៊ីយ ) រហូតមកដល់ឆ្នាំ ១៩៦២-១៩៧៣ ឃុំបានធ្វើការផ្លាស់ប្តូរទីតាំងមករស់នៅឃុំប៉ូយ ដែលចំណុះអោយស្រុកវឺនសៃ ។ ដល់ឆ្នាំ ១៩៧៣ មកដល់ឆ្នាំ ១៩៨៩ បានប្តូរទីតាំងឃុំ មកតាំងទីលំនៅនៅតាមដងអូរខ្វះ នៅភូមិឡាអ៊ិនវិញ ដែលស្ថិតនៅ ក្រោមការគ្រប់គ្រងរបស់ស្រុកលំផាត់ រហូតដល់ឆ្នាំ ១៩៨៩ មកដល់បច្ចុប្បន្ន ឃុំបានធ្វើការផ្លាស់ប្តូរទីតាំង មកនៅភូមិកាំបាក់ ដែលសព្វថ្ងៃមាន ៤ ភូមិ (តឺន កាំបាក់ តាហ៊ីយ ឡាអ៊ិន )ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ស្រុកកូនមុំ ។

### ១.១.១ ទីតាំងរដ្ឋបាល

| | | |
|---|---|---|
| **ខេត្ត** | **រតនគិរី** | |
| **ស្រុក** | **កូនមុំ** | |
| **ឃុំ** | **ឈ្មោះ:** តឺន | **លេខកូដ:** ១៦០៤០៤ |
| **ចំនួនភូមិ** | **៤ ភូមិ ក្នុងនោះមាន :** តឺន កាំបាក់ តាហ៊ីយ ឡាអ៊ិន | |

ឃុំតឺនមានទីតាំង ស្ថិតនៅស្រុកកូនមុំ ដែលមានចំងាយពីស្រុក មកឃុំ ៤០ គីឡូម៉ែត្រ ខាងកើតសាលាស្រុកកូនមុំ បើគិតពីក្រុងមកឃុំ មានចំងាយ ២៣ គីឡូម៉ែត្រ នាទិសខាងលិច ឈាងខាងជើងនៃទីរួមខេត្ត ។ ឃុំនេះមានព្រំប្រទល់ ខាងកើតទល់នឹងឃុំតាអង ខាងលិចទល់នឹងឃុំតាឡាត់ ស្រុកសេសាន្ត ឃុំត្រពាំងក្រហម នឹងឃុំត្រពាំងច្រេស ខាងត្បូងទល់ នឹង ភូមិនាងដី ឃុំសិរីមង្គល ខាងជើងទល់នឹងឃុំហាតប៉ក់ ស្រុកវឺនសៃ និងឃុំចាអ៊ុង ស្រុកអូរជុំ។ ឃុំនេះមានផ្ទៃក្រឡាទំហំ **២៨ ៣៧៥ ហិកតា** ចែកចេញជា ៤ ភូមិគឺ :ភូមិ តឺន កាំបាក់ តាហ៊ីយ ឡាអ៊ិន។

ឃុំតឺនមានទីតាំងរដ្ឋបាលជាខ្សែបន្ទាត់ ចាប់ពីចំនុចអូរព្រាលត្រង់ចំនុចទន្លេសេសាន ទិសខាងលិច ចាក់មកកើតតាមដងអូរ ឡឺងវិច ហើយចាក់ពីអូរឡឺងវិចមកដល់ពាមអូរក្រញ៉ូង និងអូរសំល្បៀង មកកើតរហូតដល់វាលកាសងត្រង់ចំណុចអូរ អន្ទាន់ តាមអូរអន្ទាន់រហូតដល់ពាមអូរស្ទឹង និងអូរទឹង តាមដៃអូរទឹង មកត្បូងរហូតដល់កាត់ស្រែសែនរួចកាត់តាមចំនុច ភូមិតាហ៊ីយ តំរង់កាត់ទៅអូរកាអៀក រួចកាត់អូរត្រាម កាត់អូរខ្វះរហូតដល់ផ្លូវជាតិលេខ ៧៨ ត្រង់ចំការតាពៅ រួចចាប់ពីចំណុច ចំការតាពៅ ចាក់មកដល់ពាមអូរល្បៀង និងអូរម្លូរ ត្រង់ពាមអូរទាំងពីរ ចាក់មកត្បូង

រហូតដល់ចំណុចអូររូង ចាប់ពីចំណុចអូររូងចាក់ទៅទិសខាងលិចតាមដងអូររូងដល់ពាមអូរចាងព្រិច ពីពាមអូរចាងព្រិច កាត់ផ្លូវជាតិលេខ ៧៨ ត្រង់ចំណុចចំការកៅស៊ូ លោក ឈ គៀត ហើយពីផ្លូវ ៧៨ ចាក់មកជើងដល់អូរអង្គង់ រហូតដល់ពាមអូរថ្ម ដល់ពាមអូរក្រូច ហើយតាមអូរក្រូចដល់ចំណុចពាមអូរខ្ទះ និងអូរចារមាញ ១៥០ ម៉ែត្រចាក់មកជើង កាត់អូរក្រាក់ រហូតដល់ត្រពាំងត្រឡាច ដល់ចុងអូរឈុនទូល រួចតាមអូរឈុនទូលមកលិច ដល់ពាមអូរប្រាង (អូរឈុនទូល) ហើយចាប់ពីពាមអូរប្រាង ១៥០ ម៉ែត្រ ត្រង់ចំណុចជើង ភ្នំគ្រែចាក់ទៅជើងដល់ពាមអូរព្រាល និងអូរឡឹងវិចជាប់ទន្លេសេសាន្ត ។




**រូបភាព ០១:** ផែនទីតាំងរដ្ឋបាលឃុំតឺន

### ១.១.២ ប្រជាសាស្ត្រ

ឃុំតឹនមានប្រជាជនសរុបចំនួន **២ ៤៤៣ នាក់** ក្នុងនោះស្រី **១ ២៤១នាក់** ដង់ស៊ីតេប្រជាជនមាន ៣៥នាក់ ក្នុងមួយគីឡូម៉ែត្រក្រឡា ។ របាយប្រជាជនភាគច្រើនគឺប្រមូលផ្តុំនៅតាមភូមិនីមួយៗដែលរស់នៅជាច់ពីគ្នា។ ចំណែក ផ្នែកខាងលិច និងខាងជើងគឺពុំមានប្រជាជនកុះកររស់នៅទេ ប្រជាជនឃុំតឹនមានការតាំងទីលំនៅ ជាការប្រមូលផ្តុំ រស់នៅតាមរដូវកាល សំរាប់ការធ្វើកសិកម្មតាមបែបប្រពៃណីទំនៀម ទំលាប់ ចំការវិលជុំ និង ធ្វើស្រែ (តាមភូមិ និង តាមខ្ទមចាំចំការ) ។ ប្រជាជនឃុំតឹនភាគច្រើនជាជនជាតិ ដើមភាគតិច (គ្រឹង និងទំពួន )ប្រហែល៧០ %និងប្រជាជន ខ្មែរ ១០ភាគរយ ដែលសុទ្ធសឹងជាអ្នករស់នៅទីនោះតាំងតែពី ឆ្នាំ ១៩៣០មក ។តែក្នុងមួយ រយៈពេលចុងក្រោយនេះ យើងសង្កេតឃើញ មានការហូរចូលប្រជាជន មកពីខេត្តក្រៅ មកតាំងទីលំនៅ ក្នុងតំបន់នេះ ដែលមានចំនួនគួរឱ្យ កត់សំគាល់គឺ ប្រមាណជា ២០% ដែលភាគច្រើនជាជនជាតិចាម ដែលមក ពីខេត្ត កំពង់ចាម ក្រចេះ តាកែវ និង ព្រៃវែង។ លើកំណើនដដែលនេះ ក៏មានការកត់សំគាល់ទៅលើការថយចុះនៃអត្រាមរណៈរបស់កុមារផងដែរ។ ចំពោះ ជំនឿ សាសនាប្រជាជននៅក្នុងឃុំតឹន កាន់ជំនឿសាសនា ព្រហ្មញ្ញសាសនា គឺមានការ សែនអារក្ខអ្នកតា និងការ សែនស្រូវ ។

<u>តារាងស្ថិតិប្រជាជនឃុំតឹន ឆ្នាំ២០០៨ តាមក្រុមអាយុ</u>

| ស្ថិតិតាមក្រុមអាយុ | ប្រុស | ស្រី | សរុប | ផ្សេងៗ |
|---|---|---|---|---|
| អាយុក្រោម០៥ឆ្នាំ | ១៤៥ | ១៥៩ | ៣០៤ | |
| អាយុ ០៥ឆ្នាំ | ៤៥ | ៦១ | ១០១ | អាយុចូលរៀនមត្តេយ្យ |
| អាយុពី ៦-១១ឆ្នាំ | ២០៨ | ២៣៤ | ៤៤២ | អាយុចូលរៀនបឋមសិក្សា |
| អាយុពី ១២-១៤ឆ្នាំ | ១៤៣ | ១១៤ | ២៥៧ | អាយុចូលរៀនអនុវិទ្យាល័យ |
| អាយុពី ១៥-១៧ឆ្នាំ | ៨៣ | ៦៧ | ១៥០ | អាយុចូលរៀនវិទ្យាល័យ |
| អាយុពី ១៨-២៤ឆ្នាំ | ១៥៥ | ១៩៣ | ៣៤៨ | អាយុចូលរៀនមហាវិទ្យាល័យ |
| អាយុពី ២៥-៦០ឆ្នាំ | ៣៦៨ | ៣៣២ | ៧០០ | អាយុពេញពលកម្ម |
| អាយុពី ៦១ឆ្នាំឡើងទៅ | ៥៥ | ៨១ | ១៣៦ | អាយុចូលនិវត្តន៍ |
| ប្រជាជនសរុប | ១២០២ | ១២៤១ | ២៤៤៣ | |
| **ចំនួនគ្រួសារសរុប** | **៥៥៥** | | | |

**ប្រភព :** តារាងទិន្នន័យភូមិ ឆ្នាំ ២០០៩

### ១.១.៣ ភាពគ្មានដីធ្លី

កង្វះខាត ឬភាពគ្មានដីធ្លី នៅក្នុងឃុំតឹនហាក់ដូចជាមិនទាន់កើតមានជាបញ្ហាចោទខ្លាំងនៅឡើយទេ បើទោះបី ៦៩% នៃប្រជាជនជាកសិករដែលខ្វះដីស្រែ និងគ្រួសារគ្មានដីលំនៅដ្ឋាន ១% ក៏ដោយក៏ពួកគាត់នៅតែមានការពឹងពាក់យ៉ាងខ្លាំងទៅលើការធ្វើចំការ វិលជុំតាមបែបប្រពៃណីរបស់បងប្អូនជនជាតិដើមភាគតិចរបស់ពួកគាត់ដែរ និងមួយផ្នែកទៀតមានការពឹងផ្អែកទាំង ស្រុងលើធនធានធម្មជាតិ តែទោះបីយ៉ាងណាក៏ដោយ ក៏ពួកគាត់នៅតែមានការខ្វះខាតស្ទើរតែជាង ៤០% នៃគ្រួសារ ទាំងអស់ត្រូវទិញអង្ករបន្ថែមសំរាប់ ការបរិភោគប្រចាំឆ្នាំ ដោយប្រើប្រាស់ចំណូលដែលរកបានពីធនធាន អនុផល ព្រៃឈើដែលមាននៅក្នុងឃុំ ។ នេះមិន មែនជាបញ្ហាក្នុងការខ្វះខាតដីធ្លីទេ តែវាមកពីការធ្វើកសិកម្មយថាផល ដែល មានទិន្នផលទាប និងប្រពៃណី ទំនៀមទម្លាប់ក្នុងការរកទទួលទានរបស់ពួកគាត់តាំងពីដើមមក។

<u>តារាងចំនួនគ្រួសារដែលគ្មានដី និងមានដីមិនគ្រប់គ្រាន់</u>

| លរ | បរិយាយ | ចំនួនគ្រួសារ | ភាគរយ/ប្រជ.សរុប | ផ្សេងៗ |
|---|---|---|---|---|
| ១ | គ្មានដីស្រែផ្ទាល់ខ្លួន | ៣៨៣ | ៦៩% | |
| ២ | មានដីស្រែតិចជាង ១ ហិកតា | ៥ | ១% | |
| ៣ | ចំនួនគ្រួសារគ្មានដីលំនៅដ្ឋាន | ៥ | ១% | |

**ប្រភព:** ឯកសារពត៌មាន ស្តីពីស្ថានភាពឃុំតឹន ឆ្នាំ ២០០៩

### ១.១.៤ ស្ថានភាពសេដ្ឋកិច្ច

ប្រជាជនឃុំតឹន ប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគាត់ ដោយពឹងផ្អែកលើ ការធ្វើកសិកម្មដែលមុខរបរ កសិកម្មទាំងនោះគឺ ៧០% ប្រកបមុខរបរធ្វើចំការវិលជុំ និង ២៥ ភាគរយទៀតធ្វើស្រែវស្សា និងការប្រើប្រាស់ធនធានធម្មជាតិ ជាពិសេសព្រៃឈើ ។ល។

ក្រៅពីមុខរបរធ្វើកសិកម្ម ពួកគាត់តែង តែឆ្លៀតឱកាស នេសាទត្រីតាមដងអូរតូចៗ បរបាញ់សត្វ ស៊ីឈ្នួលកាប់ចំការ ចិញ្ចឹមសត្វ ធ្វើសួនបន្លែតាមគ្រួសារ ដោយដាំដំណាំហូបផ្លែ ដំណាំយុទ្ធសាស្រ្តស្វាយចន្ទី និង បន្លែបង្កា ផ្សេងៗទៀត ។ ក្រៅពីនេះប្រជាពលរដ្ឋឃុំតឹន នៅមានមុខរបរបន្ទាប់បន្សំថែមទៀតដូចជា ការលក់ដូរតាមផ្ទះ នៅតាមភូមិនីមួយៗ និងចូលព្រៃ បោចវល្លិ៍ អារឈើ រកជ័រចុង ជ័រទឹក ផ្សិត ផ្តៅ ទឹកឃ្មុំ ឱសថបុរាណ និងកំរៃមកពី សិប្បកម្មបែបប្រពៃណីដូចជា : ត្បាញកាផា ស្មូនឆ្នាំង ក្អមធ្វើពីដី ធ្វើកាំបិត ពូថៅ ដឹង ឆ្លាក់ចំលាក់ឃ្លោក ។ល។ ហើយផលិតផលដែលពួកគាត់ ផលិតបានមួយចំនួន ទុកសំរាប់ធ្វើជាអាហារ និងមួយចំនួនទៀតយកទៅលក់ ឬដោះដូរជា របស់របរផ្សេងៗ ។ តាមការសាកសួរក្រុមប្រឹក្សាឃុំ និងប្រជាពលរដ្ឋនៅក្នុងឃុំបានអោយដឹងថា ប្រជាជនជាង ២៥ ភាគរយមានរបររកស៊ីធ្វើស្រែ និង ៥០ភាគរយទៀតធ្វើចំការ ដោយពឹងផ្អែកទៅលើរបបទឹកភ្លៀង ប្រជាពលរដ្ឋបច្ចុប្បន្នធ្វើរបរកសិកម្មតាមបែបយថាផល និងមានជីវភាពក្រីក្រច្រើននៅឡើយ ។

តារាងមុខរបរសំខាន់ៗរបស់ប្រជាជនឃុំតឹន

| ល.រ | ប្រភេទមុខរបរ | ចំនួនគ្រួសារ | | ផ្សេងៗ |
|---|---|---|---|---|
| | | ចំនួន | ភាគរយ (%) | |
| ១ | **មុខរបរកសិកម្ម** | | | |
| | ធ្វើស្រែជាចំបង | ៥៥០ | ៩៩.១ | ស្រែវស្សា |
| ២ | **មុខរបរផ្សេងៗក្រៅពីកសិកម្ម** | ០៥ | ០,៩០ | |

ប្រភព: ឯកសារពត៌មាន ស្តីពីស្ថានភាពឃុំតឹន ឆ្នាំ ២០០៩

## ១.១.៥ ស្ថានភាពអប់រំ និងសិក្សាធិការ

ឃុំតឹនមានកំរិតនៃការសិក្សាដល់ ត្រឹមបឋមសិក្សា មានសាលារៀនចំនួន ៧ ដែលមាន ១៥បន្ទប់ ស្មើនឹង ១០ ថ្នាក់ មានគ្រូបង្រៀនចំនួន ១៥ នាក់ បច្ចុប្បន្នតាមពត៌មាន សៀវភៅស្ថានភាពភូមិបានបង្ហាញអោយឃើញថា នៅក្នុងឃុំតឹន កុមារដែលអាយុ ០៥ឆ្នាំ មានចំនួន ១០៦នាក់ ដែលកំពុងចូលរៀន ថ្នាក់មត្តេយសិក្សា និងកុមារចាប់ពីអាយុ ៦-១១ ឆ្នាំមានចំនួនសរុប ៤៤២ នាក់ បើគិតកុមារដែលមិនបានចូលរៀនស្មើនឹង ៥៨% និងសរុបចំនួនមនុស្សអាចចូលរៀននៅថ្នាក់អនុវិទ្យាល័យមានចំនួន ២៥៧នាក់ បើគិតចំនួនមនុស្សដែលមិនបានចូលរៀនមានចំនួនស្មើនឹង ៦៤% និងថ្នាក់វិទ្យាល័យដែលមានមនុស្សដែលត្រូវចូលរៀនមានចំនួន ៤៤នាក់ ស្មើនឹចំនួន ៧១%ដែលមិនបានចូលរៀន។ ទន្ទឹមនឹងនោះដែរ ក្នុងឃុំក៏មានថ្នាក់អក្ខរកម្មដែលកំពុងដំណើរការសិក្សាដែលមានការឧបត្ថម្ភដោយអង្គការមួយចំនួន រួមមានចំនួន៣ថ្នាក់ចំនួនសិស្សអក្ខរកម្មកំពុងសិក្សាមាន ១៥០នាក់ និងបានបញ្ចប់មានចំនួន ១៥០នាក់ សិស្សដែលបានបញ្ចប់ដោយប្រឡងជាប់មានចំនួន ១៥ នាក់ ។ តាមការសាកសួរក្រុមប្រឹក្សាឃុំ និងប្រជាជន បានអោយដឹងថា កុមារដែលមិនបានចូលរៀន និងកុមារដែលបោះបង់ការសិក្សា ដោយសារកុមារទាំងនោះមួយចំនួនតាមឪពុកម្តាយទៅប្រកបការងារធ្វើស្រែចំការនៅឆ្ងាយពីផ្ទះ និង មួយចំនួនទៀតជួយធ្វើការងារឪពុកម្តាយ នៅផ្ទះ និង ខ្វះខាតជីវភាពនៅក្នុងគ្រួសារ ។

ទន្ទឹមនោះដែរ បច្ចុប្បន្នមានការខ្វះខាតគ្រូបង្រៀន និងខ្វះសាលារៀនចាប់ពីកំរិតបឋមសិក្សាដល់វិទ្យាល័យ។ ឯសាលាបឋមសិក្សាមាន ទីតាំងគ្រប់គ្រាន់ តែនៅលើទីតាំងនីមួយៗ មានការខ្វះខាតអាគារសិក្សា ដែល ទាមទារត្រូវមានការសាងសង់បន្ថែម ចំណែកសាលាមតេយ្យមានវិធានការបង្កើតឱ្យបាននៅគ្រប់ភូមិដែលបច្ចុប្បន្ន ពុំទាន់មាននៅឡើយ ។

តារាង ស្ថិតិសាលា និងចំនួនសិស្ស ប្រចាំឆ្នាំ ២០០៨

| ប្រភេទសាលា | ចំនួនសាលានៅឆ្នាំ ២០០៨ | | | ចំនួនកុមារ/សិស្សនៅឆ្នាំ ២០០៨ | | | **អត្រាមិនចូលរៀន** |
|---|---|---|---|---|---|---|---|
| | **សាលា** | **បន្ទប់** | **ថ្នាក់** | **កុមារ** | **សិស្ស** | **សិស្សស្រី** | |
| ថ្នាក់មត្តេយ្យ | ០ | ០ | ០ | ១០៦ | ០ | ០ | ១០០% |
| ថ្នាក់បឋមសិក្សា | ៧ | ១៥ | ១០ | ៤៤២ | ២៣១ | ១១៩ | ៤៨% |
| ថ្នាក់អនុវិទ្យាល័យ | ០ | ០ | ០ | ២៥៧ | ៩២ | ៥២ | ៦៤% |
| ថ្នាក់វិទ្យាល័យ | ០ | ០ | ០ | ១៥០ | ៤៤ | - | ៧១% |

**ប្រភព:** ឯកសារពត៌មាន ស្តីពីស្ថានភាពឃុំតឺន ឆ្នាំ ២០០៨




រូបភាពទី ២ : សាលាបឋមសិក្សា ភូមិតឺន

## ១.១.៦ ស្ថានភាពសុខាភិបាល

### ១.១.៦.១ ផ្នែកសុខាភិបាល

បច្ចុប្បន្នសេវាសុខភាពនៅក្នុង ឃុំតឺនមានមិនទាន់បានបំពេញនូវសេចក្តីត្រូវការនៅឡើយ ព្រោះថាមានភូមិមួយចំនួន ស្ថិតនៅឆ្ងាយពីប៉ុស្តិ៍សុខភាពឃុំ ហើយអ្នកជំងឺនៅភូមិឆ្ងាយៗ ដូចជាភូមិឡាអ៊ិន (តំបន់ឡាអ៊ិនស្រែ តំបន់ម៉ឺនថាំង-១ និងម៉ឺនថាំង-២ ) ភូមិកាំបាក់ មានការពិបាកក្នុងការធ្វើដំណើរបើគិតពីចំងាយផ្លូវមធ្យមពីភូមិមកមណ្ឌល

សុខភាពឃុំមានចំងាយ ២៩.៥០ គីឡូម៉ែត្រ ហើយបច្ចុប្បន្ននោះមណ្ឌលសុខភាពតឹន ដែលមានទីតាំងនៅភូមិកាំបាក់ មានគ្រូពេទ្យចំនួន ០២នាក់ និងឆ្មបបូរាណ ១២នាក់ផងដែរ។ តែដោយឡែក គ្រូពេទ្យដែលបំរើការងារសព្វថ្ងៃ មានជំនាញមានកំរិត រឹងសេវាផ្សព្វផ្សាយពីការថែទាំសុខភាពមិនទាន់បានទូលំទូលាយ កត្តានេះហើយបានធ្វើអោយ ប្រជាជនមួយចំនួនគាត់មិនបានទៅទទួលសេវាសុខភាពទេ។ អ្នកភូមិខ្លះ នៅពេលគាត់មានជំងឺធ្ងន់ធ្ងរ ពួកគាត់តែងតែ មានការកាប់ជ្រូក ឬមាន់ ឬក្របី ដើម្បីសែនព្រេន អ្នកភូមិខ្លះទៀត ក៏មកព្យាបាលនៅពេទ្យខេត្តដែលមានចំងាយផ្លូវ ១៨គីឡូម៉ែត្រ ទៅ ៣០ គីឡូម៉ែត្រ។

ផ្អែកទៅតាមស្ថានភាពភូមិសាស្ត្រនៃឃុំតឹន ដែលមានប្រជាជនរស់នៅតាមភូមិដាច់ឆ្ងាយពីគ្នា និងមានចំងាយ ផ្លូវឆ្ងាយពីប៉ុស្ដិ៍សុខភាពឃុំ បណ្ដាលអោយមានការលំបាកក្នុងការធ្វើដំណើរ ដូច្នេះការផ្ដល់សេវាកម្មផ្នែកសុខភាព មិនទាន់គ្រប់គ្រាន់ទេ។ ស្ថិតក្នុងដំណាក់កាលនេះឃុំតឹន ក៏ពុំទាន់មាន ប៉ុស្ដិ៍សុខភាពនៅតាមភូមិ សំរាប់ជួយសំរួល ដល់ ការទ្រទ្រង់សុខមាលភាពរបស់ប្រជាពលរដ្ឋ បន្ថែមលើប៉ុស្ដិ៍សុខភាពភូមិនៅឡើយទេ ។




**រូបភាពទី ៣ :** ប៉ុស្ដិ៍សុខភាពតឹន

តារាងស្ថិតិមណ្ឌល/ប៉ុស្តិ៍សុខភាព និងចំនួនគ្រូពេទ្យ

| ល.រ | មណ្ឌល/ប៉ុស្តិ៍សុខភាព | សមត្ថភាពផ្គត់ផ្គង់សេវាកម្ម | | | | |
|---|---|---|---|---|---|---|
| | | ចំនួន | គ្រែ/បន្ទប់ | គ្រូពេទ្យ | ពេទ្យឆ្មប | ឆ្មបបុរាណ |
| ១ | មណ្ឌលសុខភាព | 0 | 0 | 0 | 0 | 0 |
| ២ | ប៉ុស្តិ៍សុខភាពឃុំ | ១ | ២ | ២ | 0 | ១២ |
| ៣ | ប៉ុស្តិ៍សុខភាពភូមិ | 0 | 0 | 0 | 0 | 0 |

ប្រភព: ឯកសារពតិមាន ស្តីពីស្ថានភាពឃុំតឹន ឆ្នាំ ២000

### ១.១.៦.២ ការផ្គត់ផ្គង់ទឹកស្អាត

ចំពោះសេវានៃការប្រើប្រាស់ទឹកស្អាតប្រជាជននៅក្នុងឃុំតឹនមានអណ្តូងទឹកចំនួន ២៧ ក្នុងនោះមាន អណ្តូងស្នប់ ចំនួន ១២ អណ្តូងលូ0៤ និងអណ្តូងដៃ (មិនដាក់លូ) ចំនួន១១ ដែលឧបត្ថម្ភដោយអង្គការក្រៅរដ្ឋាភិបាល ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋនៅក្នុងឃុំតឹន មានតែប្រមាណ៥0% ប៉ុណ្ណោះ ប្រើប្រាស់ទឹកអណ្តូង រីឯប្រមាណ ៥0%ផ្សេងទៀត នៅតែបន្តប្រើប្រាស់ទឹកអូរនៅឡើយ ។

រីឯការប្រើប្រាស់បង្គន់អនាម័យប្រជាជនឃុំតឹន បច្ចុប្បន្នមិនមានទំលាប់ក្នុងការប្រើប្រាស់បង្គន់ទេ នៅពេលពួកគាត់បន្ទោបង់ពួកគាត់តែងតែចូលទៅព្រៃ ។

តារាងស្ថិតិប្រភពទឹកប្រើប្រាស់នៅក្នុងឃុំ តឹន

| ល.រ | ប្រភពទឹកស្អាត | ចំនួនប្រភពទឹក | | | សំគាល់ |
|---|---|---|---|---|---|
| | | សរុប | ប្រើបាន | ខូចខាត | |
| ១ | អណ្តូងស្នប់ ឬអណ្តូងចំរុះ | ១២ | ១១ | 0១ | ខូចត្រូវជួសជុលឡើងវិញ |
| ២ | អណ្តូងលូ | 0៤ | 0៣ | 0១ | ខូចត្រូវស្តារឡើងវិញ |
| ៣ | អណ្តូងដៃ (មិនដាក់លូ) | ១១ | ១១ | 00 | |

ប្រភព: ឯកសារពតិមាន ស្តីពីស្ថានភាពឃុំតឹន



**រូបភាពទី ៤:** អណ្តូងទឹកស្អាតតឺន

## ១.២.ស្ថានភាពភូមិសាស្ត្រ

### ១.២.១ ទីតាំងភូមិសាស្ត្រ

ភូមិសាស្ត្រឃុំតឺនមានរាងទ្រវែង បណ្តោយប្រមាណជា ៣៥ គម. និងទទឹងនៃចំនុចកណ្តាលរាងផតប្រមាណជា ៥.៥០គម. និងផ្នែកខាងត្បូងរាងស្រួចដែលប្រវែងប្រមាណ ១២គម ចំណែកផ្នែកខាងលិច ឈាងខាងជើងមានប្រវែងទទឹង ១២ គម បញ្ឆិតលាត សន្ធឹងយ៉ាងវែងតាមទិសដៅពីទិសនិរតី មកទិសឥសាន។

នៅផ្នែកខាងជើងជាប់នឹងដងទន្លេសេសាន្តជាតំបន់ខ្លង់រាប ដែលផ្នែកខាងជើងនេះមានរយៈកំពស់ពីប្រមាណ ៦៥ម ដល់ ៨២ម នឹងសណ្តូកមកត្បូងរហូតមកដល់ចំណុចកណ្តាលរាងផតមានរយៈកំពស់ពី៨២ម ដល់ ១៣៨ ម ហើយភាគ ខាងត្បូងឈាងខាងកើតដែលជាតំបន់កូនភ្នំមានរយៈកំពស់ ១៣៨ម ដល់ ២១៦ម និងត្រង់ចំណុចស្តួចនៃទិសខាងត្បូង និងកើតមានរយៈកំពស់ចាប់ពី ២១៦ ដល់ ៤០២ ដោយសារតំបន់ខ្ពស់នេះជាតំបន់កូនភ្នំ ជាទីជំរាលដែលមានផ្លូវទឹក ហូរយ៉ាងខ្វាត់ខ្វែងតែភាគច្រើន មានទឹកហូរខ្លាំងតែនៅរដូវវស្សាទឹកនេះ ប្រមូលផ្តុំហូរចាក់ចូលមកទន្លេសេសាន្ត។




**រូបភាព ០៥:** ផែនទីបង្ហាញរយះកំពស់ឃុំតឺន

## ១.២.២ អាកាសធាតុ

យោងតាមកំណត់ត្រា របស់នាយកដ្ឋានឧត្តុនិយមនៃក្រសួងធនធានទឹក និងឧត្តុនិយម ពីឆ្នាំ ២០០៣-២០០៦ បង្ហាញអោយឃើញថា កំពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំខ្ពស់ជាងគេ ២៧៩១,៧មម នៅឆ្នាំ ២០០៦ ហើយទាបជាងគេ ២១១៩,៨មម នៅឆ្នាំ២០០៤។ ភ្លៀងធ្លាក់ច្រើននៅរដូវវស្សាចាប់ពីខែ ឧសភា ដល់ខែកញ្ញា ដែលកំពស់ទឹកភ្លៀងមធ្យមពី ១៧២,០-៧៤៦,៧មម។

រយៈពេលនៃរដូវប្រាំង ៦ ខែ គឺចាប់ពីខែ ធ្នូ ដល់ខែ មេសា និងរយៈពេលនៃរដូវវស្សា ពីខែ ឧសភា ដល់ ខែ តុលា ហើយចំពោះការប្រែប្រួលមានលំអៀងតិចតួចប៉ុណ្ណោះ ដោយជួនកាលអាចរាំងតាំងពីពាក់កណ្តាល ខែធ្នូ។




| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 11 | 12 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| " 2003" | 0.0 | 0.0 | 90.8 | 121.0 | 390.2 | 287.1 | 480.3 | 396.6 | 452.7 | 77.6 | 55.6 | 0.0 |
| " 2004" | 0.0 | 0.0 | 48.6 | 23.8 | 172.0 | 511.1 | 413.8 | 509.4 | 400.5 | 32.6 | 8.0 | 0.0 |
| "2005" | 0.0 | 0.0 | 6.4 | 48.8 | 195.7 | 300.9 | 643.6 | 746.7 | 408.5 | 128.4 | 13.6 | 7.4 |
| " 2006" | 0.0 | 0.0 | 0.0 | 147.2 | 317.6 | 212.2 | 682.9 | 642.0 | 504.5 | 257.6 | 0.0 | 27.7 |

ខែ ១២

**រូបភាព ០៦:** ក្រាភិច របាយទឹកភ្លៀងមធ្យមប្រចាំឆ្នាំ ខេត្តរតនគីរី

## ១.២.៣ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន

មានផ្លូវក្រាលគ្រួសក្រហមភ្ជាប់មកពីទីរួមខេត្តបានលុង តាមបណ្តោយផ្លូវជាតិលេខ ៧៨ ដែលមានចម្ងាយប្រមាណ ២០គម. នេះជាហេដ្ឋារចនាសម្ព័ន្ធផ្លូវគោកយ៉ាងសំខាន់ សំរាប់ឃុំ ។ តាមប្រសាសន៏របស់លោកមេឃុំ ក្រុមប្រឹក្សាឃុំ និងប្រជាជននៅក្នុងឃុំបានបញ្ជាក់ច្បាស់ថា ហេដ្ឋារចនាសម្ព័ន្ធផ្លូវគោកនៅក្នុងឃុំតឺនសំរាប់ផ្លូវក្រាលគ្រួសក្រហមមានចំនួន ៣ខ្សែ គឺពីឃុំតឺនមកភូមិឡាអ៊ិនស្រែ និងចាក់មកផ្លូវជាតិលេខ ៧៨ ដែលមានចំនួន ២ខ្សែ មានប្រវែង ២០៣០៣ ម និងមួយខ្សែទៀតពីភូមិ កាំបាក់ មកភូមិតាហ៊ីយមានប្រវែង ៤២២៩ ម និងមួយខ្សែទៀតផ្លូវជាផ្លូវជាតិ ៧៨ ដែលមានប្រវែង ៦៥៧៦ ម ចំពោះផ្លូវដើរជើងសរុបមានចំនួន ១៤ ខ្សែដែលរួម មានផ្លូវដីស និងដីក្រហម ។

ហើយហេដ្ឋារចនាសម្ព័ន្ធផ្លូវគោកទាំងនេះ មានសារៈសំខាន់ណាស់ដែលបានជួយដល់ប្រជាជននៅក្នុងឃុំ ក៏ដូចអ្នកនៅក្រៅឃុំដែរក្នុងការដឹកទំនិញផ្សេងៗ និងផលិតផលនាំយកទៅលក់នៅទីរួមខេត្ត ។



**រូបភាពទី ៧ :** ផ្លូវលំក្រាលគ្រួសក្រហមក្នុងឃុំតឹន ផ្លូវបំបែកទៅភូមិឡាអ៊ិន និងភូមិកាំបាក់

### ១.២.៤ ប្រព័ន្ធស្រោចស្រព

បច្ចុប្បន្នប្រព័ន្ធស្រោចស្រពនៅក្នុងឃុំតឹន យើងសង្កេតឃើញថា មិនទាន់បានអភិវឌ្ឍន៍ នៅឡើយ ហើយប្រព័ន្ធស្រោចស្រពទាំងនោះមានប្រភពពីដងអូរតូចៗ ជាពិសេស អូរខ្វេះ តែត្រូវតែមានការសិក្សាអោយបានច្បាស់លាស់ជាមុនសិនទើបឃុំអាចរៀបចំជាប្រព័ន្ធស្រោចស្រពសំរាប់ពេលអនាគត ។

## ១.៣ ស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

### ១.៣.១ ស្ថានភាពនៃការប្រើប្រាស់ដី

ក្នុងឃុំតឹនមានចំណាត់ថ្នាក់នៃការប្រើប្រាស់ដីលំអិតចំនួន ១៧ ប្រភេទ រួមមានដីលំនៅដ្ឋានភូមិ (ផ្ទះ-ឈើហូបផ្លែ) ព្រៃអារក្ស( ព្រៃគោរពបូជា )ស្រូវវស្សា ដីកសិកម្មពនេចរ ( ដីចំការផ្លាស់វេន ) ព្រៃស្រោងសើម (ព្រៃញាតមាន ឈើធំៗ) ព្រៃល្បោះ ព្រៃល្បោះស្ងួត ព្រៃចំរុះ(ស្រោង និងរបោះ) ព្រៃដុះឡើងវិញ ( ព្រៃកម្ពោធ

)វាលស្មៅ (ស្រែបោះបង់) ចំការបោះបង់ដុះស្មៅ (ព្រៃបូស) ព្រៃគម្ពោធ ចំការបោះបង់ដុះព្រៃគម្ពោធព្រៃគម្ពោធលាយដើមឈើ ធំមួយៗ ព្រៃដុះតាមមាត់ទឹក វាលភក់ ចំការឈើហូបផ្លែ ។

<u>តារាងប្រភេទនៃការប្រើប្រាស់ដីលំអិត</u>

| លរ | ប្រភេទនៃការប្រើប្រាស់ដី | ទំហំ (ហត) | | ចំណាត់ថ្នាក់របស់មូលដ្ឋាន |
|---|---|---|---|---|
| | | $ម^2$ | ហត | |
| ១ | ដីលំនៅដ្ឋានភូមិ | ២៩៣៨៣៩ | ២៩ | ផ្ទះ-ឈើហូបផ្លែ |
| ២ | ព្រៃអារក្ស | ៥៧៦៨៧៣ | ៥៨ | ព្រៃគោរពបូជា |
| ៣ | ស្រូវវិស្សា | ៤០២៨៧១៥ | ៤០២ | ស្រូវវិស្សា |
| ៤ | ដីកសិកម្មពនេចរ | ១២៨៨២៩៣០ | ១២៨៩ | ដីចំការផ្លាស់វេន |
| ៥ | ព្រៃស្រោងសើម | ១១១៧៩៥៣៨៥ | ១១១៧៩ | ព្រៃញាតមានឈើធំៗ |
| ៦ | ព្រៃរបោះ | ៦៣៧១១៦៩០ | ៦៣៧១ | ព្រៃរបោះ |
| ៧ | ព្រៃរបោះស្ងួត | ១៣៤៦៧២៣ | ១៣៥ | ព្រៃរបោះស្ងួត |
| ៨ | ព្រៃចំរុះ(ស្រោង និងរបោះ) | ១៩២៤៧៨១៦ | ១៩២៥ | ព្រៃចំរុះ (ស្រោង និងរបោះ) |
| ៩ | ព្រៃដុះឡើងវិញ | ២៩៥៥៧១៨៧ | ២៩៥៦ | ព្រៃកម្ពោធ |
| ១០ | វាលស្មៅ | ១៦៧៨១១៩ | ១៦៨ | ស្រែបោះបង់ |
| ១១ | ចំការបោះបង់ដុះស្មៅ | ៩៨១៨៧៣០ | ៩៨២ | ព្រៃបូស |
| ១២ | ព្រៃគម្ពោធ | ២៧៩៤៦ | ៣ | ព្រៃគម្ពោធ |
| ១៣ | ចំការបោះបង់ដុះព្រៃគម្ពោធ | ១៤៣៤៩២៨៥ | ១៤៣៥ | ចំការបោះបង់ដុះព្រៃគម្ពោធ |
| ១៤ | ព្រៃគម្ពោធលាយដើមឈើធំមួយៗ | ៥០០៦៨៥៦ | ៥០០ | ព្រៃគម្ពោធលាយដើមឈើធំមួមយៗ |
| ១៥ | ព្រៃដុះតាមមាត់ទឹក | ៣៩២៩១០ | ៣៩ | ព្រៃដុះតាមមាត់ទឹក |
| ១៦ | ចំការឈើហូបផ្លែ | ១១៨០២៤៥៧ | ១១៨០ | ចំការឈើហូបផ្លែ |
| ១៧ | វាលភក់ | ៤៦៥៥១៦ | ៤៨ | វាលភក់ |
| | សរុប | ២៨៧៣៤៦៩៣៧ | ២៨ ៣៧៥ | |

<u>ប្រភព</u>: ទិន្នន័យ GIS ថ្នាក់ជាតិ/សមាសភាគរៀបចំដែនដី **បានធ្វើបច្ចុប្បន្នភាពជាមួយក្រុមប្រឹក្សាឃុំ ថ្ងៃទី...ខែ...ឆ្នាំ ២០០៩**

## ១.៣.២ ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដី

ក្នុងឃុំទាំងមូល បើនិយាយអំពីកម្មសិទ្ធិដីរបស់ប្រជាពលរដ្ឋ គឺមានការរៀបចំចុះបញ្ជីដីសហគមជនជាតិដើមភាគតិចជាលក្ខណៈប្រព័ន្ធ ១ភូមិគឺភូមិឡាអ៊ិន ដែលរៀបចំដោយអង្គការ GTZ សហការណ៍ជាមួយមន្ទីររៀបចំដែនដី និងក្រសួងរៀបចំដែនដី ចំណែកភូមិដទៃទៀតមិនទាន់មានការចេញប័ណ្ណ សំគាល់អចលនវត្ថុជូនដល់ប្រជាពលរដ្ឋ

នៅឡើយទេ តែចំពោះដីកសិកម្មពនេចរ គឺពួកគាត់មានការគ្រប់គ្រង និងកាន់ កាប់តាមបែបប្រពៃណីរបស់បងប្អូនជនជាតិដើមភាគតិចទំពួន។ ដោយឡែកប្រជាពលរដ្ឋនៅក្នុងឃុំតឹនបានស្រស់ស្រួលគ្នាបង្កើតជាសហគមន៍ព្រៃឈើ ២កន្លែង ដែលមានទំហំសរុប ៥៤៣៨.២៧៨ ហិកតា ដែលគ្រប់គ្រងដោយសហគមន៍ឃុំតឹនផ្ទាល់ ។

តារាងសង្ខេបស្ថានភាពកាន់កាប់និងគ្រប់គ្រងដី

| ល.រ | ប្រភេទនៃការគ្រប់គ្រង | ទំហំដី (ហត) | ផ្សេងៗ |
|---|---|---|---|
| ១ | សហគមន៍ព្រៃឈើតឹនការពារដោយសហគមន៍(១) | ២២៩៤.៤៤៧ | ដីសាធារណៈរបស់រដ្ឋ |
| | ចំការបោះបង់ដុះស្មៅ | ៤៦.២០៧ | ៤ កន្លែង ស្ថិតនៅក្នុងឃុំទាំងស្រុង |
| | ព្រៃរបោះ | ១១២៤.៩៧០ | ២កន្លែង |
| | ព្រៃស្រោងសើម | ១០២៤.០៣៣ | ៦ កន្លែង |
| | ព្រៃចំរុះ(ស្រោង និង របោះ) | ៣.៩០៧ | ២កន្លែង |
| | ព្រៃដុះឡើងវិញ | ៨៦.២៨៧ | ១កន្លែង |
| | ដីកសិកម្មពនេចរ | ៨.២១៩ | ៣កន្លែង |
| | ស្រូវវិស្សា | ១.២២២ | ១កន្លែង |
| ២ | សហគមន៍ព្រៃឈើតឹនការពារដោយសហគមន៍(២) | ៣១៤៣.៨៣១ | ដីសាធារណៈរបស់រដ្ឋ |
| | ចំការបោះបង់ដុះស្មៅ | ៣១.៣៩៧ | ៣កន្លែង |
| | ព្រៃរបោះ | ១២៩២.៨០៤ | ៧កន្លែង |
| | ព្រៃស្រោងសើម | ១៥៣៦.៧៤៤ | ៤កន្លែង |
| | វាលភក់ | ១០.៦៥៦ | ១កន្លែង |
| | ព្រៃចំរុះ(ស្រោង និង របោះ) | ៦៥.៨៣៥ | ២កន្លែង |
| | ព្រៃដុះឡើងវិញ | ១៩១.៨៣៥ | ១កន្លែង |
| | ដីកសិកម្មពនេចរ | ៣.៩៣៥ | ១កន្លែង |
| | ស្រូវវិស្សា | ១០.៦២០ | ២កន្លែង |
| សរុប | | ៥៤៣៨.២៧៨ | |

**ប្រភព**: ទិន្នន័យ GIS របស់រដ្ឋបាលព្រៃឈើឆ្នាំ ២០០៩

## ១.៣.៣ ស្ថានភាពកសិកម្ម

ឃុំតឹនប្រជាជនភាគច្រើនជាកសិករ ដែលប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគាត់ ដោយពឹងផ្អែកលើ ការធ្វើកសិកម្មតាមបែបប្រពៃណី និងការប្រើប្រាស់ធនធានធម្មជាតិ ជាពិសេសព្រៃឈើ ។ ការធ្វើកសិកម្មនៅឃុំតឹន ភាគច្រើនប្រជាជន ធ្វើស្រែដែលពឹងផ្អែកទាំងស្រុងលើរបបទឹកភ្លៀងដើម្បីស្រោចស្រពចំពោះគុណភាពដីសំរាប់ធ្វើស្រែពុំសូវ

មាន គុណភាពដីទេ ដែលទិន្នផលទទួលបានប្រចាំឆ្នាំ ១.៥ តោន ក្នុងមួយហិកតា ដោយឡែកកសិកម្មពនេចរនៅតំបន់ នោះ គឺធ្វើបានផលល្អប្រសើរតែក្នុងរយៈឆ្នាំទី១-៣តែប៉ុណ្ណោះ ហើយដីនេះត្រូវបានបោះបង់ចោល រហូតទៅដល់ខួបពី ៨ ដល់ ១០[១] ឆ្នាំទើបអាចវិលមកធ្វើកសិកម្មសារជាថ្មីលើដីនោះ។



**រូបភាព ០៨:** ការធ្វើកសិកម្មពនេចរនៅក្នុងឃុំតឺនរបស់បងប្អូនជនជាតិដើមភាគតិចនៅក្នុងរដូវប្រមូលផល

[១] ខួបរយៈពេល ១០ឆ្នាំសំរាប់កសិកម្មពនេចរ គឺជាខួបមួយខ្លី ដែលការវិលជុំបែបនេះនឹងធ្វើឱ្យដីខ្សោះជីជាតិជាលំដាប់

តារាងក្រឡាផ្ទៃតាមផលិតភាពដី ការប្រើប្រាស់ និងផលិតផល

| ល.រ | ចំណាត់ថ្នាក់ដីមានជីជាតិ (តាមបច្ចេកទេស) | ចំណាត់ថ្នាក់ដីមានជីជាតិ (តាមមូលដ្ឋាន) | ផ្ទៃក្រឡា ( ហត) |
|---|---|---|---|
| ១ | **ដីមានផលិតភាពទាប** | ដីក្រហម - ល្បាយគ្រោះល្បាយខ្សាច់ | ១៤៣៩៥.៧២៣ |
| | ដីលំនៅដ្ឋានភូមិ | ដំណាំ ស្វាយ, ដូង ,ចេក,ខ្នុរ,ស្រូវចំការ....... | ៥.៥៤៩ |
| | ដីស្រែវស្សា | ស្រូវធ្ងន់ :នាងនួ,ក្រមួនស សូមាលី<br>ស្រូវស្រាល : នាងខួន ក្រចកចាប ប្រវិកស ស្រូវ<br>ស្រូវកណ្តាល : ស្រូវដំណើប ចំបើងលឿង ប្រកិន | ២៨៣ |
| | ដីកសិកម្មពនេចរ | ស្វាយចន្ទី.សណ្តែក.ស្រូវដំណាំ.ល្ង.ចេក.ល្ពៅ.<br>ឃ្លោក.កុកត្រីវ.ននោង.ត្រឡាច.ដំឡូង | ៣២៨ |
| | ព្រៃអារក្ស | នាងនួន.ស្រឡៅ.គគី.ត្រាច.ត្បែង.ក្លុង | ៥២.៩២៣ |
| | ព្រៃគម្ពោធលាយដើមឈើធំមួយៗ | គគី.ស្រឡៅ.ត្រាច.ត្បែង.វាលស្មៅ | ៥០០ |
| | ព្រៃដុះឡើងវិញ | ខ្លុង ត្រាច ត្បែង រការ | ១៩១៩.៦៩៧ |
| | ព្រៃដុះតាមមាត់ទឹក ( អូរ,ស្ទឹង...) | ត្រាវព្រៃ ស្ពាយ ស្មោរ ឬស្សី | ២.១៩៤ |
| | ព្រៃចំរុះ( ស្រោង និង របោះ) | កូនឈើច្រើនប្រភេទដុះ | ១៤២០.៨២៣ |
| | វាលភក់ | ត្រីរស់ ត្រីក្រចុះថ្ម កង្កែប ។ល។ | ២២.៤៣៣ |
| | វាលស្មៅ | ស្មៅ ព្រិច បន្លាសណ្តែកខ្មោច | ៧៤.២៤៩ |
| | ព្រៃស្រោងសើម) | គគី ធ្នឹក សុក្រម ស្រឡៅ ត្រសេក | ៦៩៣១.៧៤៧ |
| | ព្រៃស្រោងស្ងួត | បេង នាងនួន កកោះ ធ្នង់ | ១៣០.៨៧២ |
| | ព្រៃរបោះ | ខ្លុង ត្រាច ត្បែង កំភ្លា ក្រវ៉ាន់ ស្ពាយ | ១១២៣.៨៩៤ |
| | ចំការបោះបង់ដុះព្រៃគម្ពោធ | ដើមឈើចំរុះតូចៗ | ៨៨២.៣២៧ |
| | ព្រៃគម្ពោធលាយដើមឈើធំមួយៗ | ធ្នឹក,ត្រយឹង,ស្ពៅ,អង្រ្កង | ៧១៩.២៥០ |
| ៣ | **ដីមានផលិតភាពខ្ពស់** | ដីក្រហម-កណ្តេងប្រផេះល្បាប់អាចម៍កណ្តុរ | ១៤៣៣៨.៩៦៩ |
| | ស្រូវវស្សា | ស្រូវធ្ងន់ :នាងនួ,ក្រមួនស សូមាលី<br>ស្រូវស្រាល : នាងខួន ក្រចកចាប ប្រវិកស ស្រូវ<br>ស្រូវកណ្តាល : ស្រូវដំណើប ចំបើងលឿង ប្រកិន | ១១៩.៨៦៥ |
| | ដីលំនៅដ្ឋាន ភូមិ | សំរាប់ដំណាំ ស្វាយ, ដូង ,ចេក,ខ្នុរ,ស្រូវចំការ....... | ១៩.៨៣៤ |
| | ដីកសិកម្មពនេចរ | ស្វាយចន្ទី.សណ្តែក.ស្រូវដំណាំ.ល្ង.ចេក.ល្ពៅ.<br>ឃ្លោក.កុកត្រីវ.ននោង.ត្រឡាច.ដំឡូង | ៩៦២.២២៤ |

| | | | |
|---|---|---|---|
| | ព្រៃអារក្ស | នាងនួន គគី កកោះ ស្រឡៅ ល្បៀង ឬស្សី | ៤.៧៦៣ |
| | ព្រៃគម្ពោធ | ស្មៅព្រិច ឬស្សី វល្លិ៍ចុល្លព្រឹក្សិ៍ ល្បៀង | ២.៧៩៤ |
| | ព្រៃដុះឡើងវិញ | ខ្លុង,ត្រាច,ត្បែង,រការ | ១០៧៦.០២១ |
| | ព្រៃដុះតាមមាត់ទឹក ( អូរ,ស្ទឹង...) | ត្រាវព្រៃ ស្វាយ ស្មោរ ឬស្សី | ៣៧.០៩៦ |
| | ចំការឈើហូបផ្លែ | ស្វាយ ខ្នុរ ចន្ទី ចេក ដូង ក្រូច ត្របែក | ១១៨០.២៤៥ |
| | ព្រៃចំរុះ( ស្រោង និង របោះ) | កូនឈើច្រើនប្រភេទដុះ | ៥០៣.៩៥៧ |
| | វាលភក់ | ជាត្លុកតូចៗ | ២៤.៥១៨ |
| | វាលស្មៅ | ប្រភេទស្មៅបារាំង | ៩៣.៥៦២ |
| | ព្រៃស្រោងសើម | បេង នាងនួន កកោះ ស្រឡៅ ត្បែង ត្រាច ផ្ដៅ | ៤២៤៧.៧៨៦ |
| | ព្រៃស្រោងស្ងួត | បេង,នាងនួន,កកោះ,ធ្នង់ | ៣.៨០០ |
| | ព្រៃរបោះ | ខ្លុង,ត្រាច,ត្បែង,កំភ្លា,ក្រវាន់,ស្វាយ | ៥២៤៧.២៧៤ |
| | ចំការបោះបង់ដុះព្រៃគម្ពោធ | ប្រភេទព្រៃផ្សេងៗមានដើមឈើតូច | ៥៥២.៦០១ |
| | ព្រៃគម្ពោធលាយដើមឈើធំមួយៗ | ឆ្លីក,ត្រយឹង,ស្ពៅ,អង្គ្រង | ២៦២.៦២២ |

**ប្រភព**: ទិន្នន័យ GIS ថ្នាក់ជាតិ/សមាសភាគរៀបចំដែនដី/អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម




**រូបភាព ០៩:** ផែនទីផលិតភាពដី

### ១.៣.៤ ធនធានធម្មជាតិ

#### ១.៣.៤.១ ធនធានព្រៃឈើ

ឃុំតឹនសំបូរទៅដោយធនធានធម្មជាតិជាច្រើនដូចជាព្រៃឈើសំខាន់ៗ ដែលមានមុខងារផ្នែក អេកូឡូស៊ី នឹងមុខងារផ្នែកសេដ្ឋកិច្ចយ៉ាងសំខាន់ដែលមានឈើសំណង់ ដូចជាឈើ គគី ស្រឡៅ កកោះ សុក្រម ឈើទាល ផ្ចឿក នាងនួន បេង ធ្នុង ក្រញូង ត្រាច ឃុំនេះមានផ្ទៃដីព្រៃឈើសរុបចំនួន ២៨៧៣៥.១៤៥ហិកតា ក្នុងនោះមានព្រៃស្រោង ចំនួន ១២២៥៧.៥២ ហិកតា ហើយព្រៃពាក់កណ្តាលស្រោងមានចំនួន ២៦០៨.១៩៤ ហិកតា និងព្រៃល្បោះចំនួន ៧៦៧១.៦០៩ ហិកតា ហើយព្រៃផ្សេងៗមានចំនួន ១៦៤.៦១៧ ហិកតា និងដីមិនមែនព្រៃចំនួន ៦០៣៣.២០៥ ហិកតា ។ មានប្រភេទរុក្ខជាតិផ្សេងទៀតសំរាប់ជាជំរក និងចំណីសត្វព្រៃ,ស្រុកគ្រប់ប្រភេទ មិនតែបណ្តោះផ្តល់នូវដីសំបូរជីជាតិ សំរាប់ធ្វើចំការស្រែ និងឈើសំណង់គ្រប់ប្រភេទ សំរាប់បំរើជីវភាពដល់ប្រជាជនសហគមន៍ ដែលសំដៅតាមតំបន់មាត់ព្រៃដូចជា រកជ័រ ផ្តៅ ឬស្សី បន្លែបង្ការផ្សេងៗដោះដូរជីវភាពក្នុងគ្រួសារ ។ ចំណែកសត្វព្រៃ ដូចជា ឈ្លូស ប្រើស ជ្រូកព្រៃ ខ្ទីង សំបូរនៅតាមព្រៃស្រោង ។ បច្ចុប្បន្ននេះធនធានដែលមានតំលៃទាំងនេះត្រូវបានបាត់បង់បន្តិចម្តងៗ ដោយការប្រើប្រាស់មិនសមស្រប របស់ប្រជាពលរដ្ឋមួយចំនួន ។ បច្ចុប្បន្នប្រជាជននៅក្នុងឃុំ បានកំពុងយកចិត្តទុកដាក់លើការ ការពារធនធានព្រៃឈើ ក៏ដូចជាធនធានធម្មជាតិ សត្វព្រៃ ជីវះចំរុះឡើងវិញដោយមានបង្កើតគំរោងសហគមន៍ព្រៃឈើ ។ល។

#### ១.៣.៤.២ ធនធានជលផល

ឃុំតឹនជាឃុំដែលសំបូរទៅដោយអូរតូចៗ និងអូរធំមួយចំនួនដែលភាគច្រើននៅក្នុងអូរទាំងនោះសំបូទៅដោយមច្ឆាជាតិ និងជីវះចំរុះគ្រប់ប្រភេទដូចជា ប្រភេទត្រី រស់ ត្រីអណ្តែង ក្តាម ខ្ចង ត្រីឆ្លាំង.អណ្តើក និងមួយចំនួនទៀតដែលអំណោយផលដល់ប្រជាពលរដ្ឋនៅក្នុងឃុំ ក្នុងការរកនេសាទតាមគ្រួសារនៅ តាមភូមិនីមួយៗ ។

### ១.៤ ទីផ្សារ និងខ្សែសង្វាក់ផលិតផល

#### ១.៤.១ ទីផ្សារ និងតម្លៃកសិផល ផលអនុផលព្រៃឈើ និងផលនេសាទ

**ស្ថានភាព**

- តម្លៃស្រូវ ១ គីឡូក្រាម = ៨៥០រៀល
- អង្ក ១គីឡូក្រាម = ១.៧០០ រៀល
- សាច់ជ្រូក ១គីឡូក្រាម = ១៨.០០០រៀល
- សាច់ត្រី ១គីឡូក្រាម = ១៥.០០០រៀល

- មាន់ ១ តំលៃ ២៥.០០០ រៀល
- សាច់គោ ១គីឡូក្រាម = ១៨.០០០ រៀល
- គ្រឿងផ្ទះ ១ គូប = ៥០០.០០០ រៀល
- គ្រោះ ១ គូប= ៥.០០០រៀល

### ១.៤.២ ខ្សែសង្វាក់ និងចរាចរផលិតផល

- ការទិញចូលស្រូវអង្ករ បានទិញពីអ្នកភូមិ ជិតខាង និងភូមិខ្លួនឯង តែក៏មានមួយចំនួនតូចទិញពីផ្សារ ដែលអង្កនៅលើទីផ្សារត្រូវបាននាំចូលពីទីរួមខេត្ត ស្ថិតនៅស្រុកបានលុង ។
- ការលក់ចេញនូវ ផលអនុផលព្រៃឈើ ប្រជាជនបាននាំយកទៅលក់នៅទីរួមខេត្ត ជួនកាលក៏មានឈ្មួញមកពីក្រៅមកទិញដែរ ភាគច្រើនតម្រូវការរបស់ឈ្មួញ រួមមានឈើ និងអនុផលព្រៃឈើខ្លះៗដែរ ។

### ១.៤.៣ ឱកាស និងឧបសគ្គ

នៅក្នុងឃុំគឺនជាឃុំនៅជាប់ និងផ្លូវជាតិ ហេតុនេះផលប៉ះពាល់ដែលកើតមានឡើងគឺបរិស្ថាន ដូចជាការកាប់បំផ្លាញព្រៃឈើតែងតែកើតមានឡើងជាញឹកញាប់ និងការពង្រីកដីសំរាប់ធ្វើចំការ គឺមិនអាចជៀស ផុតទេដែលភាគច្រើននៅក្នុងភូមិឡាអ៊ីន ហើយបញ្ហានេះកំពុងបន្តរីករាលដាលនៅគ្រប់ភូមិ ការកាប់រានដីព្រៃធ្វើកម្មសិទ្ធិ និងចំការពនេចរ របស់បងប្អូនជនជាតិដើមភាគតិច និងមានការលួចចូលអារឈើនៅក្នុងតំបន់ព្រៃឈើជ្រៅៗនៅពេលយប់ ព្រមទាំងមានលួចបបាញ់សត្វព្រៃគ្រប់ប្រភេទផងដែរ ។

ចំពោះធនធានជលផល គឺជាធនធានមួយដែលមានសក្តានុពលយ៉ាងខ្ពស់ ក្រៅពីការផ្តល់ជាអាហារ គឺជាប្រភពចំណូលមួយយ៉ាងសំខាន់សំរាប់ប្រជាពលរដ្ឋនៅក្នុងឃុំ ក៏ដូចជាសេដ្ឋកិច្ចជាតិ តែបច្ចុប្បន្នការប្រើប្រាស់ធនធានមានការប៉ះពាល់ គឺធ្វើអោយធនធានទទួលរងនូវគ្រោះថ្នាក់យ៉ាងខ្លាំង ដោយសារការរកផលនេសាទមានលក្ខណៈអនាធិបតេយ្យ ដូចជាការបំពុល ការប្រើម៉ងមានក្រឡាតូច ។ល។

ហើយការលំបាកដែលឃុំត្រូវប្រឈម គឺកុមារភាគច្រើនមិនបានចូលរៀន និងស្ត្រីមេម៉ាយ មនុស្សចាស់ជរាគឺជាបញ្ហាកង្វល់របស់ឃុំ ដែលបណ្តាលមកពីគ្រួសារទាំងនោះមានជីវភាពក្រីក្រ ។ អក្ខរជនមានច្រើន ហើយថ្នាក់អក្ខរកម្មដែលពុំបានបើកជាប្រចាំ បានធ្វើអោយធនធានមនុស្សនៅក្នុងឃុំពុំសូវ មានការកើនឡើង ។ ចំណែកឯវិស័យសុខាភិបាលគឺប្រជាជននៅក្នុងឃុំមានប៉ុស្តិ៍សុខភាពនៅឆ្ងាយពីភូមិមួយចំនួនធ្វើអោយប្រជាពលរដ្ឋ នៅតាមភូមិខ្លះមានការលំបាកនៅពេលពួក គាត់មានជំងឺ ពិបាកក្នុងការទៅព្យាបាលដោយសារចំងាយផ្លូវឆ្ងាយ ភាគច្រើនគឺស្ត្រី និងកុមារ ។

ហើយការលំបាកមួយទៀតឃុំតឹនមានបែងចែកបុរស និងស្ត្រី ឬរវាងកូនប្រុស និងកូនស្រីដែលជារនាំងសំរាប់ការទប់ស្កាត់ការកើនឡើងធនធានមនុស្សដោយយើងសង្កេតឃើញថាប្រជាពលរដ្ឋតាមបណ្តាភូមិទាំងបួនមានចំនួនក្មេងស្ត្រីមិនបានចូលរៀនច្រើនជាងក្មេងប្រុស ។ ចំណែកអំពើរហឹង្សាក្នុងគ្រួសារកើតមានឡើងប្រហាក់ប្រហែលគ្នាស្ទើរគ្រប់ភូមិដែលគេចាត់ទុកជារឿងធម្មតាយូរៗទៅស្ទើតែក្លាយទៅជាលក្ខណៈប្រពៃណី និងគ្មាននណាអាចជួយដោះស្រាយបានហើយបុរស់មានឱកាសក្នុងការប្រព្រឹត្តិល្មើស និងធ្វើអោយស្ត្រីមួយចំនួនធំបាត់បង់ទំនុកចិត្តលើខ្លួនឯង ។

# ជំពូក២

# ការវិភាគតម្រូវការសំរាប់អនាគត

## ២.១ តំបន់រសើប

ឃុំតីនជាឃុំដែលសំបូរទៅដោយធនធានធម្មជាតិ ដីសំបូរបែប ដូចជាសត្វព្រៃដែលមានច្រើនប្រភេទ និងពពួកព្រៃឈើយ៉ាងប្រណិត១ ព្រមទាំងដីសំបូរជីជាតិ ហើយធនធានទាំងនោះត្រូវបានបាត់បង់បន្តិចម្តង១ ដោយសំណាក់ជនខិលខូចមួយចំនួន និងមានការដេកហួតបែបអនាធិបតេយ្យ ដោយឃើញទង្វើបែបនេះ ប្រជាពលរដ្ឋទាំងអស់នៅក្នុងឃុំបានរៀបចំផែនការគ្រប់គ្រងសហគមន៍ព្រៃ ដោយយោងអនុក្រិត្យលេខ ៣៩ អនក្រ.បក ចុះថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងសហគមន៍ព្រៃឈើ ក្រោមកិច្ចព្រមព្រៀងជាមួយគណៈកម្មការ សហគមន៍ព្រៃឈើភូមិសហគមន៍ព្រៃឈើឃុំតីន រួមមាន ២កន្លែង ដែលមានទំហំក្រឡាផ្ទៃសរុប ៥៤៣៨.២៧៨ ហិកតា ដែលកន្លែងទី១ ស្មើ ២២៩៤.៤៤៧ ហិកតា និង កន្លែងទី ២ ស្មើនិង ៣១៤៣.៨៣១ហិកតា តំបន់ នេះត្រូវបានរៀបចំដើម្បីគ្រប់គ្រងនិងការពារធនធានធម្មជាតិប្រកបដោយនិរន្តរភាព ។

ប្រជាពលរដ្ឋក្នុងឃុំមានជំនឿទៅលើអារុក្ខអារក្ស អ្នកតា តាំងពីយូរលង់ណាស់មកហើយ និងក៏ជាទំនៀមទំលាប់ប្រពៃណីរបស់បងប្អូនជនជាតិដើមភាគតិចទំពួនដែរ ដែលពួកគាត់បានរក្សា និងការពារ ព្រៃអារក្សដែលជាព្រៃតំណមរបស់អ្នកភូមិនៅក្នុងឃុំ ហើយតំបន់ព្រៃអារក្សនេះសំបូរទៅដោយដើមឈើធំ១ និងព្រៃញាតមានតំលៃនិងសត្វព្រៃផងដែល ដែលត្រូវបានការពារដោយអ្នកភូមិតំបន់ព្រៃអារក្សនៅក្នុងឃុំមានចំនួន ៥ កន្លែង សរុបទំហំក្រឡាផ្ទៃមាន ១៣១ ហិកតា ដែលស្ថិតនៅតាមភូមិនីមួយ១ ។

បច្ចុប្បន្នការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងឃុំតីន បានជួបប្រទះនូវបញ្ហាមួយចំនួន សំរាប់ការអភិវឌ្ឍន៍ក្នុងមូលដ្ឋានរបស់ខ្លួន ដែលក្រុមប្រឹក្សាឃុំក៏ដូចជាប្រជាជនបានលើកយកមកបង្ហាញ រួមមានៈបញ្ហាសេដ្ឋកិច្ច និងសង្គមកិច្ចដែលពាក់ព័ន្ធនឹងការប្រើប្រាស់ដីធ្លីនិងធនធានធម្មជាតិ។ ការគំរាមកំហែងចម្បងចំពោះស្ថានភាពសត្វព្រៃនៅ ក្នុងតំបន់ការពារ គឺការកាប់ឈើខុសច្បាប់ និងការកាប់រានដី សំរាប់គោលបំណងជាកម្មសិទ្ធិ ដែលបង្កអោយមាន ការកាប់បំផ្លាញនិងបាត់បង់ទីជំរកក៏ដូចជាការរំខានទៀតផង។ ការបរបាញ់ខុសច្បាប់ដើម្បីផ្គត់ផ្គង់ម្ហូបអាហារសំរាប់ ប្រើប្រាស់ក្នុងមូលដ្ឋាន និងម្តងម្កាលលក់ទៅទីផ្សារនានា និងបានបន្ថែមបញ្ហាកាន់តែធ្ងន់ធ្ងរថែមទៀត។ ម៉្យាងទៀត ឃុំតីនបើយោងលើ ផែនទីគំរបព្រៃឈើឆ្នាំ ២០០២បានអោយដឹងថាផ្ទៃដីរបស់ឃុំមានចំនួន ២៨៧៣៥,១៤៥ ហិកតា ចែកចេញជា :

- ព្រៃស្រោង . ១២២៩៧,៥២ ហិកតា
- ព្រៃពាក់កណ្តាលស្រោង ២៦០៨,១៩៤ ហិកតា
- ព្រៃរបោះ . ៧៦៧១,៦០៩ ហិកតា
- ប្រភេទព្រៃផ្សេង . ១៦៤,៦១៧ ហិកតា
- ដីមិនមែនព្រៃ . ៦០៣៣,២០៥ ហិកតា

- នៅចំនុចភ្នំយក្សលោម ស្រែឯង ស្ថិតនៅក្នុងភូមិកាំបាក់ឃុំតឹន និងមានការកាប់ព្រៃយកដីព្រៃធ្វើជាកម្មសិទ្ធិផ្ទាល់ខ្លួន រឺមានការទិញលក់ពីបងប្អូនជនជាតិជាដើម ។

## ២.២ ការប្រឈម/ ឧបសគ្គ

សហគមន៍ព្រៃឈើឃុំតឹនទាំង ២ តំបន់នេះមិនត្រឹមតែសំបូរសក្តានុពលសព្វបែបយ៉ាងប៉ុណ្ណោះទេ សូម្បីតែដី នៅក្នុង តំបន់នេះក៏មានលក្ខណៈអំណោយផលផងដែរ ដែលជាប្រភេទដីក្រហមមានលក្ខណៈអំណោយផលដីល្អសំរាប់ ដាំដំណាំកសិកម្មផ្សេងៗ ដូចនេះហើយ នឹង មានការប្រឈមក្នុងការកាប់រាន ឈូសឆាយដីព្រៃយកមកធ្វើជាកម្មសិទ្ធិ ការលួចកាប់ឈើដោយខុសច្បាប់ របស់ជនខិលខូចមួយចំនួនជាដើម...។ ល។ ទាំងនេះជាឧបសគ្គរបស់អ្នកភូមិនៅ ក្នុងឃុំ ដែលបង្កដល់ការប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគាត់ដែលពឹងផ្អែកក្នុងការរុករកផល-អនុផលព្រៃឈើ និង បេះបន្លែផ្លែឈើព្រៃយកមកធ្វើជាម្ហូបអាហារប្រចាំថ្ងៃរបស់អ្នកភូមិនៅក្នុងឃុំ ។ ម្យ៉ាងទៀតសោធជនចំណាកស្រុក បានមករស់នៅក្នុងឃុំនេះយ៉ាងច្រើនបានធ្វើអោយសក្តានុពលធនធានធម្មជាតិបានបាត់បង់ជាបណ្តើរៗ ។ ដែលប្រជា ពលរដ្ឋនៅក្នុងឃុំតឹន ដែលមកពីមុខរស់នៅចិញ្ចឹមជីវិតដោយពឹងផ្អែកលើផលអនុផលព្រៃឈើ និងសត្វព្រៃឥឡូវបាន ជួបប្រទះការលំបាកខ្លះៗ។ ការស្វែងរកម្ហូបចំណីអាហារ ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារតាមលក្ខណៈប្រពៃណីរបស់ បងប្អូនជនជាតិដើមភាគតិចបានធ្លាក់ចុះមួយកំរិតគួរអោយព្រួយបារម្ភយ៉ាងខ្លាំង ។

ការកាប់រុករានទន្រ្ទាន ព្រៃអារក្ស និងដីព្រៃផ្សេងៗកាន់កាប់យក ធ្វើជាដីកម្មសិទ្ធិដុតព្រៃចាប់សត្វ អណ្តើក, កន្ធាយ ,ពស់ , ដុតយកឃ្មុំធ្វើអោយឆេះដល់ព្រៃ បច្ចុប្បន្នកំពង់មានសកម្មភាពគួរអោយកត់សំគាល់ព្រោះថានៅដំណាក់ កាលប៉ុន្មានឆ្នាំចុងក្រោយនេះ មានកើតបញ្ហាជាច្រើន ដែលពាក់ពន្ធ័ ទៅនិងការកាប់បំផ្លាញ វាតដីព្រៃអារក្ស មួយ ចំនួនយកធ្វើជាកម្មសិទ្ធិប៉ុន្តែផ្អែកទៅតាមការអនុវត្តន៏ច្បាប់របស់ស្ថាប័នជំនាញ និង អាជ្ញាធរដែនដីភូមិឃុំបានធ្វើអោយ សកម្មភាពនេះមានការថយចុះមកវិញជាបណ្តើរៗ ។

## ២.៣ តម្រូវការនៃការអភិវឌ្ឍន៍ និងគោលដៅយុទ្ធសាស្ត្រឃុំតឹន

ដើម្បីទ្រទ្រង់បាននូវយុទ្ធសាស្រ្តរួម សំដៅធ្វើអោយការអនុវត្តន៏ សំរេចបានដល់គោលដៅនៃចក្ខុវិស័យដែល បានកសាងឡើងខាងលើចាំបាច់ត្រូវកសាងយុទ្ធសាស្រ្តតាមវិស័យសំខាន់ៗ ដែលពាក់ពន្ធ័មួយចំនួនដល់ ការអភិវឌ្ឍន៏ ឃុំតឹន ។ យុទ្ធសាស្រ្តតាមវិស័យសំខាន់ៗ ទាំងនោះ ក្រុមប្រឹក្សាឃុំ និងគផថ និងប្រជាពលរដ្ឋទាំងអស់ នៅក្នុងឃុំ បានជ្រើសរើសយក គោលដៅអភិវឌ្ឍន៍ចំនួន ០៥ គឺៈ

**- គោលដៅអភិវឌ្ឍន៍ទី ១** : នៅឆ្នាំ២០០៩- ២០២២ ប្រព័ន្ធគមនាគមន៍នៅឃុំតឹនត្រូវបានពង្រីកដល់គ្រប់ បណ្តាភូមិទាំងអស់ និងប្រជាជនក្មេងចាស់ប្រុសស្រ្តីមានផ្លូវល្អងាយស្រួលធ្វើដំណើរ និងសុវត្ថភាព ចំណេញពេលវេលា និងមានការចិញ្ចឹមត្រីបន្ថែមសំរាប់ធ្វើជាអាហារ និងបង្កើនប្រាក់ចំណូល ជីវភាពរស់នៅបានល្អប្រសើរដល់គ្រប់គ្រួសារ នៅក្នុងឃុំ ។

**- គោលដៅអភិវឌ្ឍន៍ទី ២ :** នៅឆ្នាំ២០០៩- ២០២២ ប្រជាពលរដ្ឋនៅក្នុងឃុំតឹន និងទទួលបាននូវប្រព័ន្ធប្រឡាយ និងទំនប់គ្រប់គ្រាន់សំរាប់បំរើអោយការបង្កបង្កើនផលកសិកម្ម ដើម្បីធានាបាននូវសុវត្ថិភាពស្បៀង សំដៅលើកកំពស់ក៏រិតជីវភាពរស់នៅអោយកាន់តែប្រសើរ ។

**- គោលដៅអភិវឌ្ឍន៍ទី ៣ :** នៅឆ្នាំ២០០៩- ២០២២ ប្រជាពលរដ្ឋទាំង ២ភេទ មានសេវាសុខភាពគ្រប់គ្រាន់មានសុខភាពល្អប្រសើរមានចំណេះដឹងផ្នែកអក្សរសាស្ត្រកើនឡើង និងអោយតំលៃដល់ការសិក្សា ហើយមានទឹកស្អាតប្រើប្រាស់គ្រប់គ្រួសារ ដោយឳពុកម្តាយផ្តល់ឳកាសអោយបានចូលរៀនសូត្របានគ្រប់ៗគ្នា និងមានចំណេះដឹងល្អប្រសើរ ។

**- គោលដៅអភិវឌ្ឍន៍ទី ៤ :** នៅឆ្នាំ២០០៩- ២០២២ ស្ត្រីមានភាពទទួលខុសត្រូវដូចជាបុរសដែរ ដូចជាការចូលរួមការងារនៅមូលដ្ឋាន និងមានជំនាញក្នុងការប្រកបមុខរបរចិញ្ចឹមជីវិតដោយមិនពឹងផ្អែកលើការដកហូតអនុផលព្រៃឈើទាំងស្រុង ។ និងបានផ្តល់ឳកាសអោយស្ត្រីបានចូលរួម និងសំរេចចិត្តយ៉ាងសកម្មក្នុងការលើកស្ទួយ និងការអភិវឌ្ឍន៍ ។

**- គោលដៅអភិវឌ្ឍន៍ទី ៥ :** នៅឆ្នាំ២០០៩- ២០២២ សហគមន៍មានការចូលរួម និងយល់ពីច្បាប់គ្រប់គ្រងព្រៃឈើ សត្វព្រៃ ត្រី បានចូលរួមថែរក្សា និងប្រើប្រាស់ធនធានធម្មជាតិមានប្រសិទ្ធភាពខ្ពស់ មាននិរន្តរភាពសំរាប់កូនចៅទៅថ្ងៃអនាគតបានល្អប្រសើរដោយមានការចូលរួមសហការគ្រប់ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងមូលដ្ឋានទាំង ២ភេទ ។

## ២.៤ តម្រូវការដីសំរាប់អនាគត

### ២.៤.១ ប្រជាសាស្ត្រ

#### ២.៤.១.១ អត្រាកំណើន

ស្ថានភាពអត្រាកំណើននៃ ប្រជាពលរដ្ឋនៅក្នុងឃុំតឹន បើពិនិត្យនៅក្នុងឆ្នាំ ២០០៥ មានចំនួនគ្រួសារ ៤៩៣ គ្រួសារ ដែលស្មើនឹងប្រជាពលរដ្ឋចំនួន ២២៣៣នាក់ បើយើងធ្វើការប្រៀបធៀបនៅឆ្នាំ ២០០៦ មានការកើនឡើងតែ ៤៦គ្រួសារស្មើ ៨១នាក់ ដូចនេះ ចំពោះចំនួនមនុស្សមានចំនួនច្រើនជាងនៃចំនួនគ្រួសារ ។ តែចំនួនគ្រួសារក្នុងឆ្នាំ ២០០៦នេះ មានចំនួន ៥៤២គ្រួសារ ស្មើនិង ២១៥២នាក់ ។ តែបើយើង ពិនិត្យទៅលើឆ្នាំ ២០០៦ ធៀបទៅនឹងឆ្នាំ ២០០៧ ឃើញថាមានការថយចុះ ១០គ្រួសារទៅវិញដែលចំនួនប្រជាជនឃើញមានការកើនឡើងទៅវិញ រហូតដល់ ១០៤នាក់ ។

តែចំណែកឯ ឆ្នាំ ២០០៨ មានការកើនឡើងចំនួន២៣គ្រួសារស្មើរ នឹង៥៥៥ គ្រួសារ ច្រើនជាងឆ្នាំ ២០០៦-២០០៧ បើធៀបជាមួយឆ្នាំ ២០០៧-២០០៨ មានការកើនឡើងតែ ៦២គ្រួសារ ស្មើនិង៣១០ នាក់តែប៉ុណ្ណោះ តាមការសាកសួរព័ត៌មានពីក្រុមប្រឹក្សាឃុំ និង អ្នកចូលរួមនៅក្នុងឃុំ ដែលបណ្តាលមកពីការ ឡើងចុះនៃចំនួនប្រជាពលរដ្ឋនៅក្នុងឃុំតឹន គឺបណ្តាលមកពី ការហូរចូល និងធ្វើចំណាកស្រុកចេញទៅរកមុខរបរនៅក្រៅមូលដ្ឋាន តែចំនួន

គ្រួសារ និងចំនួនប្រជាពលរដ្ឋតាមបណ្តាឆ្នាំមានការ កើនឡើងជាលំដាប់ ហើយចំនួនកុមារ ក៏មានការ កើនឡើងដែរ កត្តានេះហើយដែលបណ្តាលអោយមានការកង្វះខាតនៅទីកន្លែងសិក្សា និងមានការខ្វះខាតដី ក្នុងការពង្រីកដី នៅក្នុងវិស័យកសិកម្មដែរ ដូច្នេះយើងក៏ត្រូវកំណត់នូវសក្តានុពលមួយចំនួនដូចជាលទ្ធភាព នៃកាពង្រីកអាគារសិក្សាការបង្កើនមុខរបរការធ្វើស្រែបង្កើនរដូវ ការបង្កើននូវទិន្នផលកសិកម្ម ការរៀបចំប្រព័ន្ធស្រោចស្រព ការអភិរក្សនូវធនធានធម្មជាតិ និងការកំណត់នៃការប្រើប្រាស់ធនធានអោយបានសមស្របទើបអាចធានាបាននូវអត្រាកំណើន ។

តារាង ការគណនាអត្រាកំណើនមធ្យម

| **ចំនួនគ្រួសារ/ប្រជាជន** | **២០០៥** | **២០០៦** | **២០០៧** | **២០០៨** | **កំណើនមធ្យម** | **កំណើន/ឆ្នាំ** |
|---|---|---|---|---|---|---|
| ចំនួនគ្រួសារសរុប | ៤៩៣ | ៥៤២ | ៥៣២ | ៥៥៥ | - | - |
| អត្រាកំណើនគ្រួសារ | % | ១០% | -២% | ៤% | ៤% | ២២ គ្រួសារ |
| ចំនួនប្រជាជនសរុប | ២២៣៣ | ២១៥២ | ២២៥៦ | ២៥៤៣ | - | - |
| អត្រាកំណើនប្រជាជន | % | -៤% | ៥% | ១៣% | ៥% | ១២៧នាក់ |

ប្រភព: ឯកសារពត៌មាន ស្តីពីស្ថានភាពឃុំតឹន ឆ្នាំ ២០០៩

នៅក្នុងអត្រានៃការប្រែប្រួលចំនួនគ្រួសាររបស់ប្រជាពលរដ្ឋ នៅក្នុងអំឡុងឆ្នាំ ២០០៥-២០០៦ ឃើញថាមានការកើនឡើង តែ ១០% ប៉ុន្តែឆ្នាំ ២០០៦-២០០៧ ឃើញថាមានការថយចុះ -២ % ប៉ុន្តែ ២០០៧-២០០៨ អត្រាប្រជាជនមានការកើនឡើងតែ ៤%ប៉ុណ្ណោះ នេះបញ្ជាក់អោយឃើញថាប្រជាជនឆ្នាំ ២០០៦-២០០៧ មានការ ហូរចូលច្រើន ។ ក្នុងនោះដែរបើតាមការគណនាអត្រាកំណើនចំនួនគ្រួសារ ពីឆ្នាំ ២០០៥-២០០៨ ឃើញថាអត្រាកំណើនមាន ៤% ស្មើនិង ២២គ្រួសារក្នុងមួយឆ្នាំ ។ ផ្អែកតាមទិន្នន័យព័ត៌មាននៃផែនការអភិវឌ្ឍន៍ឃុំ និងតាមរយៈការគណនារកអត្រាកំណើនរបស់ប្រជាពលរដ្ឋឃើញថា ចំនួនប្រជាជនពីមួយឆ្នាំទៅមួយឆ្នាំមានការប្រែប្រួល កើនឡើង និងឆ្នាំខ្លះមានការថយចុះ កត្តានេះគឺ អាស្រ័យដោយមូលហេតុដូចករណីខាងលើប៉ុន្តែទោះជាយ៉ាងក៏ដោយ ក៏អត្រាកំណើនជាមធ្យម ៥% ដែលក្នុង នោះមានការកើនឡើងក្នុង ១ ឆ្នាំ ១២៧ នាក់ ។

### ២.៤.១.២ ការធ្វើចំណោលប្រជាសាស្ត្រ

ការធ្វើចំណោលប្រជាសាស្ត្រគឺសំរាប់ការទស្សន៍ទាយកំណើនប្រជាជនជាចំណុចដ៏សំខាន់ណាស់ សំរាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ឃុំតឹន ។ ការដឹងជាមុននូវចំនួនដង់ស៊ីតេប្រជាជន គឺជាមធ្យោបាយ ដ៏សំខាន់មួយដើម្បីធ្វើការកំណត់ជាមុននូវគោលដៅអភិវឌ្ឍន៍សំខាន់ៗរបស់ឃុំនាពេលអនាគត ។ដូចនេះការលើកយកចំនួន ប្រជាជនក្នុងឆ្នាំ២០០៨ មកធ្វើការប្រៀបធៀប និង ទស្សន៍ទាយ ពីកំណើនប្រជាជនទៅថ្ងៃអនាគត ( ឆ្នាំ២០០៨ និង ២០២២) គឺជាយុទ្ធសាស្ត្រមួយសំរាប់ប្រើប្រាស់ និង អនុវត្តផែនការអភិវឌ្ឍន៍ឃុំ ក្នុងរយៈពេល ១៥ ឆ្នាំ ។

តារាងការធ្វើចំណោលប្រជាសាស្ត្រ

| **ស្ថិតិតាមក្រុមអាយុ** | **ឆ្នាំ ២០១២** | | **ឆ្នាំ ២០១៧** | | **ឆ្នាំ ២០២២** | | **ផ្សេងៗ** |
|---|---|---|---|---|---|---|---|
| | **សរុប** | **ស្រី** | **សរុប** | **ស្រី** | **សរុប** | **ស្រី** | |
| អាយុក្រោម០៥ឆ្នាំ | ៣៦៧ | ១៩២ | ៤៤៦ | ២៣៣ | ៥២៥ | ២៧៥ | |
| អាយុ ០៥ឆ្នាំ | ១២៨ | ៧៤ | ១៥៦ | ៩០ | ១៨៣ | ១០៥ | |
| អាយុពី ៦-១១ឆ្នាំ | ៥៣៤ | ២៨៣ | ៦៤៩ | ៣៤៣ | ៧៦៤ | ៤០៤ | |
| អាយុពី ១២-១៤ឆ្នាំ | ៣១០ | ១៣៨ | ៣៧៧ | ១៦៧ | ៤៤៤ | ១៩៧ | |
| អាយុពី ១៥-១៧ឆ្នាំ | ១៨១ | ៨១ | ២២០ | ៩៨ | ២៥៩ | ១១៦ | |
| អាយុពី ១៨-២៤ឆ្នាំ | ៤២០ | ២៣៣ | ៥១១ | ២៨៣ | ៦០១ | ៣៣៣ | |
| អាយុពី ២៥-៦០ឆ្នាំ | ៨៤៦ | ៤០១ | ១០២៨ | ៤៨៧ | ១២០៩ | ៥៧៤ | |
| អាយុពី៦១ឆ្នាំឡើងទៅ | ១៦៤ | ៩៨ | ២០០ | ១១៩ | ២៣៥ | ១៤០ | |
| **ចំនួនប្រជាជនសរុប** | **២៩៥១** | **១៤៩៩** | **៣៥៨៦** | **១៨២២** | **៤២២១** | **២១៤៤** | |
| **ចំនួនគ្រួសារសរុប** | **៦៧០** | | **៨១៥** | | **៩៥៩** | | |

អត្រាកំណើនប្រជាពលរដ្ឋនៅក្នុងឃុំតឹន បើពិនិត្យទៅលើកំណើនក្នុងរយៈពេល ៥ ឆ្នាំម្តងសំរាប់រយៈពេល ១៥ ឆ្នាំខាងមុខ ឃើញថាអត្រាកំណើនប្រជាពលរដ្ឋជាមធ្យម ៥%ក្នុងនោះស្មើរនិង ១២៧នាក់ ក្នុងមួយឆ្នាំហើយនិង ៤% ស្មើនិង ២២គ្រួសារក្នុង ១ឆ្នាំនោះបើពិនិត្យទៅលើបរិមាណផ្ទៃដី ដែលអាចប្រើប្រាស់បាននៅមានក៏វិត ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក៏យើងត្រូវចាប់អារម្មណ៏ដល់ការអភិវឌ្ឍន៏ដែរ ព្រោះអត្រាកំណើនរបស់ប្រជាពលរដ្ឋនៅក្នុងឃុំតឹន គឺវាពាក់ព័ន្ធទៅលើការអភិវឌ្ឍន៏ធនធានដែលមានក្នុងឃុំ ពិសេសបរិមាណដី ដែលអាចបង្កើននូវផលដំណាំជានាស្បៀងក្នុងតំបន់ ។

### ២.៤.២ តម្រូវការដីសំរាប់លំនៅដ្ឋាន

ចំពោះដីលំនៅដ្ឋានរបស់បងប្អូនជនជាតិដើមភាគតិច គឺពួកគាត់មានដីពីកន្លែង មួយកន្លែងគឺពួកគាត់រស់នៅជា ក្រុមនៅក្នុងភូមិសំរាប់សាងសង់លំនៅដ្ឋាន និងមួយកន្លែងទៀតគាត់មានដីលំនៅដ្ឋាន ជាមួយនឹងដីស្រែ នឹងចំការ ដែលមានដាំដំណាំសួនគ្រួ នៅជុំវិញចំការ ឬស្រែរបស់ពួកគាត់ (លំអិតសូមមើលឧបសម្ព័ន្ធ១) សំរាប់ឆ្នាំគោល ២០០៨ ដីលំនៅដ្ឋានរបស់ឃុំតឹនសរុបមានទំហំ ២៥ ហិកតា សំរាប់ប្រជាជន ប្រមាណជា ២៥៤៣ នាក់ ស្មើរនឹង ៥៥៥ គ្រួសារ ដូច្នេះទំហំដីសំរាប់មួយគ្រួសារគិតជា មធ្យមគឺមាន ០,០២៣ ហិកតា គឺ តិចជាងដី សំរាប់សង់លំនៅដ្ឋានដែលមាន ១២០០-៣៦០០ម២ (មាត្រាទី១៥ ជំពូក៥នៃអនុក្រិត្យ ស្តីពីសម្បទាន ដីសង្គមកិច្ច) ដោយសារឃុំតឹនដីពុំមានវិសាលភាពគ្រប់គ្រាន់ ដូច្នេះក្នុងការ ប៉ាន់ប្រមាណដី សំរាប់សង់លំនៅដ្ឋានត្រូវកំណត់យក ១២០០ម$^{២}$ ។ ដើម្បី

ធានាអោយប្រជាជនដែលខ្វះដី មានដីមិន គ្រាន់គ្រាន់ និងប្រជាជនដែលកើនឡើងនៅឆ្នាំ ២០២២ មានដីលំនៅដ្ឋានសមរម្យ យើងត្រូវពិចារណាដូចខាងក្រោមៈ

តម្រូវការសំរាប់ឆ្នាំ ២០២២ គឺមាន :

| | | |
|---|---|---|
| - ចំនួនគ្រួសារគ្មានដីលំនៅដ្ឋាន | ៥ គ្រួ.x 0,១២ | = 0.៦ហត |
| - កំណើនគ្រួសារ ២០២២ | ៤០៤គ្រួx 0,១២ | = ៤៨,៤៨ ហត. |
| | សរុប | = **៤៩.០៨ ហត.** |

## ២.៤.៣ តម្រូវការដីកសិកម្ម

តម្រូវការដីកសិកម្មគឺរួមមានដីសំរាប់ស្រែវស្សា និងចំការដំណាំផ្លាស់វេន (លំអិតសូមមើលឧបសម្ព័ន្ធ១) សំរាប់ឆ្នាំគោល ២០០៨ មានទំហំ ៤០២ ហិកតា សំរាប់ប្រជាជនសរុប **២៥៤៣ នាក់ ស្មើនិង ៥៥៥** គ្រួសារ ដូច្នេះទំហំដីជាមធ្យមសំរាប់មួយគ្រួសារមាន ១.៨២ ហិកតា។ ចំពោះប្រជាជនឃុំតឺនប្រជាជនពឹងពាក់ទាំងស្រុងទៅលើធនធានធម្មជាតិ និងអនុផលព្រៃឈើទាំងស្រុង ពិសេសគឺដើមជ័រទឹក និងការបេះបន្លែផ្លែឈើពីក្នុងព្រៃសំរាប់ផ្គត់ផ្គង់ជីវភាពរបស់ពួកគាត់ ។ ដោយឡែកការធ្វើកសិកម្មពនេចរតាមប្រពៃណីរបស់បងប្អូនជនជាតិដើមភាគតិចពួកគាត់មិនអាចអត់ឬអាក់ខានបានឡើយដូចនេះតម្រូវការសំរាប់ដីកសិកម្មរបស់ពួកគាត់គឺមានប្រមាណ ៥៥៥ គ្រួសារ ដែលអាចមានដីជាមធ្យមទំហំ ២ហិកតា[២] ដែលជាទំហំដីសមស្របសំរាប់ប្រជាជនមួយគ្រួសារ។

តម្រូវការសំរាប់ឆ្នាំ ២០២២ គឺមាន :

| | | |
|---|---|---|
| - ចំនួនគ្រួសារដែលបច្ចុប្បន្នមិនទាន់មានដីកសិកម្ម | ៣៨៣ គ្រួ. x ២ | = ៧៦៦ ហត. |
| - កំណើនគ្រួសារ ២០២២ | ៤០៤ គ្រួ. x ២ | = ៨០៨ ហត. |
| | សរុប | **១៥៧៤ ហត.** |

ខាងលើនេះជាការវិភាគទៅតាមទំហំដី តែបើយើងវិភាគទៅតាម ចំនួនប្រជាជន ផ្ទៃដីដំណាំស្រូវគឺយើងឃើញថា ទិន្នផលស្រូវមាន ១.៥តោនក្នុងមួយហិកតា ហើយប្រជាជនម្នាក់ៗត្រូវការតែ ២៣០ គក្រ. ក្នុងមួយឆ្នាំតាមស្ថិតិឃុំ ផ្ទៃដីស្រែមានប្រមាណ ៤០២ ហិកតា ទទួលបានផលស្រូវ ៦០៣តោន តម្រូវការជាក់ស្តែង ៥៨៤.៨៩ តោន ដូចនេះឃើញថាប្រជាពលរដ្ឋមិនមានការខ្វះខាតតម្រូវក្នុងការផ្គត់ផ្គង់ជីវភាពទេ ចំណែកឯកំណើនប្រជាជនរហូតដល់ឆ្នាំ ២០២២ គឺមាន ១៦៧៨ នាក់ (៦៥%) ត្រូវការស្រូវតែ ៣៨៥.៩៤ តោន តែប៉ុណ្ណោះក្នុង១ឆ្នាំ។ ការពង្រីកដីកសិកម្មជាអាទិភាពអាចគួរ តែពង្រីកប្រមាណតែ ១៩៦៧.៥ហិកតា ទៅសំរាប់ទល់នឹងឆ្នាំ ២០២២។

## ២.៤.៤ តម្រូវការដីសំរាប់កិច្ចការពារបរិស្ថាន និងធនធានធម្មជាតិ

ឃុំតឺនជាឃុំ សំបូរដោយព្រៃឈើធនធានធម្មជាតិ មានបឹង អូរ និងដីមានជីរជាតិដូចនេះដីដែលបានកំណត់នៅក្នុងតំបន់រសើប គឺមានដីដែលស្នើសុំបង្កើតសហគមន៍ព្រៃឈើ តំបន់ព្រៃអារក្ស តំបន់គ្រប់គ្រងដោយសហគមន៍

តំបន់ការពារដើមដំរទឹក តំបន់រក្សាព្រៃគ្រាប់ពូជ ដែលជាព្រៃស្រោងសើមលាយ និងព្រៃរបោះសំរាប់តំបន់អភិរក្សសត្វព្រៃ និងតំបន់ព្រៃដុះ ឡើងវិញដែលគ្រប់គ្រងដោយសហគមន៍ ចំណែកដីផ្សេងៗទៀតដែលមិន បានកំណត់ទៅក្នុងប្រភេទ នៃការប្រើប្រាស់ ដីគឺត្រូវតែទុកអោយនៅជាដីព្រៃ និងវាលស្មៅ ដីដែល ដែលជាដីរបស់រដ្ឋ ដើម្បីធានានូវតម្រូវការដី សំរាប់កិច្ចការពារ បរិស្ថាន និងធនធានធម្មជាតិ ដែលមានការចាប់អារម្មណ៍ទៅលើការការពារ និងទប់ស្កាត់អោយបាន ជាដាច់ខាតនូវការ លួចកាប់រំលោភយកដី ពីសំណាក់ជនខិលខូច និងចាត់វិធានការអោយបានខ្លាំងខ្លាបំផុតសំរាប់ ជនទាំងនោះ ។

### ២.៤.៥ តម្រូវការដីសំរាប់ ហេដ្ឋារចនាសម្ព័ន្ធសង្គម

ជារួមហេដ្ឋារចនាសម្ព័ន្ធសង្គមក្នុងរូបភាពតូចតាច គឺត្រូវបានបញ្ចូលទៅក្នុងដីលំនៅដ្ឋាន ឬដីទីប្រជុំជនដោយមិនបានញែកចេញដោយឡែកនោះទេ (ក្នុងនោះដីកប់ខ្មោច សាលារៀន ប៉ុស្តិ៍រដ្ឋបាលឃុំ ប៉ុស្តិ៍នគបាលឃុំ ប្រព័ន្ធធារាសាស្រ្ត ក៏គិតគូរក្នុងនេះដែរ) តែក្នុងនោះក៏មានការគិតគូរជារួម លើកលែងតែហេដ្ឋារចនាសម្ព័ន្ធ សង្គមដែលមានទ្រង់ទ្រាយធំ ទើបមានការ គិតគូរដោយឡែក។ និយាយរួមដីសំរាប់តម្រូវការហេដ្ឋារចនាសម្ព័ន្ធ ត្រូវបានកំណត់ជារួមជាមួយនឹង ដីត្រៀមបំរុង សំរាប់ពង្រីកទីប្រជុំជន។

តាមការប៉ាន់ប្រមាណជាសរុបដីសំរាប់ហេដ្ឋារចនាសម្ព័ន្ធសង្គមគឺមានតម្រូវការបន្ថែម ព្រោះចំពោះផ្លូវ ទំនប់ប្រឡាយ លូរតូចៗគឺមិនមានការគិតជាផ្ទៃដីទេ តែមានប្រវែងហើយនឹងបង្ហាញក្នុងផែនទីដោយឡែក (សូមមើលឧបសម្ព័ន្ធ ....ផែនទីហេដ្ឋារចនាសម្ព័ន្ធ...)

<u>តារាងផែនការអភិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេវាកម្មទូទៅ</u>

| ហេដ្ឋារចនាសម្ព័ន្ធ | ចំនួនក្នុងឆ្នាំនេះ | ចំនួន១៥ឆ្នាំក្រោយ | បំរែបំរួល |
|---|---|---|---|
| សាលាមត្តេយ្យ | 0 | ០១សាលា ៣បន្ទប់ | ០១សាលា ៣បន្ទប់ |
| សាលាបឋមសិក្សា | ០៧សាលា ១៥បន្ទប់ | ០៨សាលា ១៩បន្ទប់ | ០១ សាលា ៤បន្ទប់ |
| សាលាអនុវិទ្យាល័យ | 0 | ០២សាលា ៧បន្ទប់ | ០២ សាលា៧បន្ទប់ |
| សាលាវិទ្យាល័យ | 0 | ០១សាលា ៤បន្ទប់ | ០១ សាលា ៤ បន្ទប់ |
| ប៉ុស្តិ៍សុខភាព | ០១ | ០៣ | ០២ |
| ស្រះទឹកចិញ្ចឹមត្រី | 0 | ៥0 | ៥0 |
| ជួសជុលទំនប់ទឹក | ២ កន្លែង | ៦ កន្លែង | ៤ |
| ប៉ុស្តិ៍រដ្ឋបាលឃុំ | 0 | ២ កន្លែង | ២ កន្លែង |
| អណ្តូងទឹកស្អាត | ២៣ | ៣៤ | ១១ |

### ២.៤.៥.១ តម្រូវការសាលារៀន

ដីសំរាប់សាងសង់សាលារៀនមានការកំណត់បានច្បាស់លាស់គឺមាន មួយកន្លែងសំរាប់គ្រោងសាងសង់សាលារៀនដែលបានកំណត់ដោយអ្នកភូមិនៅក្នុងឃុំ ហើយដីសាលានេះ វាស្ថិតនៅក្នុងដីលំនៅដ្ឋានភូមិ ដោយភូមិ និងឃុំត្រៀមសំរាប់សាងសង់នាពេលខាងមុខ នៅពេលដែលមានចំនួយឧបត្ថម្ភពីសំណាក់រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ។

ចំពោះការអភិវឌ្ឍន៍ និងប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធ សង្គមនៅក្នុងមូលដ្ឋានឃុំ បច្ចុប្បន្ននៅមានកំរិត ហើយឃុំពុំមានសាលាអនុវិទ្យាល័យ និងវិទ្យាល័យទេប៉ុន្តែទោះបីយ៉ាងនេះក៏ដោយក៏ការអភិវឌ្ឍលើវិស័យអប់រំនៅក្នុងឃុំតឺននៅពុំទាន់បំពេញបាននូវតម្រូវការសិក្សារបស់សិស្សានុសិស្សនៅឡើយ ជាអាទិ៍ដូចជា នៅគម្រោង ផែនការ ១៥ ឆ្នាំខាងមុខតម្រូវការលើ អាគារសិក្សា ផ្អែកតាមបរិមាណ សិស្សានុសិស្ស គឺ សាលាមតេយ្យសាលា បឋមសិក្សា ក៏ដូចជាអនុវិទ្យាល័យ បើពិនិត្យទៅតាមការគណនាកំណើនប្រជាពលរដ្ឋ ឃើញថាតម្រូវការទាំងនេះអាចផ្តល់ឱកាសអោយឃុំអាចអភិវឌ្ឍន៍ទៅតាមលទ្ធភាពជាបណ្តើរៗ ដែលក្នុងនោះសាលាមត្តេយ្យ ១អាគារ ២បន្ទប់ នៅភូមិឡាអ៊ិន ហើយសាលាបឋមសិក្សាឃុំ មានគម្រោងពង្រីក ០១អាគារ ៤បន្ទប់ និងអនុវិទ្យាល័យ ២អាគារ ៧បន្ទប់ និងវិទ្យាល័យឃុំត្រៀមពង្រីក ១ អាគារ ៤ បន្ទប់ នៅពេលខាងមុខ។

<u>តារាងកំណើនកុមារ និងតម្រូវការថ្នាក់រៀន និងសាលានៅឆ្នាំ ២០១២-២០២២</u>

| ប្រភេទសាលា | នៅឆ្នាំ ២០១២ | | | នៅឆ្នាំ ២០១៧ | | | នៅឆ្នាំ ២០២២ | | |
|---|---|---|---|---|---|---|---|---|---|
| | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ | កុមារ | សាលា | បន្ទប់ |
| ថ្នាក់មត្តេយសិក្សា | ១២៨ | 0 | ១ | ១៥៦ | 0 | 0 | ១៨៣ | 0 | ២ |
| ថ្នាក់បឋមសិក្សា | ៥៣៤ | - | - | ៦៤៩ | - | - | ៧៦៤ | ១ | ៤ |
| ថ្នាក់អនុវិទ្យាល័យ | ៣១០ | ១ | ៣ | ៣៧៧ | 0 | ១ | ៤៤៤ | ១ | ៤ |
| ថ្នាក់វិទ្យាល័យ | ១៨១ | ១ | ២ | ២២០ | 0 | 0 | ២៥៩ | ១ | ២ |

### ២.៣.៥.២ សេវាកម្មសុខភាព និងការផ្គត់ផ្គង់ទឹកស្អាត

#### ក. សេវាកម្មសុខភាព

បច្ចុប្បន្ននេះឃុំតឺន មានប៉ុស្តិ៍សុខភាព១អាគារភូមិតឺន ហើយចំពោះមុខបច្ចុប្បន្ន ប៉ុស្តិ៍សុខភាព ឃុំនេះ មិនទាន់បានបំពេញនូវតម្រូវការ នៃការទ្រទ្រង់ សុខមាលភាពរបស់ប្រជាពលរដ្ឋនៅឡើយទេ ចំណែកវេជ្ជបណ្ឌិត និងគ្រូពេទ្យព្យាបាលជំងឺទូទៅក៏ពុំទាន់មានគ្រប់គ្រាន់នៅឡើយដែរ ដែលជាហេតុនាំអោយ មានការខ្វះខាតចំពោះសេវាសុខាភិបាលពីព្រោះប្រសិន បើមានអ្នកជំងឺឈឺធ្ងន់ ពួកគាត់ មិនអាចបញ្ជូនអ្នកជំងឺទៅមណ្ឌលសុខភាពទេ ព្រោះថាបើគិតចំងាយពីមណ្ឌលសុខភាពស្រុក គឺចំងាយផ្លូវប្រហាក់ប្រហែល និងមន្ទីរពេទ្យបង្អែកនៅទីរួមខេត្ត ដូចនេះពួកគាត់ត្រូវបញ្ជូនអ្នកជំងឺទាំងនោះទៅមន្ទីរពេទ្យបង្អែក នៅទីរួមខេត្តរតនគីរី ដែលមានចំងាយឆ្ងាយរហូតដល់ ២៩ គ.ម ឯណោះ ។

ដោយស្ថានភាព ភូមិសាស្ត្រនៃឃុំដែលមានប្រជាជនរស់នៅដាច់ឆ្ងាយពីគ្នា និងមានចំងាយផ្លូវឆ្ងាយពី មណ្ឌលសុខភាព ស្រុក និង ពីឃុំមកខេត្តរតនគីរី បណ្តាលអោយមានការលំបាក ក្នុងការធ្វើដំណើរ ហើយប្រជាពលរដ្ឋ តែងតែជួបប្រទះនូវប្រភេទជំងឺច្រើនប្រភេទ ដូចជានៅរដូវវស្សាប្រជាពលរដ្ឋតែងជួបប្រទះនូវជំងឺគ្រុនចាញ់ គ្រុនឈាម ជំងឺក្អកមាន់ និងនៅរដូវប្រាំងតែងជួបប្រទះជំងឺរលាកផ្លូវដង្ហើមលើ និងផ្លូវដង្ហើមក្រោម ព្រមទាំងជំងឺរាគរូសទៀតផង ។

បច្ចុប្បន្នមណ្ឌលសុខភាពឃុំ កំពុងខ្វះអាគារសំរាប់អ្នកជំងឺសំរាកព្យាបាល ខ្វះគ្រូពេទ្យ និង វេជ្ជបណ្ឌិត សំរាប់ពិនិត្យ និងព្យាបាលជំងឺ ។ ដោយអ្នកជំងឺមនុស្សចាស់ និង កុមារសំរាកនៅជាមួយគ្នា ដែល ជាហេតុនាំឱ្យមានបញ្ហាដល់សុវត្ថិភាពចំពោះអ្នកជំងឺ ពីព្រោះកុមារងាយនឹងឆ្លងជំងឺពីមនុស្សចាស់ និងម្យ៉ាងទៀត មានអ្នកជំងឺឈឺធ្ងន់ ពុំមានគ្រូពេទ្យ ឬ វេជ្ជបណ្ឌិតពិនិត្យព្យាបាលជំងឺ អោយបានដឹតដល់ ជាពិសេសស្ត្រីមានផ្ទៃពោះប្រហែល ៥០-៦០%ជាចំនួនដ៏តិចតួច ដែលបានទទួលសេវាពី ពេទ្យឆ្មប ក្រៅពីនោះដែលជាចំនួនច្រើនសុទ្ធតែទទួលសេវាពីឆ្មបបុរាណ ។ ដោយឃុំមានប្រជាពលរដ្ឋពុំគ្រប់ចំនួនតាមបទដ្ឋាន នៃស្តង់ដាដែលតំរូវឱ្យមានប្រជាពលរដ្ឋគ្រប់ចំនួនទើបអនុញ្ញាត ឱ្យបង្កើតអោយមានប៉ុស្តិ៍សុខភាព នៅតាមភូមិក៏ដោយ ក៏គួរបង្កើតឱ្យមានប៉ុស្តិ៍សុខភាពនៅតាមបណ្តាភូមិ ពីព្រោះ ភូមិនីមួយៗជាតំបន់ដាច់ស្រយាល នៅឆ្ងាយពីទីរួមខេត្ត ។ ដូច្នេះជាអាទិភាព ឃុំត្រូវលើកផែនការសាងសង់ ប៉ុស្តិ៍សុខភាពអោយមាននៅតាមភូមិ នីមួយៗ ទើបអាចជួយសំរាលដល់ការលំបាក លើការថែទាំសុខភាពក្នុងមូលដ្ឋាន ។

### ខ. ការផ្គត់ផ្គង់ទឹកស្អាត

ការប្រើប្រាស់ទឹកស្អាតនៅក្នុងឃុំតឺនបច្ចុប្បន្ន នៅតែជាបញ្ហាចំបង នៅឡើយព្រោះថាចំពោះអណ្តូងទឹក ស្អាតនៅក្នុងឃុំ ដែលបានសាងសង់ពីមុននោះ មួយចំនួនត្រូវបានខូចខាត ដូច្នេះជាជំហ៊ានដំបូងនៃការអភិវឌ្ឍន៏ ត្រូវស្តារ និងជួសជុលនូវប្រភពទឹកស្អាតទាំងនេះ ហើយជាផែនការនៅពេលអនាគត ឃុំត្រូវបន្ថែមនូវគម្រោងផែនការក្នុងការរៀបចំក្នុងការធ្វើអាងដើម្បីស្តុកទឹកស្អាត និង ព្រមទាំងផ្តល់ជូនធុងចម្រោះគ្រប់គ្រួសារនៅក្នុងភូមិ នីមួយៗ ដើម្បីចែកចាយជូនប្រជាពលរដ្ឋប្រើប្រាស់ ។

ដើម្បីធានាបាននូវការប្រើប្រាស់ទឹកស្អាត សំរាប់ប្រជាជន នៅក្នុងឃុំ ទាំងមូលនោះឃុំមានគម្រោង ផែនការកសាងនូវបរិក្ខារទឹកស្អាត ដោយជីកអណ្តូងស្នប់ចំនួន ១១ អណ្តូងថែមទៀត ចំនួន ០៤ភូមិ ភូមិតឺន ឡាអ៊ិន កាំបាក់ និងភូមិតាហ៊ីុយ និងធ្វើការជួសជុលអណ្តូងស្នប់ដែលមានស្រាប់ ចំនួន ១១ សំរាប់ ០៤ភូមិដែរ ។

### ២.៤.៥.៣ ផ្នែកវប្បធម៌ និងសាសនា

ដោយសារឃុំតឺនភាគច្រើនប្រជាពលរដ្ឋជាជនជាតិដើមភាគតិច ដូចនេះផ្នែកព្រះពុទ្ធសាសនាពួគគាត់មិន មានការគោរពទេ គឺពួគគាត់កាន់ សាសនាព្រហ្មញ្ញសាសនា ។ បច្ចុប្បន្ន មានការហូរចូលនូវជនជាតិ ខ្មែរឥស្លាម និង ប្រជាជនខ្មែរដែលបានទៅរស់នៅក្នុងឃុំនេះ ធ្វើអោយពួកគាត់ទុកដីសំរាប់សាងសង់វត្ត មួយកន្លែងសំរាប់ប្រជាជនខ្មែរយើង

ហើយបច្ចុប្បន្នសំរាប់ជនជាតិដើមភាគតិច ពួកគាត់នៅតែមានទំនៀមទំលាប់លើការសែនព្រេនអារុក្ខអារក្សអ្នកតាម្ចាស់ ទឹកម្ចាស់ដីដែលបានថែរក្សានៅក្នុងព្រៃ និងដីដែលពួគគាត់រស់នៅ និងការសែនស្រូវនៅពេលដែលពួគគាត់ប្រមូលផល ទាំងនេះជាការគោរពផ្នែកព្រហ្មញ្ញសាសនា ។ ប៉ុន្តែដោយឡែកប្រជាជននៅក្នុងឃុំក៏បានគ្រោងនូវការ

សាងសង់ មជ្ឈមណ្ឌលវប្បធម៌ជនជាតិដើមភាគតិច ៤កន្លែងដែលមាននៅតាមបណ្តាភូមិ ដើម្បីក្នុងការ ស្រាវជ្រាវនូវវប្បធម៌របស់បង ប្អូនជនជាតិដើមភាគតិច លើការថែរក្សាវប្បធម៌ដើម្បីផ្តល់ចំណេះដឹងដល់ កូនចៅជំនាន់ ក្រោយនៅក្នុងឃុំ ។

### ២.៤.៥.៤ ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងប្រព័ន្ធស្រោចស្រព

ផ្អែកតាមស្ថានភាពជាក់ស្តែងក្នុងឃុំតឺន ឃើញថាផ្លូវមួយចំនួនត្រូវធ្វើការកែលំអរ ដូចជាផ្លូវគ្រួសក្រហម ដែលបានសាងសង់ពីមុន មកបច្ចុប្បន្នត្រូវបានខូចខាត ជាក់ស្តែងផ្លូវពីឃុំតឺន មកតាហ៊ីយ កាំបាក់ ចូលទៅភូមិកាំបាក់ ហើយនៅក្នុងឆ្នាំ២០០៩ នេះឃុំបាន ធ្វើការជួសជុលឡើងវិញបាន ចំនួន ៣ខ្សែ ៣ភូមិ គឺភូមិ តាហ៊ីយ តឺន និងកាំបាក់ ប្រវែងសរុប ១៤០០ ម និងសាងសង់ផ្លូវថ្មី ១ខ្សែទៀត ពីភូមិកាំបាក់ មកភូមិឡាអ៊ិនដែល មានប្រវែង ១០០០០ ម ។

បច្ចុប្បន្នបើយើងពិនិត្យជាក់ស្តែងផ្លូវក្រាលគ្រួសក្រហមនៅក្នុងឃុំតឺនរួមមាន ៥ខ្សែ ខ្សែទី ១ គឺជាផ្លូវជាតិលេខ ៧៨ មានប្រវែង ៦៩៥៦ ម ខ្សែទី ២ ពីតំបន់ឡាអ៊ិនស្រែ ទៅឡាអ៊ិនចំការមានប្រវែង ៦៩០០ ម ខ្សែទី ៣ ត្រង់ចំនុចច្រកចូល គ ៦០ ទៅ ទៅភូមិតឺន មានប្រវែង ១០០៣៣ ម ខ្សែទី ៤ ផ្លូវពីម៉ឺនថាំងមកផ្លូវជាតិលេខ ៧៨ និង ខ្សែទី ៥ ពីភូមិតឺនទៅតាហ៊ីយ ។

ដោយឡែកចំពោះផ្លូវដីស និងដីក្រហម ដែលត្រូវបានក្លាយពីផ្លូវថ្មើរជើង និង ផ្លូវរទេះ នោះគឺឃុំមិនទាន់បានគិតគូរលើការសិក្សានៅឡើយទេ ព្រោះផ្លូវថ្មើរជើងភាគច្រើនជាផ្លូវក្នុងព្រៃ ហើយមានទំហំ ១-១.៥០ម ប៉ុណ្ណោះដែលបច្ចុប្បន្ន មានប្រវែងក្នុងឃុំសរុប ១២០ ៥៦១ម សំរាប់បងប្អូនជនជាតិដើមភាគតិចធ្វើដំណើរដូចជាការ បណ្តើរឆ្កែរកសត្វ និងរកបន្លែបង្ការព្រៃ និងចរាចរក្នុងការ ទំនាក់ទំនងរវាងភូមិ នឹងភូមិ ដែលជាទំនៀមទំលាប់តាំង ពីយូណាស់មកហើយ ។

នៅក្នុងដំណើរការអភិវឌ្ឍន៏ ទៅលើប្រពន្ធ័ទឹក ឃុំបានធ្វើការសិក្សាទៅលើ ប្រភពទឹក ដែលមានស្រាប់ ដូចជា អូរខ្មេះ ដែលជាអូរមួយធំនៅក្នុងឃុំ និង ប្រឡាយរួមមាន ៥ ខ្សែ (ខ្សែទី១ នៅអូរម៉ាន់តាន់ និងអូរត្រោមភូមិតឺន)(ខ្សែទី២ ចំណុចទំនប់អូរត្រោម ១៥០០ម នៅភូមិតឺន)(ខ្សែទី៣ចំណុចស្រែសែនភូមិតាហ៊ីយ)(ខ្សែទី ៤ចំណុចត្រង់ស្រែឬស្សីរ៉ាប ភូមិតាហ៊ីយ)(ខ្សែទី ៥ចំណុចត្រង់ស្រែអន្ទង់ នៅភូមិកាំបាក់)

ដោយផ្អែកទៅស្ថានភាពភូមិសាស្ត្រ និងលទ្ធភាព អំណោយផលរបស់ឃុំតឺន នោះឃុំបានលើកគម្រោងផែនការអភិវឌ្ឍន៏ សំរាប់រយ:ពេល១៥ឆ្នាំខាងមុខ ដោយធ្វើការ ស្តារ ប្រឡាយមេចំនួន ២ខ្សែ ស្មើរនឹង២ គីឡូម៉ែត្រ នៅភូមិកាំបាក់ និងសាងសង់ ២ ទៀតនៅភូមិឡាអ៊ិននៅតំបន់ ឡាអ៊ិនស្រែបន្ថែមទៀត និងធ្វើការ ជួសជុលទំប់ទឹក ចំនួន ១កន្លែង នៅភូមិឡាអ៊ិន ព្រមទាំងធ្វើការសាងសង់ទ្វាទឹក ៣ កន្លែង ១ នៅភូមិកាំបាក់ និង១ទៀតនៅភូមិឡាអ៊ិន ដែលមានវិសាលភាពស្រោច ស្រព្វទៅលើដីស្រែ ប្រមាណ៤០២ ហិកតា ។ ក្នុងករណីដែលឃុំអនុវត្តបាននូវផែនការខាងលើនោះ ឃុំអាចធ្វើស្រែបង្កើនរដូវនិងអាចធានាបាននូវសន្តិសុខ ស្បៀង ក្នុងឃុំទាំងមូល ។

ស្ថានភាពលំនៅដ្ឋានរបស់ប្រជាពលរដ្ឋឃុំតឹន ភាគច្រើនជាលំនៅដ្ឋាននៅជាប់ដងផ្លូវក្រាលគ្រួសក្រហម ហើយរស់នៅជាក្រុមកុលសម្ព័ន្ធផ្តុំគ្នា និងដាច់ពីគ្នាពីភូមិមួយទៅភូមិមួយ ដូច្នេះជាចាំបាច់ប្រជាជន ត្រូវមានការឆ្លងទៅមកពីភូមិមួយទៅភូមិមួយ ហើយបញ្ហានេះ ជាបញ្ហាចោទសំរាប់ប្រជាពលរដ្ឋរបស់ឃុំតឹន ព្រោះបច្ចុប្បន្នតាមភូមិខ្លះមិនទាន់មានស្ពាន សំរាប់ប្រជាពលរដ្ឋ ក្នុងការឆ្លងកាត់អោយបានងាយស្រួលនៅឡើយនោះទេ។ ផ្អែកតាមបញ្ហាខាងលើ ឃុំបានលើកគម្រោងផែនការ លើការសាងសង់ស្ពានឈើ ចំនួន ៣កន្លែង ១កន្លែងនៅ អូរអន្ទាន់ ភូមិតឹន ១កន្លែងទៀតនៅអូរម៉ាន់តាន់ ភូមិតឹន ១កន្លែងទៀតអូរត្រាមតឹន។

បច្ចុប្បន្ន លូឆ្លងផ្លូវ នៅក្នុងឃុំតឹន មានការខូចខាត មួយចំនួន ដោយសារ ផ្លូវគ្រួសក្រហម ត្រូវខូចខាតធ្វើអោយលូត្រូវខូចបែក និង លប់ដីជិតមិនអាចប្រើបាន ដូច្នេះតម្រូវការក្នុងពេលអនាគតតម្រូវអោយមានការជួសជុលនិងការសាងសង់ លូឆ្លងផ្លូវ និង លូរំដោះទឹក ចំនួន ១៨ លូ ដែលក្នុងនេះមាន ទីតាំង នៅភូមិ ឡាអ៊ុន និងភូមិកាំបាក់ ហើយឃុំ តឹនក៏មានគម្រោងធ្វើ ផ្លូវក្រាលគ្រួសក្រហម ចំនួន ៣ខ្សែ សំរាប់រយៈពេល ១៥ ផងដែរ

<u>តារាងការអភិវឌ្ឍន៏ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត</u>

| ប្រភេទហេដ្ឋារចនាសម្ព័ន្ធ | ចំនួន/ប្រវែង ឆ្នាំនេះ | ចំនួន/ប្រវែង ១៥ឆ្នាំ | បំរែបំរួល |
|---|---|---|---|
| **១- ហេដ្ឋារចនាសម្ព័ន្ធផ្លូវ** | | | |
| - សាងសង់ផ្លូវលំក្រាលគ្រួសក្រហម | ២ខ្សែ ២០ គ.ម | ៣ខ្សែ ២៥ គ.ម | ៣ខ្សែ ៤៥ គ.ម |
| - លូឆ្លងកាត់ផ្លូវ | ១២ កន្លែង | ១៨ កន្លែង | ៣០ កន្លែង |
| - ស្ពានឈើ | ០៣ កន្លែង | ០២ កន្លែង | ០៥ កន្លែង |
| - ទ្វារទឹក | ០ | ០៣ កន្លែង | ០៣ កន្លែង |
| **២- ប្រព័ន្ធស្រោចស្រព** | | | |
| - ស្តារប្រឡាយ | ០ | ៥ខ្សែ ០២ គ.ម | ៥ខ្សែ ០២ គ.ម |
| - ជួសជុលទំនប់ទឹក | ០ | ១ កន្លែង ៥០០ម | ១ កន្លែង ៥០០ ម |

# ជំពូក ៣

# ផែនការប្រើប្រាស់ដីពេលអនាគត ឆ្នាំ ២០០៩ ដល់ ២០២២

## ៣.១ ស្ថានភាពដី សក្តានុពលដី និងតម្រូវការដី

### ៣.១.១ ស្ថានភាពដីទូទៅ និងសក្តានុពល

នៅក្នុងឃុំតឺន ធនធានដែលមានស្រាប់អាចផ្តល់នូវសក្តានុពលភាពដល់ការប្រើប្រាស់ដី និងអភិរក្ស អភិវឌ្ឍន៍ ទៅលើធនធានទាំងនោះ អោយមាននិរន្តរភាព ដែលក្នុងនោះរួមមានដូចជា : ស្ថានភាពដី ដែលជាតំបន់ដីមានជីជាតិ ដែលជាប្រភេទដីក្រហម លាយនិងដីល្បាយខ្សាច់ពណ៌ខ្មៅ ដែលអំណោយផលទៅលើដំណាំយុទ្ធសាស្ត្រ និងការធ្វើ កសិកម្ម សំរាប់ជួយទ្រទ្រង់ដល់ការប្រកបមុខរបររស់នៅ របស់ប្រជាពលរដ្ឋ ។ដោយឡែកធនធានធម្មជាតិដីសំបូរបែប ដែលជាដែនជំរកសត្វព្រៃលំផាត់ ដែលផ្តល់នូវបរិស្ថានធម្មជាតិដ៏ល្អប្រសើរសំរាប់សត្វព្រៃ និងនៅក្នុងទន្លេមាន មច្ឆាជាតិរស់នៅ ព្រមទាំងពពួកជីវៈចំរុះ នៃប្រព័ន្ធអេកូឡូស៊ី ដែលធ្វើអោយតំបន់នេះបានផ្តល់នូវសារៈប្រយោជន៍ បំពេញអោយគ្នាទៅវិញទៅមក មិនត្រឹមតែប៉ុណ្ណោះ ធនធានដីសំបូរ បែបនេះបានជួយដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ក្នុងការដកហូតអនុផលព្រៃឈើ ដូចជា វល្លិ៍ ផ្តៅ ឫស្សី ឱសថបុរាណ និងប្រភេទឈើប្រណិត។ដូចជាបេង នាងនួន ក្រញូង គគី ស្រឡៅ ដែលជាឈើសំរាប់សំណង់ និងគ្រឿងសង្ហារឹមជាដើម សំរាប់បំរើការអោយក្នុងតំបន់ និងក្រៅតំបន់ ។

### ៣.១.២ តម្រូវការដីតាមប្រភេទ

ដោយផ្អែកទៅលើអត្រាកំណើនរបស់ប្រជាពលរដ្ឋមានការកើនឡើង ដូចនេះតម្រូវការ នៃការប្រើប្រាស់ទៅលើធនធានត្រូវមានការសិក្សា និងធ្វើការពិចារណានៃធនធានដែលមាននៅក្នុងឃុំ ដោយរៀបចំគម្រោងផែនការទៅលើតម្រូវការពង្រីកដីលំនៅដ្ឋានសំរាប់សម្បទានសង្គមកិច្ច បានកំណត់នៅលើផ្ទៃដី ១កន្លែងដែលស្ថិតនៅតំបន់ឡាអ៊ិនស្រែ និងមួយភាគទៀតជាដីស្រែដែលមាន ៥ កន្លែងស្មើនឹង ៥០ហិកតា ដោយហេតុថាតំបន់នោះមានប្រព័ន្ធស្រោចស្រព្វពីជងអូរមួយចំនួន ជាពិសេសអូរខ្វេះ និងអូរឡក ដែលតំបន់នេះមានសក្តានុពលក្នុងការរៀបចំដីស្រែវស្សាសំរាប់បងប្អូនជន ជាតិដើមភាគតិច ធ្វើការផ្លាស់ប្តូរពីការធ្វើចំការពនេចរមកធ្វើស្រែវស្សាវិញទាំងអស់នេះគឺឃុំមានការពិភាក្សាជាមួយ ប្រជាជននៅក្នុងឃុំ ព្រមទាំងឃុំបានរៀបចំផែនការអនាគតដោយបានគ្រោងដីសំរាប់លំនៅដ្ឋានភូមិដែលមានទំហំ ០៧ ហិតតា សំរាប់រយៈពេល ១៥ ឆ្នាំ សំរាប់ជួយដល់ប្រជាជនដែលមានការខ្វះខាតដីសំរាប់ការតាំងទីលំនៅដ្ឋានដោយជ្រើសរើសកន្លែងដែលមានប្រភពទឹកគ្រប់គ្រាន់សំរាប់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់នាពេលអនាគត ។

**- សហគមន៍ព្រៃឈើ :** ដែលគ្រប់គ្រងដោយសហគមន៍ : តំបន់នេះភាគច្រើនជាប្រភេទព្រៃស្រោងសើម និងព្រៃរបោះដែលមានពីកន្លែង ទំហំ ៥៤៣៨ ហិតតា ហើយត្រូវបានបង្កើតឡើងដោយសហគមន៍នៅក្នុងមូលដ្ឋាន ដោយសហការណ៍ជាមួយស្ថាប័នជំនាញដើម្បីគ្រប់គ្រង និងការពារព្រៃឈើក្នុងការដកហូតផល-អនុផលព្រៃឈើប្រកបដោយនិរន្តភាពហើយដីព្រៃនេះជាដីសាធារណៈរបស់រដ្ឋមិនអាចយកដីទាំងនេះ ប្រើប្រាស់សំរាប់ជាប្រយោជន៍ឯកជន ឡើយ ។

- តំបន់ទេសចរណ៍ ៖ ដោយឃុំតឺនជាឃុំសំបូរទៅដោយសក្តានុពលដូចជាព្រៃឈើ សត្វព្រៃគ្រប់ប្រភេទ ជាពិសេសតំបន់ទឹកធ្លាក់អូរខ្វេះនៅភូមិឡាអ៊ិន ដែលអ្នកភូមិឡាអ៊ិន បានគ្រោងដីតំបន់នោះដែលមានទំហំ ១១ ហិកតា សំរាប់តំបន់ទេសចរណ៍ ដើម្បីទាញយកនូវប្រាក់ចំណូលក្នុងការទ្រទ្រង់ជីវភាពរស់នៅរបស់បងប្អូនជនជាតិដើមភាគតិច ដែលពឹងផ្អែកទាំងស្រុងទៅលើធនធានធម្មជាតិនោះ ។

**- ព្រៃអភិរក្សគ្រាប់ពូជអោយដុះឡើងវិញ ៖** តំបន់នេះមានទំហំ ៤០ ហិកតា ត្រូវបានការពារ និងថែរក្សា ដោយសហគមន៍មូលដ្ឋាន និងដោយរដ្ឋបាលព្រៃឈើដែលតំបន់នោះត្រូវបានការពារគ្រាប់ពូជអោយដុះឡើងវិញ ដើម្បីរក្សាបាននូវធនធានព្រៃឈើ ក៏ដូចជាសត្វព្រៃ និងជីវះចំរុះ គ្រប់ប្រភេទដើម្បីទ្រទ្រង់នូវបរិស្ថានអោយមានឡើងវិញ ។

**- តំបន់អភិរក្សដើមជ័រ ៖** ប្រជាពលរដ្ឋនៅក្នុងឃុំតឺនក្រៅពីការធ្វើស្រែ ចំការ ពួកគាត់មានធនធានព្រៃឈើ ដែលត្រូវដកហូត ផល-អនុផលព្រៃឈើ ពីដើមជ័រដែលផល-អនុផលទាំងនោះបានផ្តល់នូវប្រាក់ចំណូលជាច្រើន ក្នុងការទ្រទ្រង់ដល់ជីវភាពរស់នៅរបស់បងប្អូនជនជាតិដើមភាគតិច នៅក្នុងតំបន់នោះ ។ ម្យ៉ាងទៀតការអភិរក្សដើមជ័រក៏អាចជួយរក្សានូវធនធានសត្វព្រៃមួយចំនួន និងជីវៈចំរុះជាច្រើននៅក្នុងតំបន់នោះដែរ ដែលត្រូវរក្សា និងការពារ ។ ធនធានដើមជ័រនោះមាន ៣ កន្លែងដែលមានទំហំសរុប ៩៨១ ហិកតាដែលស្ថិតនៅក្នុង ភូមិឡាអ៊ិន ។

- ដីព្រៃអារក្ស ៖ ជាតំបន់ព្រៃដែលប្រជាជនឃុំតឺន មានការគោរពបូរជាជាទីសក្ការះទៅតាមបែបប្រពៃណីទំនៀមទំលាប់ និងមានជំនឿយ៉ាងមុតមាំ លើអារក្ស អ្នកតា ម្ចាស់ទឹក ម្ចាស់ដី ដូចជាការសែនព្រេន ឬការបន់ស្រន់សុំអ្វីមួយ ដូចជាមានគ្រោះថ្នាក់ ឬឧប្បត្តិហេតុអ្វីមួយ ឬក៏កូនចៅញាតិសណ្តាន ដូចជាមានជំងឺ ឈឺគ្រុនក្តៅ ខ្យល់ចាប់ រាករូសជាដើមដោយធ្វើការរំលឹកនឹកដល់ខ្មោចចាស់ព្រឹទ្ធាចារ្យ ណាដែលរស់នៅគ្រប់គ្រងភូមិទាំងមូល មានឫទ្ធិបារមីអំណាចដឹកនាំ ពួកអ្នកស្រុកតែងបានសេចក្តីសុខ ហេតុដូចនេះឃុំបានរក្សាតំបន់នេះសំរាប់ជាកន្លែងបូជាសក្ការះដែលរួមមាន ៥កន្លែង នៅភូមិឡាអ៊ិន ៣កន្លែង ស្មើនិង ៩០ ហិតា កាំបាក់ ១កន្លែង ស្មើនិង ៣០ ហិកតា និងភូមិតាហ៊ីយ មាន១កន្លែង ស្មើ ៦ ហិតា ។

**- ដីព្រៃកប់ខ្មោច ៖** ដោយឃុំតឺនជាឃុំដែលភាគច្រើន ជាជនជាតិដើមភាគតិចរស់នៅដូចនេះតាមទំនៀមទំលាប់របស់ពួកគាត់នៅពេលដែលមានមនុស្សស្លាប់ គឺត្រូវយកសពនោះទៅកប់ ហេតុដូចនេះនៅតាមភូមិនីមួយៗ ពួកគាត់តែងតែតម្រូវអោយមានដីសំរាប់កប់សពដែលមានទំហំសរុប៦ហិកតានៅភូមិឡាអ៊ិនមាន ២កន្លែង ភូមិឡាអ៊ិនចំការ ១កន្លែង និងតំបន់ឡាអ៊ិនស្រែ ១កន្លែង, ភូមិតឺន ១កន្លែង,ភូមិកាំបាក់ ១កន្លែង តាហ៊ីយ ១កន្លែង ។

**- ដីកសិកម្មពនេចរ ៖** ដោយឃុំតឺនជាឃុំដែលមានប្រជាពលរដ្ឋភាគច្រើនជាបងប្អូន ជនជាតិដើមភាគតិច ដូចនេះការធ្វើស្រែវស្សាតែមួយរដូវគឺវាមិនគ្រប់គ្រាន់ចំពោះតម្រូវការសំរាប់ប្រជាពលរដ្ឋនៅក្នុងឃុំឡើយ ហេតុដូច្នេះហើយប្រជាពលរដ្ឋនៅ ក្នុងភូមិឃុំគឺពួកគាត់តម្រូវអោយមានការធ្វើចំការពនេចរ បន្ថែមសំរាប់ជាជំនួយក្នុងការ ខ្វះខាត

ស្មៀងព្រោះការធ្វើចំការពនេចរ ពួកគាត់អាចដាំដំណាំ និងបន្លែបង្ការ លាយជាច្រើនសំរាប់ការផ្គត់ផ្គង់បន្ថែមមុនពេលការប្រមូលផលស្រូវវស្សាមកដល់ ។

**- ដីប៉ុស្តិ៍រដ្ឋបាលឃុំ :** ដីប៉ុស្តិ៍រដ្ឋបាលឃុំ បានគ្រោងសំរាប់រៀបចំ សាលាឃុំដែលមានទំហំចំនួន ៤៣១៦ ម៉ែត្រការេ មានទីតាំងស្ថិតនៅភូមិកាំបាក់ ដូច្នេះប្រភេទដីនេះ ស្ថិតនៅក្នុងក្របខ័ណ្ឌ ជាដីឯកជនរបស់រដ្ឋសំរាបបំរើអោយឃុំ។

**- ដីសាលារៀន :** ដីសាលារៀនឃុំក៏បានគ្រោងទុកចំនួន ១កន្លែងដែលមានទំហំ ៦ហិកតា ដែលស្ថិតនៅតំបន់ឡាអ៊ុនស្រែ ដីនេះជាសាធារៈរបស់រដ្ឋ ដែលបានគ្រោងសំរាប់ធ្វើសាលា ។

<u>តារាងតម្រូវការនៃការប្រើប្រាស់ដីពេលអនាគត</u>

| **ការគ្រប់គ្រង/ការប្រើប្រាស់ដីធ្លី** | **ក្រឡាផ្ទៃឆ្នាំនេះ(ហិចតា)** | **ក្រឡាផ្ទៃ ១៥ឆ្នាំ(ហិចតា)** | **បំរែបំរួល (ហិចតា)** |
|---|---|---|---|
| **១- ការគ្រប់គ្រង និងកាន់កាប់ដី** | | | |
| - សហគមន៍ព្រៃឈើ | 0 | ៥៤៣៨ | ៥៤៣៨ |
| - តំបន់ទេសចរណ៏ | 0 | ១១ | ១១ |
| - ព្រៃអភិរក្សគ្រាប់ពូជ | 0 | ៤0 | ៤0 |
| - ដីព្រៃអភិរក្សដើមជ័រ | 0 | ៩៨១ | ៩៨១ |
| - ដីព្រៃអារក្ស | ៥៨ | ១៨៩ | ១៣១ |
| - ដីកប់ខ្មោច | 0 | ៦ | ៦ |
| **២- ការប្រើប្រាស់ដី** (តាមតម្រូវការ) | | | |
| ដីលំនៅដ្ឋានភូមិ | ២៥ | ២៦ | ១ |
| ដីកសិកម្មពនេចរ | ១២៨៩ | ១៥១៧ | ២២៨ |
| ដីស្រែវស្សា | ៤0២ | ៤៥២ | ៥0 |
| ដីរដ្ឋបាលឃុំ | 0 | 0.៤៣៣៦ | 0.៤៣៣៦ |
| ដីសាលារៀន | ៩ | ១៤ | ៥ |
| ប៉ុស្តិ៍សុខភាព | ១ | ៣ | ២ |

## ៣.២ ការបែងចែកដីតាមតម្រូវការប្រើប្រាស់

### ៣.២.១ ការវិភាគអន្តរអំពើ

ការគ្រប់គ្រងនិងបែងចែកសំរាប់ការប្រើប្រាស់ដី មានកត្តាដែលធ្វើអោយមានការផ្តល់នូវផលប្រយោជន៏ និងមាននិរន្តរភាពហើយនឹង មានការប៉ះពាល់ទៅលើផ្នែកមួយចំនួនដូចជា សេដ្ឋកិច្ច សង្គមកិច្ច និងបរិស្ថាន ដែលក្នុងនោះមានដូចជា:

- **ដីលំនៅដ្ឋាន:** ការប្រែប្រួលពីព្រៃដុះឡើងវិញនិងព្រៃរបោះរិចរិលឱ្យប្រែក្លាយទៅជាដីលំនៅដ្ឋានសំរាប់សម្បទានសង្គមកិច្ចវាជាការជួយដល់ប្រជាពលរដ្ឋដែលខ្វះខាតដី " ប៉ុន្តែដីនោះនៅជាដីសាធារណៈរបស់រដ្ឋនៅឡើយ "សំរាប់ការសាងសង់លំនៅដ្ឋាន កត្តានេះវាជុំរុញឱ្យប្រជាពលរដ្ឋនាពេលបច្ចុប្បន្នក៏ដូចជាកូនចៅជំនាន់ក្រោយ មិនបានធ្វើចំណាកស្រុក ដែលអ្នកទាំងនោះជាទំពាំងស្នងឬស្សីសំរាប់ធ្វើការអភិវឌ្ឍន៏ឃុំនាពេលខាងមុខ ប៉ុន្តែលំនៅដ្ឋានបងប្អូនជនជាតិពីមុនច្រើនធ្វើការបំផ្លាស់ទីនៅពេលដែលលំនៅដ្ឋានមានអ្នកឈឺឬស្លាប់គាត់យល់ថាទីនោះអារក្សមានការខឹងសំបារឹឈប់ឱ្យនៅទីនោះ " នេះជាប្រពៃណីរបស់បងប្អូនជនជាតិដើមភាគតិច " ។ កត្តាទាំងនេះវាបានធ្វើឱ្យប៉ះពាល់ដល់ព្រៃឈើ និងគំរបព្រៃធ្វើឱ្យបរិស្ថានប្រែប្រួលបាត់បង់ជំរកសត្វព្រៃ និងជីវះចំរុះផ្សេងទៀត ។

- **ដីស្រូវវស្សា:** ការពង្រីកដីស្រែចំការសំរាប់បង្កបង្កើនផលទៅថ្ងៃអនាគតដោយសារកំណើនប្រជាពលរដ្ឋកើនឡើងពីព្រៃរបោះរិចរិល " ដែលជាដីសាធារណៈរបស់រដ្ឋ " នោះវាជាការប្រសើរហើយ លើវិស័យកសិកម្មដែលជាកត្តាអំណោយផលដល់ការបង្កបង្កើនផលក៏ដូចជាការលើកស្ទួយសេដ្ឋកិច្ចនៅក្នុងមូលដ្ឋានក៏ដូចជាការបង្កើនជីវភាពគ្រួសារ ។ ប៉ុន្តែដីទាំងនេះត្រូវធ្វើពាក្យស្នើសុំជាដីសម្បទានសង្គមកិច្ច ។

- **ដីកសិកម្មពនេចរ:** ការប្រែប្រួលប្រភេទដី ពីព្រៃរបោះ រឺព្រៃដុះឡើងវិញមកជាដីដំណាំ រឺ ដីកសិកម្មវិលជុំគឺជាទំនៀមទំលាប់របស់ជនជាតិដើមភាគតិចនៅតាមតំបន់នាភូមិភាគឥសាន្ត ព្រោះចំការរបស់ពួកគាត់តែងតែធ្វើបានពី ២-៣ឆ្នាំទើបបោះបង់ចោលរួចហើយគាត់បានកាប់ចំការកន្លែងថ្មីសំរាប់ដាំដំណាំហូបផ្លែរឺដាំស្រូវជាដើម ព្រោះវាជួយផ្គត់ផ្គង់នូវជីវភាពប្រចាំថ្ងៃ ។ ប៉ុន្តែការធ្វើរបៀបនេះវាបំផ្លាញនូវព្រៃឈើ "ព្រោះដីនេះជាដីព្រៃ និងជាដីសាធារណៈរបស់រដ្ឋ " ។

-**ដីសហគមន៏ព្រៃឈើ:** ដោយយល់ឃើញថាការបាត់បង់ព្រៃឈើ ធ្វើឱ្យបាត់បង់ប្រាក់ចំណូលប្រចាំថ្ងៃរបស់ពួកគាត់ និងធ្វើឱ្យបរិយាកាសប្រែប្រួលប្រជាពលរដ្ឋរស់នៅក្នុងឃុំតឺនបានឯកភាពគ្នាបង្កើតសហគមន៏ព្រៃឈើឡើងចំនួន ០២ កន្លែង នៅចំណុចខាងជើងឈៀងខាងលិចភូមិដែលបច្ចុប្បន្នបានធ្វើការស្នើរសុំបង្កើតសហគមន៏មួយស្របច្បាប់ដល់ក្រសួងកសិកម្មរួចទៅហើយដើម្បីធ្វើការអភិរក្សនូវធនធានធម្មជាតិធ្វើការថែរក្សាការពារនិងដាំដុះឡើងវិញនូវប្រភេទឈើមួយចំនួនដែលជិតផុតពូជសំរាប់ជាថ្នាលបណ្តុះសំរាប់កូនចៅជំនាន់ក្រោយបានស្គាល់ និងឱ្យចេះស្រលាញ់ សម្បត្តិធនធានធម្មជាតិដែលមានតម្លៃមហាសាលនេះ ។

- **ដីកប់ខ្មោច:** ឃុំតឺនប្រជាពលរដ្ឋភាគច្រើនសុទ្ធតែជនជាតិដើមភាគតិចដូច្នេះសហគមន៏ភូមិបានព្រមព្រៀងគ្នាទុកដីចំនួនពី៤-៦ហិកតាសំរាប់ធ្វើការកប់នូវសាកសពរួមព្រោះទំនៀមទំលាប់គាត់តែងតែកប់សាកសពរួមគ្នាតាមប្រពៃណីតាំងពីយូរលង់ណាស់មកហើយរហូតដល់បច្ចុប្បន្ននេះ ។



**រូបភាពទី ១០ : ព្រៃកប់ខ្មោចរបស់បងប្អូនជនជាតិដើមភាគតិចទំពួន**

**-ដីសាលារៀន:** ដោយឡែកសាលារៀននៅឃុំតឺនមានចំនួន ៤ កន្លែងតែពុំទាន់គ្រប់គ្រាន់នូវសេចក្តីត្រូវការលើវិស័យអប់រំដូច្នេះចាំបាច់ឃុំត្រូវតែស្វែងរកការជួយឧបត្ថម្ភចំពោះការកសាងអាគារសិក្សាដើម្បីបង្កើននូវធនធានមនុស្សក្នុងមូលដ្ឋានដូចជា សាលាមត្តេយ្យសិក្សា,អនុវិទ្យាល័យ,វិទ្យាល័យជាដើម... ។

**-ដីព្រៃអារក្ស:** ព្រៃអារក្សដែលបងប្អូនជនជាតិដើមភាគតិចធ្វើការគោរពជាទីសក្ការៈដែលគាត់យល់ថាព្រៃនេះមានអ្នកតាម្ចាស់ស្រុកមានឫទ្ធិបារមីពូកែអាចជួយឃុំគ្រង រឺបញ្ចៀសនូវឧបសគ្គដល់កូនចៅ រឺភូមិ ឃុំរបស់ពួកគាត់កុំឱ្យកើតមាននូវជម្ងឺ ដង្កាត់ផ្សេងៗ រឺ មួយអាចសុំនូវការសែនព្រេនរបស់អ្វីតាមបែបព្រហ្មញ្ញសាសនា សំរាប់ការសុខសប្បាយដល់ភូមិ ឃុំ ។



**រូបភាពទី ១១ : ព្រៃអារក្សបងប្អូនជនជាតិដើមភាគតិចទំពួន**

- **តំបន់អភិរក្សគ្រាប់ពូជឈើ:** គឺជាផ្ទៃដីដែលត្រូវបានហ៊ុំព័ទ្ធថែរក្សាការពារ ទុកសំរាប់តំបន់ផ្តល់គ្រាប់ពូជឈើគ្រប់ប្រភេទដូចជា : បេង នាងនួន ធ្នង់ គគី ឈើទាល កកោះ ....ជាដើម ដែលមានផ្ទៃដីចំនួន ៤០ ហិកតា ស្ថិតក្នុងភូមិសាស្រ្ត ភូមិឡាអ៊ិន ឃុំ តឹន ដើម្បីបេះប្រមូលគ្រាប់ ពូជឈើទាំងនេះយកទៅបណ្តុះធ្វើការដាំឡើងវិញ បង្កើននូវធនធានព្រៃឈើ ក៏ដូចជា ការ បង្កើននូវគំរបព្រៃ ធ្វើឱ្យបរិស្ថានបានល្អប្រសើរឡើងវិញ ។

- **តំបន់អភិរក្សដើមជ័រ:** ក្រៅពីការធ្វើស្រែចំការ ប្រជាពលរដ្ឋនៅក្នុងឃុំតឹន ពួកគាត់តែងតែរុករកនូវផលអនុផលព្រៃឈើមួយចំនួនដូចជា: ជ័រ វល្លិផ្តៅ ជាដើមសំរាប់ផ្គត់ផ្គង់ជីវភាពបន្ថែម ពិសេសគឺការដងជ័រលក់ដើម្បីបន្ថែមបង្គ្រប់ជីវភាពប្រចាំថ្ងៃក្នុងនោះ ដែលពួកគាត់បានកំណត់ទីតាំង ៤ កន្លែងសំរាប់ធ្វើការដងជ័របំពេញជីវភាពគ្រួសាររបស់គាត់ ។

-**ប៉ុស្តិ៍សុខភាព:** ឃុំមានគំរោងសាងសង់ប៉ុស្តិ៍សុខភាពបន្ថែមលើដីគ្រោងសាងសង់លំនៅដ្ឋានថ្មី " ដីសម្បទានសង្គមកិច្ច " ដោយសព្វថ្ងៃ មាន ប៉ុស្តិ៍សុខភាពមួយកន្លែងរួចទៅហើយ ប៉ុន្តែវាមិនគ្រប់គ្រាន់នឹងតំរូវការរបស់ប្រជាពលរដ្ឋ ដោយពួកគាត់រស់នៅ តំបន់ឆ្ងាយៗ ។

ការអភិវឌ្ឍនីហេដ្ឋារចនាសម្ព័ន្ធ នៅក្នុងមូលដ្ឋានឃុំ គឺជា កត្តាផ្តល់នូវផលប្រយោជន៍ យ៉ាងច្រើនដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានដែលក្នុងនោះមានដូចជា :

**- ការសាងសង់ផ្លូវ:** គឺជាការសំរួលដល់ការធ្វើដំណើរ និង ចរាចរណ៏គ្រប់ប្រភេទ ហើយនិងចូលរួមក្នុងការកាត់បន្ថយការចំណាយ ទៅលើការងារដឹកជញ្ជូន ។ ការអភិវឌ្ឍន៏នេះ ថ្វីត្បិតតែមានការដោះស្រាយ និងហេតុប៉ះពាល់ខ្លះៗក៏ដោយ ប៉ុន្តែវាផ្តល់នូវផលប្រយោជន៏ច្រើនដល់ប្រជាជនប្រើប្រាស់ ។

**-ការសាងសង់ប្រឡាយ :** ដើម្បីធានាដល់ការស្រោចស្រព្វក៏ជាកត្តាផ្តល់នូវសារៈប្រយោជន៍ ក្នុងការបង្កើននូវ ប្រាក់ចំណូល តាមរយៈការបង្កបង្កើនផល និង ដំណាំរួមផ្សំ។ នៅក្នុងឃុំតឹន តម្រូវការប្រើប្រាស់ទឹកសំរាប់ ស្រោចស្រព្វ គឺ ជាកត្តាសំខាន់ ថ្វីត្បិតតែការពង្រីកប្រពន្ធ័ស្រោចស្រព្វនេះជួបការលំបាកយ៉ាងណាក៏ដោយក៏ឃុំនៅ តែព្យាយាមរកវិធីសាស្រ្តដោះស្រាយ និង ជំរុញអោយមាននិរន្តរភាពលើការងារនេះ ។

ដោយឡែកចំពោះការពង្រីកវិស័យអប់រំ ដោយផ្តោតទៅលើ ការពង្រីកអាគារសិក្សា និង សាលា គឺជាការចាំបាច់បំផុតសំរាប់ការបង្កើនធនធានមនុស្សនៅក្នុងមូលដ្ឋាន។ បច្ចុប្បន្នទោះបីឃុំមានការខ្វះខាតដីសំរាប់បង្កើតសាលាថ្មីសំរាប់ថ្នាក់បឋមសិក្សា និង អនុវិទ្យាល័យ ប៉ុន្តែជាអាទិភាពនៅតាមសាលាចាស់នៅមានដីដែលអាចសាងសង់អាគារសិក្សាបន្ថែមបាន។ រីឯសាលាមតេយ្យ ដោយមើលឃើញការលំបាកសំរាប់កុមារដែលគ្មានលទ្ធភាព ក្នុងការសិក្សានៅទីកន្លែងឆ្ងាយគឺជាអាទិភាពឃុំ ត្រូវព្យាយាមរកដំណោះស្រាយអោយខានតែបាន នៅតាមបណ្តូភូមិគោលដៅព្រោះវាមានសារៈសំខាន់និងជាមូលដ្ឋានគ្រឹះនៃការបណ្តុះបណ្តាល និងការបំពាក់បំប៉នចំណេះដឹងដល់អនក្ខរៈជនក្នុងមូលដ្ឋាន ។

### ៣.២.២ ផែនទីប្រើប្រាស់ដីអនាគត

### ៣.២.២ ការបរិយាយ ការប្រើប្រាស់តាមក្បាលដី

ការប្រើប្រាស់ដីនៅក្នុង ឃុំតឹនត្រូវបានបែងចែក ទៅតាមគោលការណ៍ មួយចំនួន ដែលមានលក្ខណៈជាសត្យានុម័តហើយបានអនុលោមទៅតាមមុខនាទី ដូចខាងក្រោមៈ

**១. ដីលំនៅដ្ឋាន :**

**- ក្បាលដី F 1200**

ដីលំនៅដ្ឋាននេះមានទំហំសរុបចំនួន ៦,៨៨ ហិកតា មានមួយកន្លែងនៅអមសងខាងផ្លូវលំក្រាលគ្រួសក្រហមពី ភូមិកាំបាក់ កាត់ភូមិឡាអ៊ិនស្រែមកចេញ (គបុកសិប)ត្រពាំងច្រេស ។បច្ចុប្បន្នដីនេះត្រូវបានប្រជាពលរដ្ឋធ្វើចំការខ្លះ និង មានសង់ផ្ទះ២ទៅ៣ខ្នង (ផ្ទះចំការ)ហើយដីត្រៀមបង្កើតភូមិគឺជាដីព្រៃរបោះដែលមានចំនួន ៦,៨៣ ហិកតា ។

**២.ចំការពនេចរ :**

**- ក្បាលដី F 2400**

ដីនេះមានទំហំសរុបចំនួន ២២៧,៣៦ ហិកតា មានចំនួន៣កន្លែងស្ថិតនៅផ្សេងៗគ្នាដែលប្រជាពលរដ្ឋ នៅក្នុងឃុំតឹនតែងតែធ្វើការដាំដំណាំសំរាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃមានដូចជា ស្រូវ ពោត ចន្ទី ដំឡូង...... ។ល ។ហើយដីពនេចរទាំងនេះភាគច្រើនស្ថិតក្នុងដីព្រៃរបោះ រឺ ព្រៃដុះឡើងវិញដែលក្នុងនោះមានព្រៃរបោះចំនួន ៦៤,៩៨ហិកតា ព្រៃដុះឡើងវិញចំនួន ១៤៤,៨៨ ហិកតា និងចំការបោះបង់ដុះស្មៅចំនួន ១៦,៨២ ហិកតា ។

**៣. ស្រូវវស្សា :**

**-ក្បាលដី F 2110**

ផ្ទៃដីស្រូវវស្សាសរុបនៅក្នុងឃុំតឹនពេលអនាគត់គឺចំនួន ៥០,២៣ ហិកតា ប្រជាពលរដ្ឋក្នុងឃុំតឹនធ្វើស្រែអាស្រ័យ ទៅលើទឹកភ្លៀងធ្លាក់ភាគច្រើនការធ្វើស្រែរបស់គាត់គឺដាំស្រូវតាមចំការ( បុកដាំ )ហើយផ្ទៃដីស្រែរបស់ គាត់គឺការ កាប់ព្រៃឈើធ្វើចំការដែលនៅក្នុងនោះមានព្រៃស្រោងស្ងួត៨,៤៣ហិកតានិងព្រៃរបោះ ៤០,៧៩ហិកតា ។

**៤. ព្រៃកប់ខ្មោច :**

**-ក្បាលដី F 1320**

ដីនេះមានទំហំសរុប ៦,៣៧ ហិកតា មានចំនួន ៥កន្លែង នៅក្បែរភូមិដែលបងប្អូនប្រជាសហគមន៍ស្ថិតក្នុងឃុំតឹនត្រៀមទុកនៅ ពេលខាងមុខសំរាប់ធ្វើជាកន្លែងបញ្ចុះសាកសពប៉ុន្តែវាពាក់ព័ន្ធនិងចំការពនេចរ ២,៥៤ ហិកតា ព្រៃរបោះ ២,៥៨ហិកតា និងចំការឈើហូបផ្លែ ១,១៨ ហិកតា ។

**៥. សហគមន៍ព្រៃឈើ :**

**-ក្បាលដី F 3710**

ដីត្រៀមបង្កើតសហគមន៍ព្រៃឈើនៅក្នុងឃុំតឺនចំនួន២កន្លែងសរុបចំនួន ៥៤៣៨,៩២ ហិកតា ដែលបងប្អូនប្រជាសហគមន៍បាននិងកំពង់ធ្វើពាក្យស្នើសុំទៅក្រសួងកសិកម្ម (រដ្ឋបាលព្រៃឈើ)ធ្វើតំបន់ថែរក្សាការពារ ដើម្បីទុកអោយកូនចៅជំនាន់ក្រោយបានឃើញនិងបានស្គាល់ពិសេសគឺសំរាប់រុករកបន្លែ បង្ការយកមកផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃរបស់ពួកគាត់ផងដែរ ប៉ុន្តែនៅក្នុងគំរោងដីព្រៃឈើសំរាប់ធ្វើតំបន់ការពារគឺមានពាក់ពន្ធ័និងប្រភេទ ព្រៃមានដូចជា :

-ព្រៃស្រោងសើម ២៥៦១,៥០ ហិកតា

-ព្រៃចំរុះស្រោង និង របោះ ៦៩,៩៤ ហិកតា

-ព្រៃរបោះ ២៤១៦,៥០ ហិកតា

-ព្រៃដុះឡើងវិញ ២៧៨,១២ ហិកតា

-ចំការកសិកម្មពនេចរ ៤,១៦ ហិកតា

-ចំការបោះបង់ដុះស្មៅ ១៨,៦១ ហិកតា

**៦. តំបន់អភិរក្សចំការពូជឈើ :**

**- ក្បាលដី F.3750**

ចំការពូជឈើ២កន្លែងស្ថិតនៅក្នុងភូមិឡាអ៊ិន ឃុំតឺន ស្រុកកូនមុំ ដែលមានផ្ទៃដីសរុបចំនួន ៤០,៦០ ហិកតា ដែលបានទទួលស្គាល់ដោយរដ្ឋបាលព្រៃឈើសំរាប់រុករានទូវប្រភេទឈើដូចជា បេង នាងនួន ធ្នង់ គគី កកោះ ........។ល។ ដែលនៅក្នុងនោះមានព្រៃស្រោងសើមចំនួន ២៥,២២ ហិកតា និងព្រៃរបោះ ១៥,៣៧ ហិកតា។

**៧. តំបន់ទេសចរណ៍:**

**- ក្បាលដី F.3760**

ដីសំរាប់បង្កើតតំបន់ទេសចរណ៍ធម្មជាតិនោះមានទំហំ ១០,៨៤ ហិកតា ស្ថិតនៅក្នុងភូមិកាំបាក់ខាងត្បូងឈាងខាងកើតលយចំងាយប្រមាណប្រហែល ៤ គីឡូម៉ែត្រ នៅក្បែរអូរក្តាមនៅទីនោះគឺមានទឹកធ្លាក់ ខួបប្រាំងវស្សា និងមានព្រៃស្រោងសើមដុះជុំវិញចំនួន ១០,៨៤ ហិកតា ដែលប្រជាពលរដ្ឋតម្រូវទុកសំរាប់ធ្វើ តំបន់ទេសចរណ៍នៅពេលអនាគត ។

## ៨.តំបន់អភិរក្សដើមជ័រទឹក :

**- ក្បាលដី F.3760**

តំបន់នេះមានពាកន្លែងផ្ទៃដីសរុបចំនួន ៩៨១,៧៨ ហិកតា ដែលជាតំបន់សំបូរទៅដោយប្រភេទឈើ ទៀល ផ្ដៀក..ដែលបងប្អូនប្រជាសហគមនិ ឃុំតឹន បានកំនត់ទុកជាតំបន់ធ្វើការដងជ័រសំរាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ ហើយតំបន់ពាក់ពន្ធ័ព្រៃស្រោងចំនួន ៥៨៦,២២ ហិកតា ព្រៃរបោះចំនួន ៣០២,៨២ ហិកតា ព្រៃស្រោង និងរបោះចំនួន ៥៧,១៨ ហិកតា និងព្រៃដុះឡើងវិញ ៣៥,៤៥ ហិកតា ។

## ៩. ព្រៃអារក្ស :

**-ក្បាលដី F.3740**

ព្រៃអារក្សរបស់ឃុំ តឹន មានចំនួនផ្ទៃដីសរុប ១៣០,៦៣ ហិកតា ដែលមានចនួន៥កន្លែង ព្រៃអារក្ស ត្រូវបានបងប្អូនប្រជាពលរដ្ឋក្នុងសហគមន៏មានការជឿជំនឿ នៅពេលមានការឈឺស្កាត់តែងតែបន់ស្រន់តាមបែបព្រហ្មមាញ្ញសាសនាដោយគាត់យល់ថាទីនោះមានអារុកអារក្សអ្នកតាគេនៅថែរក្សាការពារភូមិស្រុក រី នាតំបន់ដែលគោរពតគ្នាតាំងពីដូនតាតមក ។

តំបន់ព្រៃអារក្សនេះមានផ្ទៃដីព្រៃស្រោងចំនួន ៩១,៧៣ ហិកតា និងព្រៃដុះឡើងវិញចំនួន ៣៨,៦៥ ហិកតា ដែលជាតំបន់ពួគគាត់គោរពទៅតាមបែបព្រហ្មមាញ្ញសាសនា ។

| ល.រ | ឈ្មោះក្បាលដី | លេខកូដក្បាលដី | ក្រឡាផ្ទៃសំរាប់១៥ឆ្នាំខាងមុខ( ហិចតា) | ចំនួនកន្លែង |
|---|---|---|---|---|
| ០១ | ដីលំនៅដ្ឋានភូមិ | F1200 | ៦,៨៣ | ១ |
| ០២ | ដីចំការពនេចរ | F2400 | ២២៧,៣៦ | ៣ |
| ០៣ | ដីព្រៃកប់ខ្មោច | F1320 | ៦.៣៧ | ៥ |
| ០៤ | ដីស្រូវវស្សា | F2110 | ៥០,២៣ | ៥ |
| ០៥ | សហគមន៏ព្រៃឈើ | F3710 | ៥៤៣៨,៩២ | ២ |
| ០៦ | តំបន់អភិរក្សតំបន់ពូជឈើ | F3750 | ៤០,៦០ | ២ |
| ០៧ | តំបន់ទេសចរណ៏ | F2400 | ២២៧,៣៦ | ៣ |
| ០៨ | តំបន់អភិរក្សដើមជ័រ | F3760 | ៩៨,៧៨ | ៣ |
| ០៩ | តំបន់ព្រៃអារក្ស | F3740 | ១៣០,៦៣ | ៥ |
| **សរុប** | | | **៦២២០.៧១** | **២៩** |

ឃុំតឺន ថ្ងៃ ..24..ខែ.....4......ឆ្នាំ២០10

**មេឃុំ**

ធា. ហ៊ៅធាះ

**បានឃើញ និង ពិនិត្យត្រឹមត្រូវ**

គោរពជូន ឯកឧត្តម អភិបាលនៃគណៈអភិបាលខេត្ត

និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងជីវរដ្ឋ ខេត្តរតនគីរី

"ដើម្បីមេត្តាពិនិត្យ និងសំរេច"

កូនមុំ ថ្ងៃ ..05...ខែ..04....ឆ្នាំ ២០10

**អភិបាលនៃគណៈអភិបាលស្រុក**

**និងជាប្រធានក្រុមការងារជីវរដ្ឋ**

**ស្រុកកូនមុំ**

ឈឿន ចាន់ឆាង

**បានឃើញ និង ឯកភាព**

រតនគីរី ថ្ងៃ 21....ខែ05.....ឆ្នាំ ២០10

**អភិបាលនៃគណៈអភិបាលខេត្ត**

**និងជាប្រធានគណៈកម្មាធិការគ្រប់គ្រងជីវរដ្ឋ**

**ខេត្តរតនគីរី**

ប៉ាវ ហមផាន

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ១:  ការពិពណ៌នាអំពីស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្ន

ឧបសម្ព័ន្ធ២:  ស្ថានភាពនៃការគ្រប់គ្រង  និងកាន់កាប់ដីបច្ចុប្បន្ន

ឧបសម្ព័ន្ធ៣:  បញ្ហាពាក់ព័ន្ធក្នុងការប្រើប្រាស់ដី

ឧបសម្ព័ន្ធ៤:  ក្របខ័ណ្ឌនៃការអភិវឌ្ឍន៍

ឧបសម្ព័ន្ធ៥:  បញ្ជីគំរោង

ឧបសម្ព័ន្ធ៦:  ផែនទីប្រើប្រាស់ដីលំអិតនៅក្នុងឃុំ

ឧបសម្ព័ន្ធ៧:  ផែនទីប្រើប្រាស់ដីសាមញ្ញនៅក្នុងឃុំ

ឧបសម្ព័ន្ធ៨:  ផែនទីប្រើប្រាស់ដីអនាគតនៅក្នុងឃុំ  ឆ្នាំ២០០៩-២០២២

**ឧបសម្ព័ន ១**

**ការពិពណ៌នា អំពីស្ថានភាពនៃការប្រើប្រាស់ដីបច្ចុប្បន្នឃុំតឺន**

- **ដីលំនៅដ្ឋានភូមិ:**

**ដីភូមិរស់នៅជាកលសម្ព័ន្ធ :**

ដីភូមិរស់នៅជាកលសម្ព័ន្ធរបស់បងប្អូនជនជាតិដើមភាគតិចឃុំតឺន ដែលជាទៀមទំលាប់របស់ពួកគាត់តាំងពីយូលង់មកហើយគឺពួកគាត់មានដីលំនៅដ្ឋានពីកន្លែង ១កន្លែងពួកគាត់តែងតែធ្វើនៅចំការ ឬស្រែដែលគាត់បានធ្វើ និងមួយកន្លែង ទៀតគាត់ធ្វើនៅក្នុងភូមិដោយរស់នៅជាកលសម្ព័ន្ធ ។

១- ដីលំនៅដ្ឋានរស់នៅជាកលសម្ព័ន្ធនៅក្នុងភូមិគឺជាដីស្ថិតនៅ តំបន់ដាច់ស្រយាលឆ្ងាយនៅក្នុងព្រៃដែលរស់នៅជាកលសម្ព័ន្ធផ្តុំគ្នា ។ ជាមួយនេះផងដែរដីភូមិដែលបានរស់នៅជាកលសម្ព័ន្ធ ទាំងនេះត្រូវបានដាំនូវដំណាំរួមផ្សំ បន្តិចបន្តួច តែប៉ុណ្ណោះមានដូចជា ដូង ចេក ក្រូចថ្លុង ស្វាយ ខ្នុរ ក្រៅពីការដាំដំណាំបន្តិចបន្តួចទាំងនោះពួគគាត់មានការ ចិញ្ចឹមសត្វនៅក្នុងភូមិតាមគ្រួសាររបស់ពួគគាត់ ។ ម៉្យាងទៀត ដោយសារពួគគាត់រស់នៅជុំគ្នាជាកលសម្ព័ន្ធដូចនេះពួគគាត់មិនអាចដាំដំណាំបន្លែ បង្ការ តាមគ្រួសារបានទេ ព្រោះពួកគាត់ច្រើនលែងសត្វពាហនៈចោលនៅក្នុងភូមិ របស់ពួគគាត់ ។

២- ដីលំនៅដ្ឋានលាយចំការតាមគ្រួសារភាគច្រើនពួគគាត់ធ្វើចំការពនេចរហើយនៅក្នុងចំការរបស់ពួកគាត់មានដាំដំណាំចំរុះ ដូចជា ស្រូវបុកដាំ ល្ង ម្ទេស ឃ្លោក កុកគ្រីវ ត្រឡាច ល្ពៅ ចេក ស្លឹកគ្រៃ ត្រប់ ជី និងដំណាំផ្សេងទៀតដែលពួគគាត់អាចដាំបាន ។ល។

តាមស្ថានភាពជាក់ស្តែង បើតាមការអង្កេត ឃើញថាលទ្ធភាព សំរាប់ដីលំនៅដ្ឋានរស់នៅជាកលសម្ព័ន្ធនៅក្នុងឃុំតឺនរបស់ពួកគាត់មិនមានការខ្វះខាតដីសំរាប់សង់លំនៅដ្ឋានទេ ។

**ដីភូមិលាយស្រែវស្សា :**

ដីភូមិលាយស្រែ គឺជាដីដែលភាគច្រើនជាដីនៅដាច់ៗពីគ្នា ដែលពួកគាត់សង់លំនៅដ្ឋាននៅជាប់ជាមួយស្រែ ហើយពួគគាត់តែងតែធ្វើសំណាបនៅក្បែរផ្ទះ ហើយដីស្រែទាំងនោះមិនអាចធ្វើអ្វីបានក្រៅពីធ្វើស្រែវស្សាតែមួយរដូវតែប៉ុណ្ណោះ និងដំណាំរួមផ្សំដូចជា ស្លឹកគ្រៃ ពោះគ្រីវ ត្រប់ ត្រឡាច ល្ពៅ ស្ពៃ ហើយដីស្រែទាំងនេះភាគច្រើនមួយគ្រួសារ ១ ហិកតា ទៅ ២ហិតតា ហើយនៅពេលផុតរដូវធ្វើស្រែពួគគាត់វិលត្រលប់មករស់នៅក្នុងភូមិវិញ ។ដូច្នេះតាមការពិនិត្យសក្តានុពល នៃការប្រើប្រាស់ ដីឃើញថាគ្មានតុល្យភាពទៅនិងកំណើន និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋឡើយ គឺបង្កើនផលិតភាពលើ វិស័យកសិកម្មអោយបានល្អប្រសើរជាងមុន ( បញ្ចូលបច្ចេកវិទ្យាថ្មី ) ។

**ដីព្រៃអារក្ស :**

ជាដីសំរាប់ជាទីសក្ការៈសំរាប់គោរព បូជារបស់បងប្អូនជនជាតិដើមភាគតិច និងមានដំណម មិនអោយនណាចូលកាប់រុករានបានឡើយ បើនណាធ្វើខុសច្បាប់ត្រូវមានការឈឺគ្រុន ពីអារុកអារក្ខដែលថែរក្សានៅទីនោះ និងមានការផាកពិន័យពីចាស់ទុំ នៅក្នុងភូមិ តំបន់ព្រៃអារក្សភាគច្រើនមានដើមឈើធំៗ និងជាប្រភេទព្រៃចាស់ញាតិ ដូចជា ស្រឡៃ នាងនួន បេង គគី ត្រាច ទាល សុក្រម ដែលត្រូវបានការពារដោយអ្នកភូមិនៅទីនោះ ។

**ដីចំការឈើហូបផ្លែ :**

ដីចំការឈើហូបផ្លែជាដីស្ថិតនៅដាច់ពីគ្នាដែលដីប្រភេទនេះនៅក្នុងឃុំតឺន ជាប្រភេទដីក្រហមដែលមានជីជាតិ ដីទាំងនេះភាគច្រើនដាំដំណាំដូចជាស្វាយ ខ ចក ខ្នុរ ក្រូច ដំឡូង សណ្តែក សំរាប់ផ្គត់ផ្គង់បន្ថែមដល់ជីវភាពនៅក្នុងគ្រួសារ ។ល។ ប្រជាពលរដ្ឋនៅក្នុងឃុំនេះ ភាគច្រើនគាត់ដាំដំណាំហូបផ្លែលាយជាមួយស្រូវរយៈពេល ១ ឆ្នាំ ២ ឆ្នាំ ទើបគាត់ធ្វើការផ្លាស់ប្តូរ ហើយទិន្នផល ដែលប្រមូលបាន ពី ១៣00គក្រ ទៅ ១៦00គក្រ ក្នុងមួយហិកតាដោយប្រើប្រភេទស្រូវ ការ៉ែត ចារាយ ទំពួន ឡាហែល អឆង់ ដីចំការឈើហូបផ្លែនៅក្នុងឃុំប៉ុងមានទំហំសរុប ១១៨0 ហិកតា ។

**ដីកសិកម្មពនេចរ :**

ដីកសិកម្មពនេចរនៅក្នុងឃុំតឺនសំដៅលើដីចំការផ្លាស់វេនដែលមានទំហំ១២៨៩ ហិកតា ដំណាំដែលក្នុងនោះរួមមានចំការដំណាំស្រូវ និង ដំណាំរួមផ្សំ ផ្សេងៗទៀតរួមមានបន្លែបង្កាគ្រប់ប្រភេទ និងមិនមានអោយដាំដំណាំដើមឈើហូបផ្លែនិងដំណាំ យុទ្ធសាស្ត្រទេ ព្រោះដីចំការវិលជុំនេះពួកគាត់ធ្វើតែរយៈពេល២ឆ្នាំប៉ុណ្ណោះ ដែលក្នុងឆ្នាំទី១ដំណាំស្រូវទទួលបាន ទិន្នផលខ្ពស់ ចំណែកនៅឆ្នាំទី២ ផលស្រូវថយចុះបើធៀបនឹងឆ្នាំទី១។ បន្ទាប់ពីនោះគឺពួកគាត់បន្តទៅធ្វើនៅកន្លែង ផ្សេងទៀត ដែលដីនោះបានបោះបង់អស់រយៈពេល ៥ឆ្នាំមុននេះ បានក្លាយជាដីដុះដើមឈើឡើងវិញនិងមាន ជីវជាតិ ។

ដីកសិកម្មពនេចរគឺសំរាប់បងប្អូនជនជាតិភាគតិចដែលការគ្រប់គ្រងនិងកាន់កាប់ទៅតាមជំនឿ និងប្រពៃណីរបស់ប្រជាពលរដ្ឋនៅក្នុងសហគមន៏។ ចំការប្រភេទនេះច្រើកាប់នៅចំងាយពី២គ.មទៅ៣គ.មពីភូមិ ហើយចំការប្រភេទនេះពេលអនាគតនឹងក្លាយទៅជាដីលំនៅដ្ឋានអចិន្ត្រៃយ៏របស់ប្រជាពលរដ្ឋនៅក្នុងឃុំ។

**ព្រៃស្រោងសើម :**

ព្រៃស្រោងសើមនៅក្នុឃុំតឺនមានទំហំប្រមាណ ១១១៧៩ ហិកតា ជាប្រភេទព្រៃញ៉ាតមានឈើធំៗនិងមានច្រើនស្រទាប់ហើយរក្សាស្លឹករបស់វាបានពេញមួយឆ្នាំ ព្រៃប្រភេទនេះសំបូរទៅដោយដើមឈើប្រណិតៗហើយព្រៃប្រភេទនេះច្រើនមាននៅតំបន់ភ្នំ និងនៅតាមមាត់អូរ ។

**ព្រៃរបោះ :**

ព្រៃនេះរួមបញ្ចូលព្រៃរបោះចំរុះស្ងួត និងប្រភេទព្រៃ DIPTERCARP ស្ងួតមានទំហំ៦៣៧១ ហិកតា ព្រៃប្រភេទនេះសំបូរភាគច្រើនដើមឈើ ខ្លុង ត្បែង ស្រឡៅ ត្រាច ធ្នឹក ព្រៃរបោះជ្រុះស្លឹកស្ទើរតែទាំងស្រុងនៅរដូវប្រាំង។ព្រៃប្រភេទនេះងាយទទួលការឆេះ បើប្រៀបធៀបនឹងប្រភេទព្រៃផ្សេងទៀត។ លក្ខណៈធម្មជាតិព្រៃ DIPTERCARP ស្ងួតមានភាពរហាលឬចំហរ ប្រសិនបើពុំមានការរំខាន ព្រៃរបោះ អាចមានគំរបកន្សោមស្លឹកត្រឹមតែ៤០%ដី និងវាលស្មៅអាចមានឥទ្ធិពលសំខាន់លើការសំគាល់ព្រៃប្រភេទនេះ។ នៅរដូវ ប្រាំង វាមានការពិបាកក្នុង ការញែកប្រភេទព្រៃរបោះចេញពីព្រៃគម្ពោធ។

**ព្រៃស្រោងស្ងួត :**

ព្រៃស្រោងស្ងួតនៅក្នុងឃុំតឹនមានទំហំ ១៣៥ ហិកតា ជាប្រភេទព្រៃញ៉ាតមានឈើធំៗនិងមាន ច្រើនស្រទាប់ ហើយប្រភេទដើមឈើរក្សានូវស្លឹករបស់វាពេញមួយឆ្នាំ ។ ព្រៃប្រភេទនេះរួមបញ្ចូលទាំងព្រៃតំបន់ទំនាបត្រូពិច ព្រៃបៃតងតំបន់ភ្នំ ព្រៃបៃតងស្ងួត និងមានគំរបព្រៃក្រាស់ៗដែលអាចរក្សាបានសំណើមបានយូរ ។

**ព្រៃចំរុះ( ស្រោង និងរបោះ) :**

ព្រៃចំរុះ (ស្រោង និងរបោះ)នៅក្នុងឃុំតឹនមានទំហំ ១៩២៥ ហិកតាព្រៃប្រភេទនេះជាការរាប់បញ្ចូលព្រៃស្រោងនិងប្រភេទឈើនៃព្រៃរបោះ ហើយភាគរយនៃព្រៃស្រោង ប្រែប្រួលពី ៣០% ទៅ ៧០% ។ ព្រៃចំរុះមានពណ៌បៃតងពេញមួយឆ្នាំទោះបីជាព្រៃរបោះមានច្រើនលើសលប់ក៏ដោយ ។

**ព្រៃដុះឡើងវិញ :**

ប្រភេទព្រៃដុះឡើងវិញនៅក្នុងឃុំតឹនមានទំហំ ២៩៥៦ ហិតា ព្រៃដុះឡើងគឺជាព្រៃដែលបានកាប់ ឬរិចរិល ហើយត្រូវបាន ដុះឡើវិញដោយស្រទាប់កូនឈើតូចៗដែលដុះឡើងវិញជាថ្មី ម្តងទៀតបន្ទាប់ពីបានកាប់រានធ្វើចំការពនេចរអស់មួយរយៈពេលមក អាចនិយាយបានថាជាតំបន់នៃដំណុះព្រៃចាស់ៗឡើងវិញ និងមានពណ៌ខៀវខ្ចី។

**ដីវាលស្មៅ :**

ដីប្រភេទវាលស្មៅនៅឃុំតឹនមានទំហំ ១៦៨ ហិកតាដែលជាប្រភេទដីស្រែដែលគេបានបោះបងចោល ដីប្រភេទនេះពុំសូវសំបូរទៅដោយជីជាតិច្រើនទេ តែវាអាចទាក់ទាញនូវប្រភេទសត្វព្រៃដែលចូលចិត្តរស់នៅព្រោះជាកន្លែងសំបូរចំណីអាហារ តែងាយរងគ្រោះដោយភ្លើងឆេះនៅរដូវប្រាំង ។

**ចំការបោះបង់ដុះស្មៅ :**

ចំការបោះបង់ដុះស្មៅមានទំហំផ្ទៃដីនៅក្នុងឃុំតឹនសរុប ៩៨២ ហិកតាហើយភាគច្រើនប្រជាពលរដ្ឋមានទំលាប់ហៅថាព្រៃបួស ដែលបានធ្វើចំការកាលពីមុន នឹងបានបោះបង់ចោលទុកអោយដុះស្មៅ និងដំណុះព្រៃឡើងវិញ ដូចជាព្រៃតឿ ជាដើម ។

**ព្រៃគម្ពោធ :**

ព្រៃគម្ពោធមានទំហំ ៣ ហិតតាគឺជាដីមិនមែនព្រៃដែលរួមមានព្រៃគម្ពោធបៃតងជានិច្ច និងព្រៃគម្ពោធស្ងួត។ព្រៃគម្ពោធបៃតងជានិច្ច ជាការដុះលាយនៃពពួកចុល្លព្រឹក្សក្រាស់ វាលស្មៅ និងដើមឈើដែលគំរបកន្សោម

ស្លឹកក្រោម២០%។ ព្រៃប្រភេទនេះឃើញមានភាគច្រើននៅតំបន់ដីរាក់ៗ នៅលើកំពូលភ្នំក្រោមលក្ខខ័ណ្ឌអាកាសធាតុ ឬជាលទ្ធផលនៃការប្រើប្រាស់ដីមិនមាននិរន្តរភាព ។ព្រៃប្រភេទនេះអាចក្លាយទៅជាព្រៃធំៗឡើងវិញបាន។

**ចំការបោះបង់ដុះព្រៃគម្ពោធ :**

ចំការបោះបង់ដុះព្រៃគម្ពោធដែលមានទំហំ១៤៣៥ ហិតតា គឺជាដីមិនមែនព្រៃដែលរួមមានព្រៃគម្ពោធបៃតងជានិច្ច និងព្រៃគម្ពោធស្ងួត។ ព្រៃគម្ពោធបៃតងជានិច្ច ជាការដុះលាយនៃពពួកចុល្លព្រឹក្សក្រាស់ វាលស្មៅ និងដើមឈើដែលគំរបកន្សោមស្លឹកក្រោម២០%។ ព្រៃប្រភេទនេះឃើញមានភាគច្រើននៅតំបន់ដីរាក់ៗ នៅលើកំពូលភ្នំក្រោមលក្ខខ័ណ្ឌអាកាសធាតុ ឬជាលទ្ធផលនៃការប្រើប្រាស់ដីមិនមាននិរន្តរភាព ។ ព្រៃប្រភេទនេះអាចក្លាយទៅជាព្រៃធំៗឡើងវិញបាន។

**ព្រៃគម្ពោធលាយដើមឈើធំមួយៗ :**

ព្រៃគម្ពោធលាយដើមឈើធំមួយៗមានទំហំ ៥០០ហិកតាជាប្រភេទដីដែលដុះស្មៅដែលមានពណ៌ស្រស់បំព្រងនៅរដូវវស្សា និងអស់សោភ័ណ្ឌភាពនៅរដូវប្រាំងចូលមកដល់ ព្រៃប្រភេទនេះក៏មានដើមឈើធំមួយៗដែលសំបូរទៅដោ ពពួកថ្មតូចៗ និងព្រៃគម្ពោធពណ៌បៃតងជានិច្ច និងព្រៃគម្ពោធស្ងួត ។

**ព្រៃដុះតាមមាត់ទឹក :**

ព្រៃដុះតាមមាត់ទឹកដែលមានទំហំ ៣៩ ហិកតា ប្រភេទព្រៃទាំងនេះជាប្រភេទព្រៃតូចៗដែលមានពណ៌ខៀវស្រស់ស្រងាត់ និងសំបូរដោយព្រៃឬស្សី និងដើមឈើធំៗខ្លះដែរព្រៃប្រភេទនេះក៏វាអំណោយផលដល់ពពួកសត្វព្រៃដែរ ដែលពួកវាចូលចិត្តមកលេង និងរកចំណី ។

| | | |
|---|---|---|
| 1 | Code : 1200<br>ដីភូមិរស់នៅជាកលសម្ព័ន្ធ- ផ្ទះ- ឈើហូបផ្លែ |  |

| | | |
|---|---|---|
| 2 | Code : 2110<br>ស្រូវវស្សា |  |
| 3 | Code :1321<br>ដីព្រៃអារក្ស |  |
| 4 | Code : 2310<br>ចំការឈើហូបផ្លែ |  |

| | | |
|---|---|---|
| 5 | Code : 2400<br>ដីកសិកម្មពនេចរ : |  |
| 6 | Code : 3120<br>ព្រៃស្រោងសើម : |  |
| 7 | Code : 3210<br>ព្រៃរបោះ : |  |

| | | |
|---|---|---|
| 8 | Code : 3220<br>ព្រៃស្រោងស្ងួតៈ |  |
| 9 | Code : 3300<br>ព្រៃចំរុះ (ស្រោង និងស្ងួត)ៈ |  |
| 10 | Code : 3400<br>ព្រៃដុះឡើងវិញ |  |

| | | |
|---|---|---|
| 11 | Code : 4100<br>វាលស្មៅ : |  |
| 12 | Code : 4110<br>ចំការបោះបង់ដុះស្មៅ : |  |
| 13 | Code : 4500<br>ព្រៃគម្ពោធ |  |

| | | |
|---|---|---|
| 14 | Code : 4510<br>ចំការបោះបង់ដុះព្រៃគម្លោធ |  |
| 15 | Code : 4600<br>ព្រៃគម្លោធលាយដើមឈើធំមួយៗ : |  |
| 16 | Code : 3310<br>ព្រៃដុះតាមមាត់ទឹក |  |

| | | |
|---|---|---|
| 17 | Code : 5300<br>វាលភក់ : |  |

# ឧបសម្ព័ន្ធ ២

## ស្ថានភាពនៃការគ្រប់គ្រង និងកាន់កាប់ដីបច្ចុប្បន្ន (ផែនទីA-3)

| លរ | ប្រភេទនៃការគ្រប់គ្រង | ទំហំដី (ហត) | ផ្សេងៗ |
|---|---|---|---|
| ១ | សហគមន៍ព្រៃឈើតីការពារដោយសហគមន៍(១) | ២២៩៤.៤៤៧ | ដីសាធារណៈរបស់រដ្ឋ |
| | ចំការបោះបោះបង់ដុះស្មៅ | ៤៦.២០៧ | ៤ កន្លែង ស្ថិតនៅនៅក្នុងឃុំទាំងស្រុង |
| | ព្រៃរបោះ | ១១២៤.៩៧០ | ២កន្លែង |
| | ព្រៃស្រោងសើម | ១០២៤.០៣៣ | ៦ កន្លែង |
| | ព្រៃចំរុះ(ស្រោង និរបោះ) | ៣.៩០៧ | ២កន្លែង |
| | ព្រៃដុះឡើងវិញ | ៨៦.២៨៧ | ១កន្លែង |
| | ដីកសិកម្មពនេចរ | ៨.២១៩ | ៣កន្លែង |
| | ស្រូវវស្សា | ១.២២២ | ១កន្លែង |
| ២ | សហគមន៍ព្រៃឈើតីនការពារដោយសហគមន៍(២) | ៣១៤៣.៨៣១ | ដីសាធារណៈរបស់រដ្ឋ |
| | ចំការបោះបោះបង់ដុះស្មៅ | ៣១.៣៩៧ | ៣កន្លែង |
| | ព្រៃរបោះ | ១២៩២.៨០៤ | ៧កន្លែង |
| | ព្រៃស្រោងសើម | ១៥៣៦.៧៤៤ | ៤កន្លែង |
| | វាលភក់ | ១០.៦៥៦ | ១កន្លែង |
| | ព្រៃចំរុះ(ស្រោង និងរបោះ) | ៦៥.៨៣៥ | ២កន្លែង |
| | ព្រៃដុះឡើងវិញ | ១៩១.៨៣៥ | ១កន្លែង |
| | ដីកសិកម្មពនេចរ | ៣.៩៣៥ | ១កន្លែង |
| | ស្រូវវស្សា | ១០.៦២០ | ២កន្លែង |
| សរុប | | ៥៤៣៨.២៧៨ | |

ប្រភព: ទិន្នន័យGIS ប្រមូលពីមន្ទីរជំនាញពាក់ព័ន្ធជុំវិញខេត្តរតនគីរី

## ឧបសម្ព័ន្ធ ៣

## តារាងបញ្ហា មូលហេតុ ដំណោះស្រាយ

| បញ្ហា | ទីតាំង | មូលហេតុ | តំរូវការ | ឧបសគ្គ | ដំណោះស្រាយ | យោបល់ជន |
|---|---|---|---|---|---|---|
| ១ | ២ | ៤ | | | ៥ | |
| ព្រៃឈើថយចុះ | ៤ភូមិ | ការកាប់ព្រៃឈើអនាធិបតេយ្យ<br>ការរានដីព្រៃធ្វើចំការច្រើន-កំណើនប្រជាពលរដ្ឋ | បង្ក្រាបបទល្មើសព្រៃឈើ<br>ព្រៃឈើនៅគង់វង្ស | | -ពង្រឹងវិធានការណ៏គ្រប់គ្រងការពារ<br>- ផ្សព្វផ្សាយច្បាប់ព្រៃឈើ<br>- ដាំកូនឈើឡើងវិញ<br>- ពង្រឹងគណៈកម្មាការគ្រប់គ្រង | |
| សត្វព្រៃមានការថយចុះ | ៤ភូមិ | -ការបរបាញ់ខុសច្បាប់<br>-បំផ្លាញជំរកសត្វ<br>-ការប្រែប្រួលសង្គម | សត្វព្រៃកើនឡើង | | - ទប់ស្កាត់ការបរបាញ់ខុសច្បាប់<br>- ទប់ស្កាត បំផ្លាញជំរកសត្វ | |
| ផ្លូវលំក្រាលគ្រួសក្រហម | ៤ភូមិ | ផ្លូវលំបាកធ្វើដំណើរ | ងាយស្រួលក្នុងការធ្វើដំណើរ | | - ជួសជុលផ្លូវលំ<br>-សាងសង់ស្ពានឈើ<br>-សាងសង់លូកាត់ផ្លូវ | |
| សត្វឈឺច្រើន | ៤ភូមិ | -ខ្វះបច្ចេកទេសក្នុងការថែទាំសត្វ | -ផ្តល់បច្ចេកទេសក្នុងការថែទាំសត្វ | | -បណ្តុះបណ្តាលច្ចេកទេសចិញ្ចឹមសត្វ<br>- ចាក់ព្យាបាល,ចាក់វ៉ាក់សាំងការពារ | |

| | | | | | | |
|---|---|---|---|---|---|---|
| | | - ខ្វះថ្នាំព្យាបាល,ការពារ<br>- ពេទ្យសត្វនៅមានកំរិតយល់ដឹង | -ផ្តល់ថ្នាំព្យាបាលការពារ<br>- ពេទ្យសតមានកំរិតយល់ដឹងខ្ពស់ | | - បណ្តុះបណ្តាលច្នេកទេសដល់ពេទ្យសត្វ និងកសិករ ឱ្យមានការយល់ដឹង | |
| ត្រីមានការថយចុះ | ៤ភូមិ | ការនេសាទខុសច្បាប់ | មានម្ហូបអាហារហូបគ្រប់គ្រាន់ដោយត្រីសំបូរឡើងវិញ។ | | ជីស្រះចញ្ចឹមត្រីជាលក្ខណះគ្រួសារ ផ្តល់ពូជត្រី ផ្សព្វផ្សាយច្បាប់ជលផលទប់ស្កាត់ការប្រើឧបករណ៏នេសាទខុសច្បាប់។<br>រៀបចំបញ្ហាផ្ទៃក្នុងសំរាប់ក្រុមអ្នកទទួលផល ។<br>ឡើងទឹកចិត្តការចិញ្ចឹមត្រីតាមត្រពាំងធម្មជាតិ និង ជាលក្ខណះគ្រួសារ<br>ផ្តល់សត្វស្រុកចិញ្ចឹមតាមគ្រួសារ<br>បណ្តុះបណ្តាលពីការចិញ្ចឹមសត្វ ។ | |
| គ្មានបង្គន់អនាម័យ | ៤ភូមិ | ខ្វះបង្គន់អនាម័យប្រើប្រាស់ | - មានបង្គន់អនាម័យប្រើប្រាស់ | | - ផ្តល់បង្គន់អនាម័យប្រើប្រាស់តាមក្រុម<br>-បង្កើតគណៈកម្មាការថែទាំ | |

| | | | | | | |
|---|---|---|---|---|---|---|
| ខ្វះពូជគោល្អ | ៤ភូមិ | គ្មានថវិកាទិញ | ទិញពូជគោល្អៗ | | -ទិញពូជគោល្អៗយកមកប្រើប្រាស់ | |
| អំពើហឹង្សាក្នុងគ្រួសារ | ៤ភូមិ | -ជីវភាពមិនគ្រប់គ្រាន់<br>-ការប្រចណ្ឌ<br>-សេពគ្រឿងញៀន | -គ្មានអំពើហឹង្សាក្នុងគ្រួសារ | | - ផ្សព្វផ្សាយពីច្បាប់អំពើហឹង្សាក្នុងគ្រួសារ តាមរយៈ<br>-ការសែត,ទស្សនាវដ្ដី<br>-វីដេអូ<br>-រូបភាព | |
| ដីខ្សោះជីជាតិ | ៤ភូមិ | -ការហូរច្រោះជីជាតិដី | ដីមានជីជាតិឡើងវិញ | | - ផ្លាសលប្ដូរមុខដំណាំ<br>- ដាំដំណាំឆ្លាស់<br>-ធ្វើរបាវណ្ឌ<br>-ទប់ស្កាត់ភ្លើងឆេះព្រៃ | |
| ប្រជាជនឈឺច្រើន | ៤ភូមិ | -ខ្វះអនាម័យ<br>-ខ្វះថ្នាំបង្កា<br>-ហូបចុកមិនគ្រប់គ្រាន់ | -សុខភាពប្រជាជនប្រសើរឡើង | | -ចាក់វ៉ាក់សាំងការពារ<br>-ផ្ដល់មុងជ្រលក់ថ្នាំ<br>-វគ្គអប់រំសុខភាព<br>-ពង្រឹងភ្នាក់ងារសុខភាពភូមិ | |
| ទិន្នផលស្រូវទាប | ៤ភូមិ | - ខ្វះពូជស្រូវទំនើបៗ<br>-ឧបករណ៍កសិកម្មទំនើបៗ<br>-ខ្វះបច្ចេកទេសដាំដុះ | ស្បៀងហូបគ្រប់គ្រាន់ | | -ផ្ដល់ពូជស្រូវល្អៗ<br>-ផ្ដល់បច្ចេកទេស | |

| | | | | | | |
|---|---|---|---|---|---|---|
| បាត់បង់ប្រពៃណី<br>ជនជាតិដើមភាគតិច | ៤ភូមិ | -សង្គម<br>-ការហូរចូលនូវសាសនា<br>-ការថែទាំវត្ថុបុរាណ | រក្សាប្រពៃណីជនជាតិដើមភាគ<br>តិចអោយប្រសើរ<br>ឡើង | | -ទប់ស្កាត់ការលក់វត្ថុបុរាណ<br>-បង្កើតសហគមន៍តាំងវត្ថុបុរាណ<br>-ពង្រឹងប្រពៃណីទំនៀមទំលាប់ | |
| ខ្វះទឹកស្អាតប្រើប្រាស់ | ៤ភូមិ | ខ្វះសំភារៈបរិក្ខាផ្តល់ទឹកស្អា<br>ត | មានទឹកស្អាតប្រើប្រាស់ | | ក-១-ជីកអណ្តូងស្នប់<br>ក-២-ជីកអណ្តូងលូ<br>ក-៣-ជីកអណ្តូងដៃ | |
| គ្មានប្រពន្ធ័ស្រោចស្រព | ៤ភូមិ | -ខ្វះប្រពន្ធ័ប្រឡាយ<br>-ទំនប់មានស្រាប់ខូចខាត | មានទឹកស្រោចស្រពដំណាំ | | - ជួសជុលប្រពន្ធ័ប្រឡាយ<br>- ជួសជុលទំនប់ដែលមានស្រាប់ | |

## ឧបសម្ព័ន្ធ ៤

## ក្របខ័ណ្ឌនៃការអភិវឌ្ឍន៍ និងវិស័យនៃការប្រើប្រាស់ដីធ្លីអនាគត

## កំណត់តម្រូវការនៃការអភិវឌ្ឍន៍ គោលដៅ និងយុទ្ធសាស្ត្រ (តារាង)

| តម្រូវការនៃ ការអភិវឌ្ឍន៍ | ប្រភពឯកសារ | គោលដៅនៃ ការអភិវឌ្ឍន៍ | យុទ្ធសាស្ត្រនៃ ការអភិវឌ្ឍន៍ | សកម្មភាពជា អាទិភាព | លេខរៀង នៅលើ ផែនទី |
|---|---|---|---|---|---|
| ១ | ២ | ៣ | ៤ | ៥ | ៦ |
| ចង់បានសត្វកើនឡើង | -ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ តឹន ស្រុកកូនមុំ ខេត្ត រតនគិរី ។ | ធ្វើអោយសត្វរបស់ប្រជាពល រដ្ឋមានសុខភាពល្អ កើនឡើង | -បង្កើនការចិញ្ចឹមសត្វ | - ចាក់វ៉ាក់សាំងកាពារ,ថ្នាំព្យាបាល<br>- វគ្គបណ្តុះបណ្តាលកាចិញ្ចឹមសត្វ | |
| ផ្លូវងាយស្រួលធ្វើដំណើរ | -ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ តឹន ស្រុកកូនមុំ ខេត្ត រតនគិរី ។ | មានផ្លូវប្រើប្រាស់ល្អប្រសើរ | សាងសង់ផ្លូវលំ | - សាងសង់ និងជួសជុល<br>- ដាក់លូកាត់ផ្លូវ<br>-សាងសង់ស្ពាន | |
| ចង់អោយមានទឹកស្អាត ប្រើប្រាស់ | -ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ តឹន ស្រុកកូនមុំ ខេត្ត | ធ្វើអោយប្រជាពលរដ្ឋប្រើ ប្រាស់ប្រកបដោយអនាម័យ | រៀបចំប្រព័ន្ធទឹកស្អាត តាមលំនៅដ្ឋាន | - ជីកអណ្តូងស្នប់<br>- ជីកអណ្តូងលូ<br>- ជីកអណ្តូងដៃ | |

| | | | | | |
|---|---|---|---|---|---|
| | រតនគិរី ។ | | | - ជីក ស្រះទឹកស្អាត<br>- ធុងចម្រោះ<br>- ផ្តល់ពាងយក្ស<br>- ធ្វើអាងតំកល់ទឹក | |
| ព្រៃឈើនៅគង់វង្សកើនឡើង | -ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ តឺន ស្រុកកូនមុំ ខេត្ត រតនគិរី ។ | សហគមន៏មានការយល់ដឹងពីច្បាប់ព្រៃឈើ,សហការណ៏ជាមួយស្ថាបន័ពាក់ពន្ធ័ | ពង្រឹងដល់គណៈកម្មាការ<br>និងផ្សព្វផ្សាយពីច្បាប់ព្រៃឈើដល់សហគមន៏ | ផ្សព្វផ្សាយពីច្បាប់ព្រៃឈើដល់សហគមន៏, ទប់ស្កាត់ក្រុមអាណាធិបតេយ្យកាប់រានដ្ឋចំការពនេចរ | |
| ចង់អោយប្រជាពលរដ្ឋមិនចេះអក្សរបានចូលរៀន | -ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ តឺន ស្រុកកូនមុំ ខេត្ត រតនគិរី ។ | ប្រជាពលរដ្ឋ៥៥ភាគរយចេះអាន និង សរសេរ | លើកកំពស់ការអប់រំ មនុស្សចាស់ | - ជួសជុលសាលាបឋមសិក្សាចាស់<br>- សាងសង់អាគារសិក្សាសាលា បឋមបន្ថែម<br>- សាងសង់អាគារសិក្សាអនុវិទ្យាល័យបន្ថែម<br>- បើកថ្នាក់អក្ខរកម្ម<br>- បណ្តុះបណ្តាលគ្រូអក្ខរកម្ម<br>- ផ្តល់សំភារៈសិក្សាដល់ថ្នាក់ អក្ខរកម្ម និងឧបត្ថម្ភដល់គ្រូ<br>- ផ្តល់មុខវិជ្ជាជីវៈ | |

| | | | | | |
|---|---|---|---|---|---|
| ចង់អោយប្រជាពលរដ្ឋរស់នៅប្រកបដោយសុខមាលភាព | | ប្រជាពលរដ្ឋនៅក្នុងឃុំត្រូវបានទទួលបានសេវាកម្មថែទាំសុខភាពគ្រប់ៗគ្នា | លើកកំពស់ការថែទាំសុខភាពសាធារណៈ | - បង្កើតប៉ុស្តិសុខភាពតាមភូមិ<br>-បណ្តុះបណ្តាលពេទ្យឆ្មបមូលដ្ឋាន<br>-ផ្តល់សំភារៈនិង មធ្យោបាយដល់ប៉ុស្តិសុខភាពតាមភូមិ<br>-សំអាតផ្លូវធ្វើដំណើរតាមទឹក | |
| ចង់អោយប្រជាពលរដ្ឋរស់នៅមានអនាម័យ និងសុខភាព | -ផែនការអភិវឌ្ឍន៏ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំតឹន ស្រុកកូនមុំ ខេត្តរតនគិរី ។ | -ធ្វើអោយប្រជាពលរដ្ឋរស់នៅមានសុខភាព និងអនាម័យ | លើកកំពស់ សុខភាព និងអនាម័យ | - អប់រំពីការប្រើប្រាស់បង្គន់<br>- អប់រំសុខភាព អនាម័យ<br>- សាងសង់បង្គន់អនាម័យ | |
| ចង់បានដីមានជីជាតិឡើងវិញ | | -ធ្វើអោយប្រសើរឡើងនូវជីជាតិដី | កែលំអរដីអោយ មានជីជាតិ | - បណ្តុះបណ្តាលការប្រើប្រាស់ជីធម្មជាតិ<br>- បណ្តុះបណ្តាលការធ្វើជីកំប៉ុស្តិ<br>- ផ្សព្វផ្សាយបច្ចេកទេសប្រើប្រាស់ជីគីមី<br>- បណ្តុះបណ្តាលបច្ចេកទេសធ្វើស្រែបង្កើនរដូវ<br>- វគ្គបណ្តុះបណ្តាល អំពីការកែប្រែគុណភាពដី | |

| | | | | | |
|---|---|---|---|---|---|
| | | | | - បណ្តុះបណ្តាលបច្ចេកទេស ដាំ ឈើហូបផ្លែ និង ដាំដំណាំឆ្លាស់<br>- បណ្តុះបណ្តាលពីការថែរក្សា ជីវចំរុះតាមវាលស្រែ | |
| ចង់បានស្រូវមានគុណភាព ល្អ និងមានហូបគ្រប់គ្រាន់ | -ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ តឺន ស្រុកកូនមុំ ខេត្ត រតនគិរី ។ | រកពូជស្រូវមានគុណភាព | កែលំអរប្រពន្ធ័ដាំដុះ | - ប្រើជីធម្មជាតិ<br>- ធ្វើជីកំប៉ុស្តិ៍<br>- ផ្តល់បច្ចេកទេសរៀបចំស្រែ<br>- ផ្តល់បច្ចេកទេសប្រើប្រាស់ពូជ ទំនើប<br>- ធ្វើស្រែបង្កើនរដូវ<br>- ពង្រីកផ្ទៃដីស្រែដែលមានស្រាប់<br>- បណ្តុះបណ្តាលផលិតកម្ម ដំណាំស្រូវ<br>.- ដាំស្រូវតាមធម្មជាតិ<br>.- សាលាស្រែកសិករ | |
| ចង់អោយប្រជាពលរដ្ឋ មានមុខរបរគ្រប់គ្នា | -ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ តឺន ស្រុកកូនមុំ ខេត្ត | ធ្វើឱ្យជីវភាពប្រជាពលរដ្ឋ មានភាពប្រសើរឡើង | បង្កើនជំនាញ និង ប្រាក់ចំណូល | - បណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ង្កើតក្រុមសន្សំប្រាក់<br>- ចិញ្ចឹម មាន់ ទា ជ្រូក | |

| | | | | | |
|---|---|---|---|---|---|
| | រតនគិរី ។ | | | - ធានា គោ ក្របី មេ<br>- ក្រុមដាំបន្លែ និង ដំណាំរយៈខ្លី | |
| ចង់បានសព្វព្រៃសំបូរ ឡើងវិញ | -ផែនការអភិវឌ្ឍន៏ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ តឹន ស្រុកកូនមុំ ខេត្ត រតនគិរី ។ | ធ្វើឱ្យសព្វព្រៃសំបូរឡើងវិញ | - បង្កើនការគ្រប់គ្រង និងការពារសព្វព្រៃ<br>- កែលំអរជីវភាព សុខភាពប្រជាពលរដ្ឋ | - រៀបចំស្លាកសញ្ញានិង បោះ បង្គោល កន្លែងអភិរក្ស<br>- ទប់ស្កាត់ការដាក់អន្ទាក់និង វាយលបចាប់សត្វ<br>- ទប់ស្កាត់ការប្រើឧបករណ៏ បំពងសំឡេងចាប់សត្វ<br>- ទប់ស្កាត់ការប្រើថ្នាំពុលចាប់សត្វ<br>- បង្កើតតំបន់អភិរក្សសព្វព្រៃ | |
| ចង់អោយប្រពៃណីជនជាតិ ដើមភាគតិចប្រសើរឡើង | -ផែនការអភិវឌ្ឍន៏ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ តឹន ស្រុកកូនមុំ ខេត្ត រតនគិរី ។ | ថែរក្សាវប្បធមិប្រពៃណី,ចាស់,ក្មេង | ថែរក្សាវប្បធមិប្រពៃណីគង់វង្សទៅអនាគត | -សាងសង់មជ្ឈមណ្ឌលជនជាតិដើមភាគតិ<br>-ទប់ស្កាត់វប្បធមិខាងក្រៅ<br>- បង្កើតសហគមន៏តាំងវត្ថុបុរាណ | |
| ជួសជុលប្រពន្ធ័ធារាសាស្រ្ត | -ផែនការអភិវឌ្ឍន៏ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំ តឹន ស្រុកកូនមុំ ខេត្ត រតនគិរី ។ | មានប្រពន្ធ័ស្រោចស្រពគ្រប់គ្រាន់ | -ស្តារឡើងវិញនូវប្រពន្ធ័ប្រឡាយដែលមានស្រាប់ | -ជួសជុលឡើងវិញនូវប្រពន្ធ័ប្រឡាយដែលមានស្រាប់ | |

| | | | | | |
|---|---|---|---|---|---|
| កាត់បន្ថយ អំពើហឹង្សាក្នុងគ្រួសារ | -ផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០០៨-២០១២ របស់ឃុំតឺន ស្រុកកូនមុំ ខេត្តរតនគិរី ។ | លុបបំបាត់អំពើហឹង្សា និងស្គាល់អំពីតួនាទីបុរស-ស្ត្រីក្នុងសង្គម | -ផ្តល់ឱកាសដល់ស្ត្រី និងកុមារ<br>-លើកទឹកចិត្តដល់ស្ត្រីក្នុងការចូលរួមយោបល់ | -ផ្សព្វផ្សាយពីតួនាទីភារៈកិច្ចបុរស-ស្ត្រី<br>-ផ្សព្វផ្សាយអប់រំតាមរយៈវីដេអូ និងរូបភាពផ្សេងៗ | |

# ឧបសម្ព័ន្ធ ៥

## បញ្ជីគំរោង ឬសកម្មភាពសំខាន់របស់ឃុំ ក្នុងរយៈពេល ១៥ឆ្នាំ

| ល.រ | គំរោង ឬសកម្មភាព | លទ្ធផលគ្រោង | | ផែនការប្រើប្រាស់ដីធ្លី ១៥ ឆ្នាំ | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | ចំនួន | ឯកត្តា | ៥ឆ្នាំទី១[១] | ៥ឆ្នាំទី២[២] | ៥ឆ្នាំទី៣[៣] | |
| ២.៦.១. | គំរោងផ្នែកហេដ្ឋរចនាសម្ព័ន្ធ | | | | | | |
| | **២.៦.១.១. គំរោងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត** | | | | | | |
| | **១.១. ផ្លូវថ្នល់** | | | | | | |
| | ១.១.១. សាងសង់ផ្លូវលំក្រាលគ្រួសក្រហម | ៣ | ខ្សែ | ១ | ១ | ១ | ១០,០០០ម |
| | ១.១.២. ជួសជុលផ្លូវលំក្រាលគ្រួសក្រហម | ១ | ខ្សែ | | ១ | | ១៤,០០០ម |
| | ១.១.៣. សាងសង់ស្ពានឈើ | ៧ | កន្លែង | ២ | ៣ | ២ | |
| | ១.១.៤. សាងសង់លូកាត់ផ្លូវ | ៦ | កន្លែង | ១ | ២ | ៣ | |
| | **១.២. ប្រព័ន្ធស្រោចស្រព** | | | | | | |
| | ១.២.១. ជួសជុលទំនប់ទឹក | ១ | ខ្សែ | ១ | | | |
| | ១.២.២. ស្តារប្រពន្ធ័ប្រឡាយឡើងវិញ | ២ | ខ្សែ | | ១ | ១ | |

[១] - ៥ឆ្នាំទី១ (២០០៨-២០១២): បញ្ចូលគំរោងទាំងអស់របស់ **CDP** ឆ្នាំ ២០០៨-២០១២ រួមទាំងគំរោងផ្នែកប្រើប្រាស់ដីដែលបានបង្កើតក្នុង **CLUP** ផងដែរ (៥ ឆ្នាំទី១)

[២] - ៥ឆ្នាំទី២ (២០១៣-២០១៧): គំរោងទាំងឡាយនៃផែនការប្រើប្រាស់ដីធ្លីឃុំ **CLUP** សំរាប់អោយឃុំប្រើជាមូលដ្ឋានក្នុងការកសាង **CDP** ៥ឆ្នាំបន្ត (៥ ឆ្នាំទី២)

[៣] - ៥ឆ្នាំទី២ (២០១៨-២០២២): គំរោងទាំងឡាយនៃផែនការប្រើប្រាស់ដីធ្លីឃុំ **CLUP** សំរាប់អោយឃុំប្រើជាមូលដ្ឋានក្នុងការកសាង **CDP** ៥ឆ្នាំបន្តទៀត (៥ ឆ្នាំទី៣)

| | | | | | | | |
|---|---|---|---|---|---|---|---|
| | **១.៣. ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀត** | | | | | | |
| | ១.៣.១. ជីកស្រះចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ | ៥០ | កន្លែង | ២០ | ១០ | ២០ | |
| | ១.៣.២. សាងសង់មជ្ឈមណ្ឌលវប្បធម៌ជនជាតិដើមភាគតិច | ៤ | ខ្នង | ១ | ២ | ១ | |
| | ១.៣.៣. ជួសជុលអណ្តូងខូចខាត | ១៥ | អណ្តូង | ៤ | ៥ | ៦ | |
| | ១.៣.៤. សាងសង់សាលារៀន | ៨ | ខ្នង | ៤ | ២ | ២ | |
| | ១.៣.៥. ផ្សេងៗ | | | | | | |
| | **២.៦.១.២. ហេដ្ឋារចនាសម្ព័ន្ធសង្គម និងសេវាកម្មផ្សេងៗ** | | | | | | |
| | ២.៦.១.២.១. ការសិក្សា និងអប់រំ | | | | | | |
| | ២.៦.១.២.២. សាលាមត្តេយ្យ | ០១ | ខ្នង | ១ | ១ | ១ | |
| | ២.៦.១.២.៣. សាលាបឋមសិក្សា | ០១ | ខ្នង | ១ | ១ | ១ | |
| | ២.៦.១.២.៤. សាលាមធ្យមសិក្សា | ០១ | ខ្នង | ១ | ១ | ១ | |
| | ២.៦.១.២.៥. ផ្តល់គ្រូគ្រប់កំរិត | ០៤ | កន្លែង | ០៤ | | | |
| | **២.៦.១.៣. សុខភាព និងអនាម័យ** | | | | | | |
| | ២.៦.១.៤. បុស្តិ៍សុខភាព | ០១ | កន្លែង | ១ | | | |
| | ២.៦.១.៥. ប៉ុស្តិ៍សុខភាពតាមភូមិ | ៤ | កន្លែង | ១ | ១ | ២ | |
| | ២.៦.១.៦. ផ្តល់ធុងចំរោះទឹកស្អាត | ៥៤៧ | ធុង | ១៤៧ | ២០០ | ២០០ | |
| | ២.៦.១.៧. អណ្តូងទឹកស្អាតបន្ថែម | ១១ | កន្លែង | ៣ | ៤ | ៤ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | ២.៦.១.៨. ផ្តល់បង្គន់អនាម័យ | ៥៤៧ | បង្គន់ | ១៤៧ | ២០០ | ២០០ | |
| | **២.៦.១.៤. សន្តិសុខ និងសណ្តាប់ធ្នាប់** | | | | | | |
| | ២.៦.១.៤.១. វគ្គបណ្តុះបណ្តាលការងាររដ្ឋបាលនិង អភិបាលកិច្ចដល់ គ. ផ. ថ | ១៥ | លើក | ៥ | ៥ | ៥ | |
| | ២.៦.១.៤.២. ទប់ស្កាត់ការហូរចូល នូវគ្រឿងញៀន | ៥ | លើក | ១ | ២ | ២ | |
| | ២.៦.១.៤.៣. ពង្រឹងមន្ត្រីប៉ុស្តិ៍រដ្ឋបាលឃុំ | ៣ | លើក | ១ | ១ | ១ | |
| | ២.៦.១.៤.៤. ទប់ស្កាត់ការនេសាទខុសច្បាប់ | ១៥ | លើក | ៥ | ៥ | ៥ | |
| | ២.៦.១.៤.៥. ពង្រឹងប្រព័ន្ធកសាងផែនការតាមមូលដ្ឋាន | ០១ | កន្លែង | | ១ | | |
| | **២.៦.១.៥. កន្លែងគោរពបូជា** | | | | | | |
| | ២.៦.១.៥.១. ទីកន្លែងសាការៈបូជា | ៤ | កន្លែង | ២ | ១ | ១ | |
| | ២.៦.១.៥.២. វត្តព្រះអារាម | ១ | កន្លែង | | ១ | | |
| | ២.៦.១.៥.៣. សាលាឆទាន | ២ | កន្លែង | ១ | ១ | | |
| | ២.៦.១.៥.៤. សាឡុម ជនជាតិ ឥស្លាម | ១ | កន្លែង | ១ | | | |
| ២.៦.២. | គំរោងផ្នែកប្រើប្រាស់ដីធ្លី | | | | | | |
| | **២.៦.២.១. គំរោងប្រើប្រាស់ដីតាមវិស័យធំៗ** | | | | | | |
| | ២.៦.២.១.១. ដីតំបន់ប្រើប្រាស់ច្រើនយ៉ាង | | ហិកតា | | | | |
| | ២.៦.២.១.២. ដីសម្បទានសង្គមកិច្ច | | ហិកតា | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | **២.៦.២.២. គំរោងប្រើប្រាស់ដីលក្ខណៈសហគមន៍ភូមិ-ឃុំ** | | | | | | |
| | ២.៦.២.២.១. ដីភូមិ | ៥.៥៤៩ | ហិកតា | | | | |
| | ២.៦.២.២.២. ដីវាលកប់ខ្មោច | ៣.៤៥០ | ហិកតា | | | | |
| | ២.៦.២.២.៣. ដីវាលស្រែ | ២៨៣ | ហិកតា | | | | |
| | ២.៦.២.២.៤. ដីចំការពនេចរ | ៣២៨ | ហិកតា | | | | |
| | ២.៦.២.២.៥. ដីចំការដំណាំរយៈពេលខ្លី | ២៣៤ | ហិកតា | | | | |
| | ២.៦.២.២.៦. ដីចំការដំណាំឈើហូបផ្លែ | ១១៨០.២៤៥ | ហិកតា | | | | |
| | ២.៦.២.២.៧. ផ្សេងៗ | | | | | | |
| | **២.៦.២.៣. គំរោងផ្នែកបង្កើនជំនាញ និងមុខរបរ** | | | | | | |
| | ២.៦.២.៣.១. វគ្គបណ្តុះបណ្តាលអំពីការធ្វើស្រែបង្កើនរដូវ | ៨ | លើក | ៤ | ៤ | | |
| | ២.៦.២.៣.២. វគ្គបណ្តុះបណ្តាល អំពីការប្រើប្រាស់ដីធម្មជាតិ | ៨ | លើក | ៤ | ៤ | | |
| | ២.៦.២.៣.៣. ផ្សព្វផ្សាយពីច្បាប់ជលផល | ៣ | លើក | ១ | ១ | ១ | |
| | ២.៦.២.៣.៤. បង្កើតគណៈកម្មាការគ្រប់គ្រងជលផល | ១ | លើក | ១ | | | |
| | | | | | | | |